## សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
## មហាវិទ្យាល័យវិទ្យាសាស្ត្រ
## ដេប៉ាតឺម៉ង់បរិស្ថាន

របាយការណ៍សិក្សាស្រាវជ្រាវនេះជាផ្នែកមួយនៃតម្រូវការដើម្បី
បញ្ចប់ថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្របរិស្ថាន

# សក្ដានុពលនៃការអនុវត្តប្រតិភូកម្មមុខងារ ជួសជុល និងថែទាំ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ

ករណីសិក្សា ឃុំមង់រៀវនិងឃុំជីគរ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ


ស្រាវជ្រាវដោយ៖ ថៃ សិរីរតនា
ឈឿត ស្រីម៉ាច
ជុន សុខលី
អោ ថៃបូណា

គណៈកម្មការវាយតម្លៃ៖ ជា អេលីយ៉ាន (គ្រូដឹកនាំ)
ចាន់ វីរៈ
សុវណ្ណ ច័ន្ទសុភត្រា


មិថុនា ២០១៦

# សេចក្ដីថ្លែងការណ៍ទទួលរបាយការណ៍ស្រាវជ្រាវ

គណៈកម្មការវាយតម្លៃលទ្ធផល សិក្សាស្រាវជ្រាវសម្រាប់និស្សិត បញ្ចប់បរិញ្ញាបត្រ របស់ដេប៉ាតឺម៉ង់បរិស្ថាន នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ យល់ព្រមទទួលយកលទ្ធផលនៃការស្រាវជ្រាវក្រោមប្រធានបទ "**សក្ដានុពលនៃការអនុវត្តប្រតិភូកម្មមុខងារ ជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ**" ករណីសិក្សានៅ ឃុំមង់រៀវនិងឃុំជីគរ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ដែលសិក្សាស្រាវជ្រាវដោយក្រុមនិស្សិត កញ្ញាថៃ សិរីរតនា កញ្ញាឈឿត ស្រីម៉ាច កញ្ញាជុន សុខលី លោកអោ ថៃបូណា។

របាយការណ៍សិក្សាស្រាវជ្រាវនេះ ជាផ្នែកមួយនៃតម្រូវការរបស់ដេប៉ាតឺម៉ង់បរិស្ថាន ដើម្បីឱ្យនិស្សិតបញ្ចប់ថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្របរិស្ថាន។

......................................

**លោកគ្រូ សុវណ្ណ ច័ន្ទសុភត្រា**

សមាជិក

........................................

**លោកគ្រូ ចាន់ ទីរៈ**

សមាជិក

.....................................

**អ្នកគ្រូ ជា អេលីយ៉ាន**

ប្រធាន

កាលបរិច្ឆេទ៖ ......../....../.....

# សេចក្តីថ្លែងអំណរគុណ

ដេប៉ាតឺម៉ង់បរិស្ថាន នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ តម្រូវឱ្យមានការសិក្សាស្រាវជ្រាវសម្រាប់បញ្ចប់ថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្របរិស្ថាន ដែលការសិក្សានេះបានទទួលលទ្ធផលជាផ្លែផ្ការហូតមកដល់ពេលនេះ យើងខ្ញុំសូមសម្តែងនូវអំណរគុណ និងការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ៖

**សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងដេប៉ាតឺម៉ង់បរិស្ថាន** បានផ្តល់នូវឱកាសដ៏មានតម្លៃដល់យើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវ ដើម្បីទទួលបាននូវចំណេះដឹងយ៉ាងទូលំទូលាយ និងជាមធ្យោបាយសម្រាប់បញ្ចប់ឆ្នាំសិក្សា ហើយកសាងអនាគតដ៏ភ្លឺស្វាង។

អ្នកគ្រូ **ជា អេលីយ៉ាន** ជាសាស្ត្រាចារ្យដឹកនាំ ដែលបានលះបង់ពេលវេលាដ៏មានតម្លៃក្នុងការជួយណែនាំចង្អុលបង្ហាញ និងកែតម្រូវរាល់កំហុសឆ្គងដែលកើតមានក្នុងពេលធ្វើការសិក្សាស្រាវជ្រាវរហូតដល់ទទួលបានលទ្ធផលជាទីគាប់ចិត្ត។

លោកគ្រូ **ចាន់ វីរៈ** និងលោកគ្រូ **សុវណ្ណ ច័ន្ទសុភត្រា** ជាគណៈកម្មការវាយតម្លៃលើការសិក្សាស្រាវជ្រាវ ដែលបានលះបង់ពេលវេលាដ៏មានតម្លៃក្នុងការត្រួតពិនិត្យ និងវាយតម្លៃលើរបាយការណ៍ ស្រាវជ្រាវមួយនេះប្រកបដោយសុក្រិតភាព តម្លាភាព និងយុត្តិធម៌។

ជនបង្គោលចំនួន៦រូប ចំពោះការផ្តល់បទសម្ភាសន៍ និងអនុសាសន៍។ លើសពីនេះសូមថ្លែងអំណរគុណដល់ មិត្តភ័ក្រ្ត និងសិស្សច្បង ដែលតែងតែលើកទឹកចិត្តនិងផ្តល់ដំបូន្មានមួយចំនួន។ លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យទាំងអស់ ដែលបានចំណាយពេលវេលាក្នុងការបង្ហាត់បង្រៀនព្រមទាំងផ្តល់នូវចំណេះដឹងល្អៗ ដល់យើងខ្ញុំជារៀងដរាបមកពោលគឺតាំងពីអំឡុងពេល ដែលពួកយើងចូលរៀនថ្នាក់មតេយ្យសិក្សារហូតដល់ថ្នាក់ឧត្តមសិក្សា។

ជាចុងបញ្ចប់ យើងខ្ញុំទាំងបួននាក់ សូមសម្តែងការដឹងគុណជាអនេកប្បការចំពោះ **អ្នកមានគុណទាំងពីរ** ដែលបានផ្តល់កំណើត ការបីបាច់ថែរក្សា ការអប់រំទូន្មានប្រៀនប្រដៅ និងព្រហ្មវិហារធម៌ចំពោះកូនៗ ព្រមទាំងការគាំទ្រទាំងផ្លូវចិត្ត និងសម្ភារៈ ដើម្បីឱ្យកូនទទួលបានឱកាសរៀនសូត្រយ៉ាងត្រចះត្រចង់ដូចបច្ចុប្បន្ននេះ។

# សេចក្តីអំណះអំណាង

ក្រុមនិស្សិតយើងខ្ញុំឈ្មោះ **ថៃ សិរីរតនា ឈឿត ស្រីម៉ាច ជុន សុខលី និងអោ ថៃបូណា**។ សូមធានាអះអាងថា របាយការណ៍សិក្សាស្រាវជ្រាវក្រោមប្រធានបទៈ"**សក្តានុពលនៃការអនុវត្តប្រតិបត្តិកម្មមុខងារ ជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ**" ករណីសិក្សានៅឃុំមង់រៀវ និងឃុំជីគរ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ "គ្មានការចម្លងផ្នែកណាមួយពីរបាយការណ៍សិក្សាស្រាវជ្រាវផ្សេងៗ ដែលធ្លាប់បានដាក់ជូនសាកលវិទ្យាល័យ ឬស្ថាប័នណាទេ។

សូមបញ្ជាក់ថា លទ្ធផលដែលមានក្នុងរបាយការណ៍នេះ សុទ្ធសឹងបានមកពីចំណេះដឹងផ្ទាល់ និងការខិតខំប្រឹងប្រែងរបស់យើងខ្ញុំទាំងអស់គ្នា ដោយគ្មានការចម្លងផ្នែកណាមួយពីឯកសារផ្សេងៗនោះទេ បើមានក៏យើងខ្ញុំបញ្ជាក់ពីប្រភពនៃឯកសារទាំងនោះផងដែរ។

| ..................... | ....................... | .................... | .................... |
|---|---|---|---|
| ថៃ សិរីរតនា | ឈឿត ស្រីម៉ាច | ជុន សុខលី | អោ ថៃបូណា |

# មូលន័យសង្ខេប

ប្រជាជនជនបទប្រមាណ ៦.៣លាននាក់នៃចំនួនប្រជាជនសរុប គឺពុំទាន់មានលទ្ធភាពទទួលទឹកដែលមានសុវត្ថិភាព និងអនាម័យជាមូលដ្ឋានសម្រាប់ការប្រើប្រាស់នៅឡើយ (UNICEF, 2014)។ ទន្ទឹមនឹងអត្រាទទួលបានទឹកស្អាតប្រើប្រាស់ជាមូលដ្ឋាននៅមានកម្រិតទាប រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រថ្មីតាមរយៈ ការធ្វើកំណែទម្រង់គោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ក្រសួងអភិវឌ្ឍន៍ជនបទ, (២០១៥ក) បានធ្វើប្រតិភូកម្មមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកជនបទទៅស្រុកត្បូងឃ្មុំ គឺអនុម័តឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ មានសិទ្ធិអំណាចការទទួលខុសត្រូវក៏ដូចជាគណនេយ្យភាពក្នុងការគ្រប់គ្រងចាត់ចែងលើប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅជនបទដោយរួមមានការជួសជុល ការធ្វើតេស្តគុណភាពនិងការធ្វើបញ្ជីសារពើភ័ណ្ឌនានាទាំងអស់ ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីផ្តល់សេវានិងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន លើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋ និងចូលរួមចំណែកកាត់បន្ថយភាពក្រីក្រឲ្យមានប្រសិទ្ធិភាព។

ការសិក្សាមានគោលបំណងចំនួនពីរគឺ ប្រៀបធៀបពីប្រសិទ្ធផលនៃការអនុវត្តមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ រវាងឃុំមង់រៀវ និងឃុំជីគរ ក្នុងការអនុវត្តប្រតិភូកម្មមុខងារជួលជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ និងវិភាគពីតម្រូវការរបស់មន្ត្រីថ្នាក់ក្រោមជាតិដើម្បីបំពេញចន្លោះខ្វះខាតក្នុងដំណើរការអនុវត្តមួយនេះ។

ដើម្បីឆ្លើយតបនូវគោលបំណងខាងលើ ការសិក្សានេះប្រើប្រាស់នូវ វិធីសាស្ត្របែបគុណវិស័យដោយប្រើប្រាស់ទិន្នន័យបឋម ដែលបានពីការសម្ភាសជនបង្គោលតាមរយៈបញ្ជីសំណួរគោល និងទិន្នន័យទ្វាប់បន្សំ ហើយវិភាគតាមឧបករណ៍វិភាគមាតិកា និងឧបករណ៍វិភាគ (SWOT)។

តាមលទ្ធផលនៃការសិក្សាបានបង្ហាញថា ការធ្វើប្រតិភូកម្មមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ ពិតជាបានរួមចំនែកក្នុងការពន្លឿននូវការជួសជុលនិងដោះស្រាយបញ្ហាផ្គត់ផ្គង់ទឹកស្អាតនៅជនបទពិតប្រាកដមែន។ បើយោងតាមកាសិក្សាក្រុមបានលើកនូវសូចនាករចំនួនពីរ គឺមុខងារជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ និងដំណើរការស្នើសុំការជួសជុលប្រព័ន្ធផ្គង់ផ្គង់ទឹកស្អាតជនបទ ដើម្បីធ្វើការប្រៀបធៀបពីភាពខុសគ្នាមុន និងក្រោយការផ្ទេរមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ។ ហើយលទ្ធផលនៃការប្រៀបធៀបនេះ បានបង្ហាញថារដ្ឋបាលថ្នាក់ក្រោមជាតិពិតជាទទួលបានមុខងារបន្ថែមលើមុខងារដែលមានស្រាប់ និងដំណើរការជួសជុលក្រោយការផ្ទេរមុខងារមានសកម្មភាពជួសជុលលឿនជាងមុនរហូតទៅដល់៣ខែ បើធៀបទៅនិងមុនពេលមិនទាន់ផ្ទេរមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គង់ផ្គង់ទឹកស្អាតជនបទ។ ជាក់ស្តែងរដ្ឋបាលថ្នាក់ក្រោមសម្រេចបានការជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ចំនួន៥ នៅក្នុងឃុំមង់រៀវ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។ បើតាមរយៈ

ការវិភាគធនធាន និងស្ថានភាពទូទៅនៃរដ្ឋបាលថ្នាក់ក្រោមជាតិយើងឃើញថា តម្រូវការរបស់មន្ត្រីថ្នាក់ក្រោមជាតិ មានដូចជាតម្រូវការមន្ត្រីដែលមានជំនាញក្នុងការអនុវត្តមុខងារ និងតម្រូវការគ្រឿងបន្លាស់ ដែលមានគុណភាពល្អដើម្បីធានាការប្រើប្រាស់ប្រកបដោយនិរន្តរភាព។ បន្ថែមពីលើនេះទៅទៀត ក្រុមបានធ្វើការវិភាគទៅលើចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងភាពប្រឈម ដើម្បីបង្ហាញពីឥទ្ធិពលនៃប្រព័ន្ធគោលនយោបាយថ្មី។

# តារាងមាតិកា

**ជំពូក** **ចំណងជើង** **ទំព័រ**


គម្របក្នុង........i
សេចក្តីថ្លៃការណ៍ទទួលយករបាយការណ៍ស្រាវជ្រាវ........ii
សេចក្តីថ្លែងអំណរគុណ........iii
សេចក្តីអំណះអំណាង........iv
មូលន័យសង្ខេប........v
តារាងមាតិកា........vii
បញ្ជីតារាង........ix
បញ្ជីដ្យាក្រាម........x
បញ្ជីរូបភាព........xi
បញ្ជីអក្សរកាត់........xii

**១ សេចក្តីផ្តើម**

១.១ ស្ថានភាពទូទៅ........1
១.២ ការពិពណ៌នាពីបញ្ហា........2
១.៣ គោលបំណងនៃការសិក្សាស្រាវជ្រាវ........3
១.៤ សំនួរស្រាវជ្រាវ........4
១.៥ វិសាលភាព និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ........4

**២ សំយោគបណ្ណាល័យសាស្ត្រ**

២.១ លក្ខណៈទូទៅនៃការប្រើប្រាស់ទឹករបស់ប្រជាជនកម្ពុជានៅទីជនបទ........5
២.២ ច្បាប់ និងបទបញ្ញត្តិផ្សេងៗនៃវិស័យផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា........6
២.២.១ ផែនការយុទ្ធសាស្ត្រជាតិ ស្តីពី វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ២០១៤-២០២៥........6
២.២.២ ផែនការសកម្មភាពជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យនៅជនបទ ឆ្នាំ ២០១៤-២០១៨........7
២.៣ លក្ខណៈទូទៅនៃអភិបាលកិច្ចថ្នាក់ក្រោមជាតិ........7
២.៣.១ ការទទួលខុសត្រូវ និងសារៈសំខាន់នៃប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការនៃអភិបាលកិច្ចថ្នាក់ក្រោមជាតិ........8
២.៣.២ គណនេយ្យភាពនៃវិម្សការ និងវិសហមជ្ឈការ........9
២.៤ ការធ្វើប្រតិភូកម្មមុខងារមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ........11

២.៥ តួនាទីរបស់ស្ថាប័នពាក់ព័ន្ធ .................................................... 13

៣ **វិធីសាស្ត្រស្រាវជ្រាវ**

៣.១ សេចក្តីផ្តើម.................................................... 23

៣.២ តំបន់សិក្សា .................................................... 25

៣.២.១ មូលហេតុនៃការជ្រើសរើសតំបន់សិក្សា.................................................... 25

៣.២.២ ផែនទីតំបន់សិក្សា.................................................... 26

៣.៣ ទំហំ និងវិធីសាស្ត្រក្នុងការជ្រើសរើសសំណាក.................................................... 26

៣.៤ វិធីសាស្ត្រប្រមូលព័ត៌មាន .................................................... 27

៣.៤.១ ប្រភេទទិន្នន័យបឋម .................................................... 27

៣.៤.២ ប្រភេទទិន្នន័យបន្ទាប់បន្សំ .................................................... 28

៣.៥ ការរៀបចំ និងវិភាគទិន្នន័យ.................................................... 28

៤ **លទ្ធផល និងការពិភាក្សា**

៤.១ សេចក្តីផ្តើម .................................................... 30

៤.២ ស្ថានភាពទូទៅនៃស្រុកត្បូងឃ្មុំ.................................................... 30

៤.៣ តួនាទី និងភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ នៃការគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ .................................................... 33

៤.៣.១ តួនាទី និងមុខងារមុន និងក្រោយការផ្ទេរមុខងាររបស់រដ្ឋបាលស្រុកត្បូងឃ្មុំ .................................................... 34

៤.៣.២ តួនាទី និងមុខងារមុន និងក្រោយការផ្ទេរមុខងាររបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ.................................................... 40

៤.៤ ដំណើរការជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទរបស់រដ្ឋបាលស្រុកត្បូងឃ្មុំ.................................................... 46

៤.៤.១ ប្រៀបធៀបពីរយៈពេលនៃដំណើរការស្នើសុំជួសជុលនៃប្រព័ន្ធផ្គត់ផ្គង់ទឹក .................................................... 46

៤.៤.២ ភាពខ្លាំងនៃដំណើរការជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹក.................................................... 51

៤.៤.៣ ភាពខ្សោយនៃដំណើរការជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹក.................................................... 52

៤.៤.៤ ឱកាសនៃដំណើរការជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹក.................................................... 53

៤.៤.៥ ភាពប្រឈមលើដំណើរការអនុវត្តការផ្ទេរមុខងារ .................................................... 54

៤.៥ ស្ថានភាពឃុំដែលបានអនុវត្តនិងឃុំដែលមិនទាន់បានអនុវត្ត .................................................... 56

៤.៥.១ ស្ថានភាពឃុំដែលបានអនុវត្តផ្ទេរមុខងារ (ឃុំមង់រៀវ) .................................................... 56

៤.៥.២ ស្ថានភាពឃុំដែលមិនទាន់ទទួលបានការអនុវត្តផ្ទេរមុខងារ

(ឃុំជីគរ) .......................................................................... 58
៤.៦ សមត្ថភាពស្ថាប័នពាក់ព័ន្ធដែលមានស្រាប់ និងតម្រូវការ ......................... 61
៤.៦.១ សមត្ថភាពនិងតម្រូវការបន្ថែមសម្រាប់ពន្លឿនសំណើរការអនុវត្ត របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ ........................................ 61
៤.៦.២ សមត្ថភាពនិងតម្រូវការបន្ថែមសម្រាប់ពន្លឿនសំណើរការអនុវត្ត របស់រដ្ឋបាលស្រុកខេត្តត្បូងឃ្មុំ.............................................. 64
៤.៦.៣ តម្រូវការបន្ថែមសម្រាប់ពន្លឿនដំណើរការអនុវរបស់ក្រុម ប្រឹក្សាឃុំ មង់រៀវ និងឃុំ ជីគរ ............................................. 65
៤.៦.៤ តម្រូវការបន្ថែមសម្រាប់ពន្លឿនដំណើរការអនុវត្តរបស់ក្រុមអ្នក ប្រើប្រាស់ទឹក .................................................................... 65

## ៥ សេចក្តីសន្និដ្ឋាន និងអនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន........................................................................................67
៥.២ អនុសាសន៍................................................................................................68

**ឯកសារយោង**...........................................................................................................70

ឧបសម្ព័ន្ធ ក បញ្ជីសំណួរសម្រាប់ការសម្ភាសន៍មន្ត្រីមន្ទីរអភិវឌ្ឍន៍ជនបទស្រុក ត្បូងឃ្មុំ..........................................................................................................74
ឧបសម្ព័ន្ធ ខ បញ្ជីសំណួរសម្រាប់ការសម្ភាសន៍មន្ត្រីរដ្ឋបាលស្រុក ឃុំ/ភូមិ...........75
ឧបសម្ព័ន្ធ គ បញ្ជីសំណួរសម្រាប់ការសម្ភាសន៍ប្រជាជនបទស្រុកត្បូងឃ្មុំ............77
ឧបសម្ព័ន្ធ ឃ ទម្រង់ស្នើសុំការជួសជុលអណ្តូងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ.....78
ឧបសម្ព័ន្ធ ង ទម្រុងប៉ាន់ស្មានតម្លៃសម្រាប់ជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹក..................79
ឩបសម្ព័ន្ធ ច គំរូទម្រង់សម្រាប់កត់ត្រាលទ្ធផលនិងគុណភាពទឹករបស់SNV.........80
ឩបសម្ព័ន្ធ ឆ គំរូសារពើភ័ណ្ឌអណ្តូងរបស់SNV...................................................81

## បញ្ជីតារាង

| ជំពូក | ចំណងជើង | ទំព័រ |
|---|---|---|

២.១ ភាគរយប្រភពទឹកកែលម្អ និងមិនកែលម្អ នៅរដូវប្រាំងនិងវស្សា ........................... 6
២.២ តារាងសូចនាករការអនុវត្តផែនការយុទ្ធសាស្ត្រលើវិស័យផ្គត់ផ្គង់ទឹក.......................7
២.៣ គណនេយ្យភាពនៅក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ............................. 10
២.៤ តួនាទី និងការទទួលខុសត្រូវ លើវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យស្ថាប័នរដ្ឋ . 13
២.៥ តួនាទី និងការផ្ទេរមុខងារ លើការគ្រប់គ្រង ........................................................ 15
២.៦ មុខងារមុននិងក្រោយការផ្ទេរមុខងាររបស់ស្ថាប័នទាក់ទងធ្វើប្រតិភូកម្មមុខងារជួស

ជុលនិងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ ........ 17
២.៧ តួនាទីនិងទំនួលខុសត្រូវនៃសមាជិកក្រុមស្នូលនៃក្រុមអ្នកប្រើប្រាស់ទឹក និង អនាម័យ ........ 20
៤.១ សង្ខេបទិន្នន័យប្រភពទឹកក្នុងស្រុកត្បូងឃ្មុំ........ 31
៤.២ ប្រៀបធៀបពីមុខងារចាស់ និងមុខងារបន្ថែមថ្មីរបស់រដ្ឋបាលស្រុកត្បូងឃ្មុំ........ 36
៤.៣ សមិទ្ធផលដែលរដ្ឋបាលស្រុកសម្រេចបាន........ 39
៤.៤ ប្រៀបធៀបមុខងារមុន និងក្រោយការធ្វើប្រតិភូកម្មរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ ........ 43
៤.៥ ភាពខុសគ្នារវាងការអនុវត្តលើមុខងារចាស់ និងមុខងារដែលបានបន្ថែមថ្មីរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ........ 45
៤.៦ បង្ហាញពីសមាសភាពរបស់គណៈកម្មាធិការទទួលបន្ទុកជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ ........ 45
៤.៧ ប្រភេទនៃលទ្ធកម្ម ........ 51
៤.៨ តារាងវិភាគ SWOT នៃការធ្វើប្រតិភូកម្មមុខងារជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ........ 55
៤.៩ ចំនួនអណ្តូងឃុំមង់រៀវឆ្នាំ២០១៦........ 56
៤.១០ ភាពខុសគ្នារវាងមុខងារចាស់ និងមុខងារថ្មីរបស់ក្រុមប្រឹក្សាឃុំមង់រៀវ........ 58
៤.១១ ចំនួនអណ្តូងក្នុងឃុំជីគរឆ្នាំ២០១៦ ........ 58
៤.១២ ភាពខុសគ្នារវាងឃុំ ដែលបានទទួលការអនុវត្តមុខងារនិងឃុំដែលពុំទាន់បានអនុវត្តមុខងារ ........ 60
៤.១៣ តារាងបង្ហាញពីតួនាទី និងកម្រិតវប្បធម៌របស់មន្ត្រីការិយាល័យផ្គត់ផ្គង់ទឹកស្អាត .. 62

## បញ្ជីដ្យាក្រាម

**ដ្យាក្រាម ចំណងជើង** **ទំព័រ**

២.១ ដំណើរការក្នុងការផ្ទេរមុខងារពីរដ្ឋបាលថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិ........12
៣.១ សង្ខេបវិធីសាស្ត្រសិក្សាស្រាវជ្រាវ........24
៣.២ ការវិភាគតាមឧបករណ៍វិភាគមាតិកា........29
៤.១ រចនាសម្ព័ន្ធការងាររបស់រដ្ឋបាលស្រុកត្បូងឃ្មុំ ........ 32
៤.២ រចនាសម្ព័ន្ធក្រុមការងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទនៃរដ្ឋបាលស្រុកត្បូងឃ្មុំ ........ 37
៤.៣ សមាសភាពនៃក្រុមការងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ របស់រដ្ឋបាលស្រុកត្បូងឃ្មុំ ........ 38
៤.៤ ដំណើរការជួសជុលអណ្តូងសហគមន៍របស់មន្ទីរអភិវឌ្ឍន៍ជនបទ ........ 49

| | | |
|---|---|---|
| ៤.៥ | ដំណើរការជួសជុលអណ្តូងសហគមន៍របស់រដ្ឋបាលស្រុក | 50 |
| ៤.៦ | រចនាសម្ព័ន្ធការងាររបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ | 61 |
| ៤.៧ | រចនាសម្ព័ន្ធការងាររបស់ការិយាល័យផ្គត់ផ្គង់ទឹកស្អាតជនបទខេត្តត្បូងឃ្មុំ | 62 |
| ៤.៨ | រចនាសម្ព័ន្ធការងាររបស់រដ្ឋបាលស្រុកត្បូងឃ្មុំ | 64 |

## បញ្ជីរូបភាព

| រូបភាព | ចំណងជើង | ទំព័រ |
|---|---|---|
| ៣.១ | ផែនទីទីតាំងតំបន់សិក្សា | 27 |

# បញ្ជីអក្សរកាត់

| អក្សរកាត់ | ភាសាអង់គ្លេស | ភាសាខ្មែរ |
|---|---|---|
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| CC | Commune Council | ក្រុមប្រឹក្សាឃុំសង្កាត់ |
| CCWC | Commune Committee for Women and Children | គណៈកម្មការឃុំ សង្កាត់ទទួលបន្ទុកការ ងារស្ត្រី និងកុមារ |
| CDB | Commune Database | ទិន្នន័យឃុំសង្កាត់ |
| CDHS | Cambodia Demographic and Health Survey | អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា |
| CMDG | Cambodian Millennium Development Goal | គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា |
| CSES | Cambodia Socio-Economic Survey | ការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា |
| D & D | Decentralisation and Deconcentration | វិមជ្ឈការ និងវិសហមជ្ឈការ |
| DRWS | Department of Rural Water Supply (of MRD) | នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ (ក្នុងក្រសួងអភិវឌ្ឍន៍ជនបទ) |
| JICA | The Japan International Cooperation Agency | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន |
| JMP | Join Monitoring Program | កម្មវិធីត្រួតពិនិត្យតាមដានវឌ្ឍនភាពទឹក និងអនាម័យ |
| MDG | Millennium Development Goal | គោលដៅអភិវឌ្ឍន៍សហសវត្សរ៍ |
| MOE | Ministry of Environmental | ក្រសួងបរិស្ថាន |
| MOH | Ministry of Health | ក្រសួងសុខាភិបាល |
| MOWRAM | Ministry of Water Resources and Meteorology | ក្រសួងធនធានទឹក និងឧតុនិយម |
| MRD | Ministry of Rural Development | ក្រសួងអភិវឌ្ឍន៍ជនបទ |
| NAP | National Action Plan (for RWSSH 2014-2018) | ផែនការសកម្មភាពជាតិ (សម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យជនបទឆ្នាំ ២០១៤-២០២៥) |
| NCDD | National Committee for Sub-National Democratic Development | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅ |

| | | |
|---|---|---|
| | | ថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) |
| NGO | Non-Governmental Organization | អង្គការមិនមែនរដ្ឋាភិបាល |
| NSP | National Strategic Plan (for RWSSH 2014-2025) | ផែនការយុទ្ធសាស្ត្រជាតិ (សម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យជនបទឆ្នាំ ២០១៤-២០២៥) |
| O&M | Operation and Maintenance | ប្រតិបត្តិការ និងការថែទាំ |
| PAP | Provincial Action Plan | ផែនការសកម្មភាពខេត្ត |
| RWS | Rural Water Supply | ការផ្គត់ផ្គង់ទឹកស្អាតជនបទ |
| SNV | Netherlands Development Organization | អង្គការអភិវឌ្ឍន៍ហូឡង់ដ៍ |
| UNICEF | United Nations Children's Fund | មូលនិធិអង្គការសហប្រជាជាតិសម្រាប់កុមារ |
| WB | The World Bank | ធនាគារពិភពលោក |
| WHO | World Health Organization | អង្គការសុខភាពពិភពលោក |
| WSUG | Water and Sanitation User´s Group | ក្រុមប្រើប្រាស់ទឹក និងអនាម័យ |

# ជំពូក ១
# សេចក្តីផ្តើម

## ១.១ ស្ថានភាពទូទៅ

ប្រទេសកម្ពុជាមានប្រជាជនប្រមាណជិតពាក់កណ្តាលនៃចំនួនប្រជាជនសរុប គឺពុំទាន់មានលទ្ធភាពទទួលបានទឹក ដែលមានសុវត្ថិភាព និងអនាម័យជាមូលដ្ឋានសម្រាប់ការប្រើប្រាស់នៅឡើយ។ ជាក់ស្តែង ប្រជាជនជនបទប្រមាណ ៦.៣លាននាក់នៃប្រជាជនសរុប គឺពុំទាន់បានទទួលទឹកស្អាតប្រើប្រាស់នោះទេ (UNICEF, 2014)។ បើតាមទិន្នន័យអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ឆ្នាំ២០១៤ បង្ហាញថា ការទទួលបានទឹកមានសុវត្ថិភាពនៅតំបន់ជនបទ សម្រេចបានវឌ្ឍនភាពតិចតួចនៅ ឆ្នាំ២០១៣ គឺទទួលបាន ៤៦,៦%ធៀបនឹង ការផ្គត់ផ្គង់ទឹកឆ្នាំ២០១៤ អត្រាទទួលបានគឺ ៤៧,០%។ មកដល់បច្ចុប្បន្នប្រជាជនជនបទត្រឹមតែ ៥៤,២% ប៉ុណ្ណោះដែលទទួលបានការផ្គត់ផ្គង់ទឹកពីប្រភពទឹកកែលម្អ (ក្រសួងអភិវឌ្ឍន៍ជនបទ, ២០១៦ក)។

ទន្ទឹមនឹងអត្រាទទួលបានទឹកស្អាតប្រើប្រាស់ ជាមូលដ្ឋាននៅមានកម្រិតទាបរាជរដ្ឋាភិបាលកម្ពុជាក៏មានយុទ្ធសាស្ត្រ និងផែនការយុទ្ធសាស្ត្រជាតិដើម្បីឆ្លើយតបទៅនិងតម្រូវការផ្ទាល់របស់ប្រជាជន រួមទាំងកាត់បន្ថយបញ្ហាកង្វះទឹកស្អាតប្រើប្រាស់នៅតំបន់ជនបទ និងស្របតាមគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ (MDGs)។ ក្នុងនោះ ក្រសួងអភិវឌ្ឍន៍ជនបទ, (២០១៤ក) បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រជាតិមួយស្តីពី ការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ ឆ្នាំ២០១៤-២០២៥។ ជាក់ស្តែង គោលដៅនៃផែនការយុទ្ធសាស្ត្រនេះ គឺធ្វើយ៉ាងណាឱ្យការផ្គត់ផ្គង់ទឹកស្អាតនៅជនបទទទួលបាន ៥០%នៅក្នុងឆ្នាំ២០១៥ និងឱ្យបាន១០០% នៅក្នុងឆ្នាំ២០២៥ ដែលផែនការយុទ្ធសាស្ត្រនេះត្រូវបានចាត់តាំង និងទទួលខុសត្រូវដោយ ក្រសួងអភិវឌ្ឍន៍ជនបទ (ក្រសួងអភិវឌ្ឍន៍ជនបទ,២០១៤ក)។ ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រជាតិទទួលបានជោគជ័យក្រសួងអភិវឌ្ឍន៍ជនបទ បានរៀបចំនូវផែនការសកម្មភាពជាតិមួយទៀតស្តីពី ការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទដំណាក់កាលទី១ ឆ្នាំ២០១៤-២០១៨។ ក្នុងផែនការសកម្មភាពជាតិនេះ ក្រសួងអភិវឌ្ឍន៍ជនបទបានប្តេជ្ញានឹងសម្រេចឱ្យបានចំនួនប្រជាជនទទួលបានការផ្គត់ផ្គង់ទឹកស្អាត៦០% នៅឆ្នាំ២០១៨។ ថ្មីៗនេះ ក្រសួងអភិវឌ្ឍន៍ជនបទ, (២០១៦ខ) បានអះអាងថាអត្រាគ្របដណ្តប់ការផ្គត់ផ្គង់ទឹកស្អាតជនបទគឺពិតជាសម្រេចបានគោលដៅទីមួយហើយគឺសម្រេចបាន ៥៤,២% លើសគោលដៅដែលបានរំពឹងទុក ៤.២%។ ទោះបីជាការអនុវត្តនូវ ផែនការយុទ្ធសាស្ត្រសម្រេចបាននូវលទ្ធផលជាវិជ្ជមាននៅឆ្នាំ២០១៥នេះក្តី តែយ៉ាងណាមិញយើងសង្កេតឃើញថាការអនុវត្តនេះនៅមានភាពយឺតយ៉ាវ បើធៀបទៅនឹងកំណើនប្រជាជន និងតម្រូវការប្រើប្រាស់ទឹករបស់ប្រជាជន។ យោងតាមរបាយការណ៍បូកសរុបសកម្មភាពការងារប្រចាំឆ្នាំ២០១៥ដដែលរបស់ក្រសួងអភិវឌ្ឍន៍ជនបទ, (២០១៦ក) ភាពយឺតយ៉ាវក្នុងការអនុវត្តនេះគឺកើតឡើងដោយសារ

បញ្ហាប្រឈមចំនួនបីធំៗគឺ ទី១ បញ្ហាធនធានមនុស្សនិងចំណេះដឹង ទី២ បញ្ហាធនធានហិរញ្ញវត្ថុ និងទី៣ បញ្ហាបរិស្ថាន។ ក្រៅពីបញ្ហាធំៗទាំងបីខាងលើ ក៏នៅមានបញ្ហាមួយចំនួនទៀតដូចជា ការទទួលបានប្រព័ន្ធទិន្នន័យអណ្តូងគ្រប់ប្រភេទនៅមានកម្រិត ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីការប្រើប្រាស់ទឹកស្អាតនៅមានកម្រិត និងត្រូវការរយៈពេលវែងក្នុងការផ្លាស់ប្តូរទម្លាប់នៃការប្រើប្រាស់ទឹករបស់ពួកគាត់។

ផ្សាភ្ជាប់ជាមួយការសម្រេចនូវផែនការសកម្មភាពជាតិ ២០១៤-២០១៨ ក៏ដូចជាដោះស្រាយនូវបញ្ហាប្រឈមខាងលើ នៅក្នុងដំណើរអនុវត្តរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រថ្មីតាមរយៈការធ្វើកំណែទម្រង់គោលនយោបាយរបស់ខ្លួន។ កំណែទម្រង់អភិបាលកិច្ចកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការមានតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន សំដៅលើការលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋ និងចូលរួមចំណែកកាត់បន្ថយភាពក្រីក្រឱ្យមានប្រសិទ្ធិភាព (គ.ជ.អ.ប, ២០១៤ក)។ បើយោងរបាយការណ៍របស់ UNICEF បង្ហាញឱ្យឃើញថាតាម រយៈកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនេះ រដ្ឋាភិបាលថ្នាក់ក្រោមជាតិមានឥទ្ធិពលក្នុងដំណើរការ និងមានការកើនឡើងនៃសិទ្ធ និងគណនេយ្យ នៅកម្រិតខេត្ត ស្រុក និងឃុំ/សង្កាត់ ដើម្បីដោះស្រាយបញ្ហាប្រឈមនៅថ្នាក់មូលដ្ឋានដោយមានការថែទាំល្អក្នុងសហគមន៍របស់គាត់។ បន្ថែមលើដំណើរការប្រកបដោយប្រសិទ្ធិភាពនៃវិមជ្ឈការ ដែលធ្វើឱ្យអ្នកផ្តល់សេវាកម្មបានខិតទៅជិតអ្នកប្រើប្រាស់ជាងមុននោះ គឺការបង្កើតនូវតម្លាភាពផលិតភាព និងគុណភាពនៃសេវាកម្មដែលបានផ្តល់ (គ.ជ.អ.ប, ២០១០ក)។ យើងឃើញថាគោលនយោបាយប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ គឺមានប្រសិទ្ធិភាពក្នុងការដោះស្រាយចំពោះបញ្ហាដែលស្ថិតនៅក្នុង ដែនសមត្ថកិច្ចជាក់លាក់របស់រដ្ឋបាលណាមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិដូចជា ការគ្រប់គ្រងការរីកចម្រើនលូតលាស់នៃទីប្រជុំជន និងការផ្គត់ផ្គង់ទឹកស្អាត (គ.ជ.អ.ប,២០១០ខ)។

## ១.២ ការពិពណ៌នាពីបញ្ហា

បន្ទាប់ពីឆ្នាំ១៩៩៣ រាជរដ្ឋាភិបាលបានធ្វើកំណែទម្រង់រដ្ឋបាលក្រោមជាតិ ដោយរិះរកប្រព័ន្ធអភិបាលកិច្ចមួយដែលត្រឹមត្រូវតាមបែបប្រជាធិបតេយ្យ។ ក្នុងនោះរាជរដ្ឋាភិបាលខ្លួនឯងផ្ទាល់ បានមើលឃើញពីភាពទន់ខ្សោយនៃប្រព័ន្ធអភិបាលកិច្ចថ្នាក់ក្រោមជាតិ ទើបបង្កើតកម្មវិធីនយោបាយជាច្រើនបន្ថែមទៀតដែលពាក់ព័ន្ធនឹងអភិបាលកិច្ច។ គួបផ្សំនឹងសមាសធាតុថ្មីៗនៃអភិបាលកិច្ចដែលត្រូវបានរាជរដ្ឋាភិបាលបង្កើតច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បន្ទាប់មកទៀតគឺច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (គ.ជ.អ.ប, ២០០៨)។ រដ្ឋបាលថ្នាក់ក្រោមជាតិ មានតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់កិច្ចអភិវឌ្ឍន៍មូលដ្ឋាន ការផ្តល់សេវាសង្គម សេវាទីប្រជុំជននានា និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ដែលចូលរួមចំណែកធ្វើឱ្យជីវភាពប្រជាពលរដ្ឋនៅមូលដ្ឋានកាន់តែល្អប្រសើរឡើង (គ.ជ.អ.ប, ២០១៤ខ)។

ក្រោយពីច្បាប់ទាំងនេះបានប្រកាសឱ្យប្រើជាបន្តបន្ទាប់ដូចជា ប្រកាសស្តីពីការធ្វើប្រតិភូកម្មមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទជូនរដ្ឋបាលស្រុកឈូក ស្រុកជុំគិរី ស្រុកបន្ទាយមាស និងស្រុកកំពង់ត្រាច នៃខេត្តកំពត និងស្រុកមេមត់ ស្រុកត្បូងឃ្មុំ និងស្រុកក្រូចឆ្មារ នៃខេត្តត្បូងឃ្មុំ ដើម្បីអនុម័តឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ មានសិទ្ធិអំណាច ការទទួលខុសត្រូវក៏ដូចជា គណនេយ្យភាពក្នុងការគ្រប់គ្រង ចាត់ចែង លើប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅជនបទ ដោយរួមមាន ទាំងការជួសជុល ការធ្វើតេស្តគុណភាព ឬការធ្វើបញ្ជីសារពើភ័ណ្ឌនានានៃរាល់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតទាំងអស់ ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ យើងឃើញមានសញ្ញាណនៃអភិបាលថ្មីមួយបានកើតឡើង តាមរយៈការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យជាគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។ ក្នុងនោះនៅពេលនៅពេលដែលធ្វើការផ្លាស់ប្តូរតាមប្រព័ន្ធអភិបាលកិច្ចបែបនេះ គឺមានផលវិជ្ជមាន និងផលអវិជ្ជមានក្នុងការអនុវត្តអភិបាលកិច្ច ទោះបីជារាជរដ្ឋាភិបាលបានបង្កើតរចនាសម្ព័ន្ធជាតិក្នុងការគាំទ្រ និងកំណែទម្រង់អភិបាលកិច្ចក៏ដោយ ពីព្រោះការយល់ដឹង និងកម្រិតវប្បធម៌របស់មន្ត្រីរាជការនៅមូលដ្ឋាននៅមានកម្រិតនៅឡើយ។ ហេតុនេះ ការសិក្សានេះនិងលើកបង្ហាញពី ការបែងចែកតួនាទីការគ្រប់គ្រងឱ្យបានច្បាស់លាស់ រវាងឃុំដែលបានអនុវត្តមុខងារជួសជុល និងឃុំដែលមិនទាន់អនុវត្ត និងវិភាគពីតម្រូវការរបស់ថ្នាក់ក្រោមជាតិទាក់ទងនិងការអនុវត្តមុខងារថ្មី។

## ១.៣ គោលបំណងនៃការសិក្សាស្រាវជ្រាវ

ការសិក្សាមានខ្លឹមសារផ្តោតជាសំខាន់លើ ការសិក្សាពីសក្តានុពលនៃការអនុវត្តប្រតិភូកម្មមុខងារ ជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ នៅស្រុកត្បូងឃ្មុំ។ ចំពោះគោលបំណងជាក់លាក់នៃសំណើរការសិក្សានេះគឺៈ

- ប្រៀបធៀបពីប្រសិទ្ធផលនៃការអនុវត្តមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទរវាងដែលបានអនុវត្តន៍ឃុំមង់រៀវ និងឃុំដែលមិនទាន់បានអនុវត្ត ឃុំជីគរ។
- វិភាគពីតម្រូវការរបស់មន្ត្រីថ្នាក់ក្រោមជាតិ ដើម្បីបំពេញចន្លោះខ្វះខាតក្នុងដំណើរការអនុវត្តប្រតិភូកម្មមុខងារជួលជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ។

## ១.៤ សំណួរស្រាវជ្រាវ

- តើរដ្ឋបាលថ្នាក់ក្រោមជាតិទទួលបានមុខងារបន្ថែមអ្វីខ្លះ ដែលពាក់ព័ន្ធនឹងការងារផ្គត់ផ្គង់ទឹក បន្ទាប់ពីអនុវត្តប្រតិភូកម្មមុខងារ ជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ?
- តើដំណើរការស្នើសុំជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត រវាងឃុំមង់រៀវ និងឃុំជីគរ មានភាពខុសគ្នាដូចម្តេច?
- តើរដ្ឋបាលថ្នាក់ក្រោមជាតិសម្រេចបាន ការជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតស្រុកត្បូងឃ្មុំចំនួនប៉ុន្មានបន្ទាប់ពីការធ្វើប្រតិភូតកម្មមុខងារជួសជុលនិងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត?

- តើអ្វីខ្លះ ជាចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងភាពប្រឈមរបស់ប្រព័ន្ធនៃការផ្ទេរមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត?
- តើរដ្ឋបាលថ្នាក់ក្រោមជាតិមានតម្រូវការបន្ថែមអ្វីខ្លះក្នុងការជួយពន្លឿនសេវាផ្គត់ផ្គង់ទឹកស្អាតជនបទ?

## ១.៥ វិសាលភាព និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាខាងលើមានដែនកំណត់ដូចខាងក្រោមៈ

- ការសិក្សាបានកំណត់យក ឃុំមង់រៀវ និងឃុំជីគរ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ
- ការសិក្សាបានកំណត់យក សូចនាករចំនួនពីរ គឺការអនុវត្តប្រតិភូកម្មមុខងារ និងរយៈពេលនៃដំណើរការជួសជុល សម្រាប់ធ្វើការវាស់វែងដើម្បីប្រៀបធៀបពីដំណើរការអនុវត្តមុខងារ មុននិងក្រោយ រវាងឃុំចំនួនពីរ ក្នុងការអនុវត្តប្រតិភូកម្មមុខងារជួលជុលនិងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ ។
- ការសិក្សាមានរយៈពេល៤ខែ ចាប់ពីខែកុម្ភៈ រហូតដល់ចុងខែឧសភា ២០១៦។

# ជំពូក ២
# សំយោគបណ្ណាល័យសាស្ត្រ

## ២.១ លក្ខណៈទូទៅនៃការប្រើប្រាស់ទឹករបស់ប្រជាជនកម្ពុជានៅទីជនបទ

ប្រភពទឹកចម្បង ដែលត្រូវបានប្រើប្រាស់របស់ប្រជាជននៅតាមជនបទត្រូវបានគេបែងចែកទៅតាមស្ថាប័នផ្សេងៗគ្នា។ បើយោងទៅតាមរបាយការណ៍ ប្រជាសាស្ត្រនិងការស្ទង់មតិសុខភាព (DHS, 2015) គេធ្វើការបែងចែកប្រភពទឹកចម្បងៗជាពីរ គឺប្រភពទឹកកែលម្អ និងទឹកមិនកែលម្អ។ តាមរបាយការណ៍កម្មវិធីត្រួតពិនិត្យតានដានវឌ្ឍនភាពទឹក និងអនាម័យ, (២០១៦) បានឱ្យនិយមន័យទឹកកែលម្អថាគឺជាប្រភពទឹក ឬប្រភពនៃការដឹកជញ្ជូនដែលត្រូវបានសាងសង់ ឬរៀបចំឡើងដើម្បីការពារប្រភពទឹក ពីការជ្រាបចូលនៃបាក់តេរីខាងក្រៅពិសេសគឺពពួកមេរោគ (WHO/UNICEF, 2016)។ ចំនែកឯប្រភពទឹកមិនកែលម្អវិញ សំដៅដល់អណ្តូងជីកដែលមិនមានការការពារ ទឹកផុសដែលមានការការពារ ទឹកដឹកលក់តាមរថយន្តឬរទេះ និងទឹកលើផ្ទៃដី (ទន្លេ ទំនប់វារីអគ្គិសនី បឹង ស្រះទឹក ស្ទឹង ប្រព័ន្ធធារាសាស្ត្រ) ទឹកជប (UNICEF, 2009)។

បើតាមប្រភពទិន្នន័យដដែលនេះបានបង្ហាញពី អត្រាគ្របដណ្តប់ទឹកផឹករបស់ប្រជាជនជនបទទៅតាមប្រភពទឹកទាំង២នេះគិតជាភាគរយ និងមានលក្ខណៈលម្អិតទៅតាមរដូវវស្សា និងរដូវប្រាំង។ ក្នុងនោះផងដែរ ភាគរយនៃការប្រើប្រាស់ប្រភពទឹកកែលម្អរបស់ប្រជាជនគឺមានចំនួន៦០.១% និងប្រភពទឹកមិនកែលម្អមានចំនួន៣៩.៩% នៅក្នុងរដូវប្រាំង។ ចំនែកឯក្នុងរដូវវស្សា ភាគរយនៃការប្រើប្រាស់ប្រភពទឹកកែលម្អរបស់ប្រជាជនគឺមានចំនួន៨១.៥% ប្រភពទឹកមិនកែលម្អមានចំនួន១៨.៥% (DHS, 2015)។ ទិន្នន័យខាងលើបានបង្ហាញឱ្យឃើញថាការប្រើប្រាស់ទឹករបស់ប្រជាជនក្នុងប្រភពកែលម្អ គឺមានចំនួនកើនឡើងបើប្រៀបធៀបទៅនឹងរដូវប្រាំងក្នុងឆ្នាំតែមួយ។

តារាង ២.១. ភាគរយប្រភពទឹកកែលម្អ និងមិនកែលម្អ នៅរដូវប្រាំងនិងវស្សា

| ប្រភពទឹកនៅរដូវប្រាំង/វស្សា (%) | | រដូវប្រាំង | រដូវវស្សា |
|---|---|---|---|
| ប្រភពទឹកកែលម្អ | បណ្តាញទុយោដែលតភ្ជាប់តាមគេហដ្ឋាន | ៥.៧ | ៤.៧ |
| | អាងស្តុកទឹកសាធារណៈ | ០.៥ | ០.៥ |
| | អណ្តូងស្នប់ | ៣១.១ | ២៥.៤ |
| | អណ្តូងលូដែលមានការការពារ | ៤.០ | ២.៨ |
| | ទឹកផុសដែលមានការការពារ | ០.៣ | ០.២ |
| | ការប្រមូលទឹកភ្លៀង | ១០.១ | ៤០.៨ |
| | ទឹកផុង | ៨.៤ | ៧.០ |
| ប្រភពទឹកមិនកែលម្អ | អណ្តូងលូដែលគ្មានការការពារ | ១៣.៤ | ៩.៣ |
| | ទឹកផុសដែលគ្មានការការពារ | ១.៣ | ០.៧ |
| | ទឹកដឹកលក់ | ៣.៩ | ០.៩ |
| | ទឹកលើផ្ទៃដី | ២១.២ | ៧.៧ |
| | ទិន្នន័យដែលបាត់បង់ | ០.០ | ០.១ |

ប្រភព: DHS, 2015

## ២.២ ច្បាប់ និងបទបញ្ញត្តិផ្សេងៗនៃវិស័យផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា

### ២.២.១ ផែនការយុទ្ធសាស្រ្តជាតិ ស្តីពី វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ២០១៤-២០២៥

**ផែនការយុទ្ធសាស្រ្តជាតិ២០១៤-២០២៥** គឺមានគោលបំណងពន្លឿនដំណើរការអនុវត្ត ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជាឆ្នាំ២០១៥ និងសម្រេចបាននូវទស្សនវិស័យរបស់វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទឆ្នាំ២០២៥ សម្រេចឱ្យបាន ១០០% (ក្រសួងអភិវឌ្ឍន៍ជនបទ, ២០១៤ខ)។ ផែនការយុទ្ធសាស្រ្តជាតិនេះរួមមាន ការបង្កើតយន្តការសម្រាប់បង្កលក្ខណៈក្នុងការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ ដោយនិរន្តរភាពបង្កើនហិរញ្ញប្បទានសម្រាប់ការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យជនបទជម្រុញ និងលើកទឹកចិត្តប្រជាជនឱ្យបានការផ្គត់ផ្គង់ទឹកស្អាតប្រកបដោយនិរន្តរភាពជម្រុញ និងលើកទឹកចិត្តប្រជាជននៅជនបទ ឱ្យទទួលបានការលើកកម្ពស់អនាម័យប្រកបដោយនិរន្តរភាព និងជម្រុញលើទឹកចិត្តប្រជាជន ឱ្យមានការផ្លាស់ប្តូរឥរិយាបថ ក្នុងការប្រើប្រាស់ទឹកស្អាត និងអនាម័យប្រកបដោយនិរន្តភាព។

### ២.២.២ ផែនការសកម្មភាពជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យនៅជនបទ ឆ្នាំ២០១៤-២០១៨

ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រជាតិ២០១៤-២០២៥ ឱ្យបានជោគជ័យក្រសួងអភិវឌ្ឍន៍ជនបទរៀបចំផែនការសកម្មភាពជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់នៅជនបទដំណាក់កាលទី១ ឆ្នាំ២០១៤-២០១៨។ មូលហេតុចម្បងនៃការបង្កើតផែនការសកម្មភាពជាតិនេះ គឺដើម្បីពន្លឿនវឌ្ឍនភាពក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យជនបទដោយកែលម្អប្រសិទ្ធិភាពវិស័យទាំងមូល ពង្រឹងសមត្ថភាពស្ថាប័ន (ជាពិសេស រដ្ឋបាលមូលដ្ឋាន) ហើយធ្វើយ៉ាងណាសម្រេចឱ្យបាន ៦០% នៃចំនួនប្រជាជនជនបទទទួលបានការផ្គត់ផ្គង់ទឹកស្អាតឆ្នាំ២០១៨ (ក្រសួងអភិវឌ្ឍន៍ជនបទ,២០១៦ខ)។ ដើម្បីសម្រេចទៅដល់គោលដៅផែនការសមកម្មភាពក្រសួងអភិវឌ្ឍន៍ជនបទមានសូចនាករក្នុងការអនុវត្តដូចខាងក្រោម៖

តារាង ២.២. តារាងសូចនាករការអនុវត្តផែនការយុទ្ធសាស្ត្រលើវិស័យផ្គត់ផ្គង់ទឹកតាមឆ្នាំនីមួយៗ

| **សូចនាករ** | **ឆ្នាំអនុវត្ត** | | | | | |
|---|---|---|---|---|---|---|
| | **២០១៤** | **២០១៥** | **២០១៦** | **២០១៧** | **២០១៨** | **២០២៥** |
| ភាគរយប្រជាជនទទួលបានការផ្គត់ផ្គង់ទឹកដែលមានការកែលម្អប្រកបដោយនិរន្តរភាព (%) | ៤៦.៧០ | ៥០ | ៥៣ | ៥៦ | ៦០ | ១០០ |

ប្រភព: ក្រសួងអភិវឌ្ឍន៍ជនបទ,២០១៤ខ/២០១៦ខ

## ២.៣ លក្ខណៈទូទៅនៃអភិបាលកិច្ចថ្នាក់ក្រោមជាតិ

អភិបាលកិច្ច គឺជាប្រពៃណី និងការរៀបចំនូវស្ថាប័ននានាដែលអជ្ញាធរនៃប្រទេសមួយបានប្រើប្រាស់។ វាជាមធ្យោបាយនៃការអនុវត្តសិទ្ធិអំណាចដែលជះឥទ្ធិពលទៅលើជីវភាពសាធារណៈ ជាពិសេសការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកិច្ច (គ.ជ.អ.ប, ២០១៤ក)។ ជាសាមញ្ញ អភិបាលកិច្ច គឺមានន័យថាជាវិធីសាស្ត្រដែលរដ្ឋ ស្ថាប័ន អង្គភាព ប្រើប្រាស់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងសន្តិសុខដើម្បីបម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ ។

រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាស្ថាប័នដែលមានទំនាក់ទំនងផ្ទាល់ជាមួយប្រជាពលរដ្ឋ ហើយជាស្ថាប័នដែលធ្វើការសម្រេចចិត្តនៅមូលដ្ឋាន ដោះស្រាយវិវាទមូលដ្ឋាន និងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ។ តាមរយៈក្រុមប្រឹក្សាដែលបានឡើងពីការបោះឆ្នោតរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលខុសត្រូវ និងឆ្លើយតបចំពោះតម្រូវការជាអទិភាពនានារបស់ប្រជាពលរដ្ឋ។ លើសពីនេះទៀត រដ្ឋបាលសេវាទីប្រជុំជននានា និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ

ដែលចូលរួមចំណែកធ្វើ ឱ្យជីវភាពប្រជាជននៅមូលដ្ឋានកាន់តែមានភាពល្អប្រសើរឡើង (គ.អ.ជ.ប ២០១៤ក)។

## ២.៣.១ ការទទួលខុសត្រូវ និងសារៈសំខាន់នៃប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការនៃអភិបាលកិច្ចថ្នាក់ក្រោមជាតិ

វិមជ្ឈការ (Decentralisation) មានន័យថារាជរដ្ឋាភិបាល ផ្តល់ឱ្យក្រុមប្រឹក្សាថ្នាក់ក្រោមជាតិនូវភាពជាម្ចាស់លើមុខងាររដ្ឋាភិបាលអំណាច និងធនធានផ្សេងៗ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនានាតាមមូលដ្ឋាន។ ក្រុមប្រឹក្សាត្រូវតែទទួលខុសត្រូវចំពោះប្រជាពលរដ្ឋតាមមូលដ្ឋាន (ក្រសួងអភិវឌ្ឍន៍ជនបទ, ២០១១)។ ឯវិសហមជ្ឈការ (Deconcentration) មានន័យថារាជរដ្ឋាភិបាល ក្រសួងឬស្ថាប័នផ្សេងៗទៀត ធ្វើប្រតិភូកម្មមុខងារនិងធនធានផ្សេងៗទៅឱ្យអង្គភាពថ្នាក់ក្រោមរបស់ខ្លួន ឬទៅឱ្យថ្នាក់ក្រុមប្រឹក្សាដទៃទៀត ដើម្បីបំពេញការងារក្នុងនាមរាជរដ្ឋាភិបាល ក្រសួង ឬក៏ជាស្ថាប័ន។ អង្គភាពថ្នាក់ក្រោម ឬក្រុមប្រឹក្សាត្រូវតែមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល (ក្រសួងអភិវឌ្ឍន៍ជនបទ, ២០១១)។

រាជរដ្ឋាភិបាល បានប្តេជ្ញាចិត្តចំពោះដំណើរនៃការកែទម្រង់អភិបាលកិច្ច។ យោងតាមក្របខ័ណ្ឌយុទ្ធសាស្ត្រ ការកែទម្រង់តាមបែបប្រជាធិបតេយ្យ ជាគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ គឺមានគោលបំណង ដើម្បីបង្កើតជាប្រព័ន្ធគ្រប់គ្រងរដ្ឋបាលឯកភាពនៅថ្នាក់រាជធានី ខេត្ត ស្រុក-ខណ្ឌ និងឃុំ-សង្កាត់។ ច្បាប់ស្តីពីការគ្រប់គ្រង រដ្ឋបាល ឃុំ-សង្កាត់ (ឆ្នាំ២០០១) និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្តក្រុងស្រុក។

វិមជ្ឈការនិងវិសហមជ្ឈការ មានសារៈសំខាន់ដូចជា៖ ទី១ គឺសម្រាប់ការសម្រេចចិត្តរបស់រដ្ឋបាលមូលដ្ឋាន។ ការផ្ទេរមុខងារនេះបានបង្វិតសេចក្តីសម្រេចចិត្តទៅប្រជាពលរដ្ឋ។ រដ្ឋបាលមូលដ្ឋានអាចឆ្លើយតប និងដោះស្រាយនូវតម្រូវការរបស់ប្រជាពលរដ្ឋពីព្រោះរដ្ឋបាលមូលដ្ឋានមានការយល់ដឹងប្រសើរជាង និងអាចមានទំនាក់ទំនងជាមួយប្រជាពលរដ្ឋបានជិតស្និទ្ធហើយមានការផ្សារភ្ជាប់ទៅនឹងសហគមន៍មូលដ្ឋានតាមរយៈក្រុមប្រឹក្សាឃុំ-សង្កាត់ និងក្រុង ស្រុក និងកាត់បន្ថយការិយាធិបតេយ្យ (ដំណើរការឆ្លងកាត់ការងារគ្នា)។ សារៈសំខាន់ទី២ គឺបង្រួញខ្សែគណនេយ្យភាព។ កាត់បន្ថយពីគណនេយ្យវែងអន្លាយ តាំងពីក្រសួងរហូតដល់ប្រជាពលរដ្ឋអ្នកទទួលសេវាមកត្រឹម ក្រុមប្រឹក្សា រដ្ឋបាលមូលដ្ឋាន ដូច្នេះវាមានភាពងាយស្រួលក្នុងការឆ្លើយតបទៅតម្រូវការរបស់ប្រជាពលរដ្ឋ។ និងសារៈសំខាន់ទី៣ គឺការបែងចែកការទទួលខុសត្រូវ។ ក្រសួង គឺជាស្ថាប័នដែលរៀបចំគោលនយោបាយប៉ុន្តែចាត់តាំងឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិជាអ្នកអនុវត្តដោយខ្លួនឯង ដើម្បីអាចធ្វើដោះស្រាយបាននូវទំនាស់ផលប្រយោជន៍ដោយក្រសួងមិនចាំបាច់អនុវត្តដោយខ្លួនឯងទៀតឡើយ (SNV, 2016)។ ចុងក្រោយ ជម្រុញឱ្យបរិមាណគុណភាព និងការផ្តល់សេវាសារធារណៈបានកាន់តែប្រសើរដល់ប្រជាពលរដ្ឋ និងលើកកម្ពស់ការផ្តល់សេវាសាធារណៈប្រកបដោយនិរន្តរភាព (រាជរដ្ឋាភិបាលកម្ពុជា, ២០១០)។

### ២.៣.២ គណនេយ្យភាពនៃវិមជ្ឈការ និងវិសហមជ្ឈការ

គណនេយ្យភាពវិស័យសាធារណៈ គឺជាគោលការណ៍មួយនៃគោលការណ៍កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ដែលពង្រឹងគណនេយ្យភាពនៅគ្រប់ជាន់ថ្នាក់ ហើយផ្តល់លទ្ធភាពឱ្យប្រជពលរដ្ឋ ពិនិត្យលើកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុនៃរដ្ឋបាលទាំងនោះ។ លើសពីនេះទៅទៀត ស្ថាប័ននិងបុគ្គលិកទាំងអស់នៅក្នុងវិស័យនេះ មានគណនេយ្យភាពយ៉ាងច្រើនចំពោះសកម្មភាពរបស់ខ្លួនជាលក្ខណៈសង្គមកិច្ច ហិរញ្ញវត្ថុ បច្ចេកទេស និងបរិស្ថាន។

វិមជ្ឈការត្រូវបានគ្រប់គ្រង ផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យដោយខ្លួនឯងដែលជាការអភិវឌ្ឍរដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យក្លាយទៅជាស្ថាប័នប្រជាធិបតេយ្យដែលស្ថាប័នទាំងនោះត្រូវធ្វើជាតំណាង និងឆ្លើយតបចំពោះតម្រូវការនានារបស់ប្រជាពលរដ្ឋ គឺជាគោលបំណងចម្បងមួយនៃកម្មវិធីជាតិរយៈពេល១០ឆ្នាំ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ដោយសារអភិបាលកិច្ចល្អបានរួមចំណែកយ៉ាងធំធេងក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន ហេតុនេះ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវលើកកម្ពស់ការអនុវត្តនូវគោលការណ៍សំខាន់ៗនៃអភិបាលកិច្ចល្អ ដោយត្រូវធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋបានចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេច និងអនុវត្តន៍សេចក្តីសម្រេចនោះ ព្រមទាំងត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាផងដែរ។ គណៈអភិបាល មានភារៈកិច្ចអនុវត្តន៍សេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ដើម្បីចាត់ចែងកិច្ចការរដ្ឋបាល និងត្រួតពិនិត្យមើលកិច្ចការប្រចាំថ្ងៃរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។ អភិបាលកិច្ចល្អជាវិធីសាស្រ្ត ឬមធ្យោបាយដែលរដ្ឋ ស្ថាប័ន អង្គភាពប្រើប្រាស់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ចសង្គមកិច្ច និងសន្តិសុខ ដើម្បីបម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ។

ប្រព័ន្ធនៃអភិបាលកិច្ចមូលដ្ឋានត្រូវអនុវត្តនៅថ្នាក់ឃុំ សង្កាត់។ អំណាចដឹកនាំ និងគ្រប់គ្រងឃុំ សង្កាត់បានមកដោយការបោះឆ្នោតជាទូទៅ ជាសកលដោយសេរីត្រឹមត្រូវ និងយុត្តិធម៌ដោយស្មើភាពចំពោះដោយសំងាត់ក្នុងក្របខ័ណ្ឌឃុំសង្កាត់នីមួយៗ (ក្រសួងអភិវឌ្ឍន៍ជនបទ, ២០១១)។ រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តចំពោះដំណើរនៃការកែទម្រង់អភិបាលកិច្ច។ យោងតាមក្របខ័ណ្ឌយុទ្ធសាស្រ្ត ការកែទម្រង់ តាមបែបប្រជាធិបតេយ្យ ជាគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការគឺមានគោលបំណង ដើម្បីបង្កើតជាប្រព័ន្ធគ្រប់គ្រងរដ្ឋបាលឯកភាពនៅថ្នាក់ រាជធានី ខេត្ត ស្រុក ខណ្ឌ និងឃុំ សង្កាត់ (ក្រសួងអភិវឌ្ឍន៍ជនបទ, ២០១១)។

តារាង ២.៣. គណនេយ្យភាពនៅក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ

| គណនេយ្យភាព | មុខងារ (ធនធាន ការប្រើប្រាស់ធនធាន និងផលប៉ះពាល់ភ្លាមៗ) | យុទ្ធសាស្ត្រ (ផលប៉ះពាល់ទៅលើស្ថាប័ននិង បរិស្ថាន) |
|---|---|---|
| ចំពោះអ្នកខាងលើ (អ្នកផ្តល់ ជំនួយ រដ្ឋាភិបាលថ្នាក់លើ) | • ប្រជាជនដែលត្រូវគ្របដណ្តប់<br>• ចំណាយក្នុងមនុស្សម្នាក់<br>• ហិរញ្ញវត្ថុនិងថវិកា<br>• បុគ្គលិក<br>• នីតិវិធី<br>• ការប្រើប្រាស់សម្ភារៈនិងឧបករណ៍ដែលផលិតក្នុងប្រទេស<br>• ការទាញយកមកវិញពីការចំណាយ | • ស្របទៅតាមគោលនយោបាយជាតិ<br>• ឥទ្ធិពលទៅលើគោលនយោបាយជាតិ<br>• សម្របសម្រួលសហប្រតិបត្តិការ<br>• រចនាសម្ព័ន្ធនិងយន្តការគាំទ្រ<br>• ឧបត្ថម្ភធន<br>• ការចូលរួមចំណាយ<br>• យេនឌ័រ<br>• ការកំណត់បទដ្ឋាន<br>• ការអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗ<br>• ការត្រួតពិនិត្យនិងវាយតម្លៃ |
| ចំពោះអ្នកខាងក្រោម (អ្នកទទួលផលម្ចាស់ឆ្នោត បុគ្គលិករដ្ឋាភិបាលថ្នាក់ក្រោម) | • ប្រជាជនដែលត្រូវគ្របដណ្តប់<br>• ចំណាយក្នុងមនុស្សម្នាក់<br>• ហិរញ្ញវត្ថុនិងថវិកា<br>• បុគ្គលិក<br>• នីតិវិធី<br>• ការប្រើប្រាស់សម្ភារៈនិងឧបករណ៍ដែលផលិតក្នុងប្រទេស<br>• ការទាញយកមកវិញពីការចំណាយ | • ស្របទៅតាមគោលនយោបាយជាតិ<br>• ឥទ្ធិពលលើគោលនយោបាយជាតិ<br>• សម្របសម្រួលសហប្រតិបត្តិការ<br>• រចនាសម្ព័ន្ធនិងយន្តការគាំទ្រ<br>• ឧបត្ថម្ភធន<br>• ការចូលរួមចំណាយ<br>• យេនឌ័រ<br>• ការកំណត់បទដ្ឋាន<br>• ការអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗ<br>• ការត្រួតពិនិត្យនិងវាយតម្លៃ |

ប្រភព: រាជរដ្ឋាភិបាលកម្ពុជា, ២០១០

## ២.៤ ការធ្វើប្រតិភូកម្មមុខងារមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ

❖ ការរៀបចំក្រុមការងារទទួលមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតស្រុកត្បូងឃ្មុំ

សេចក្ដីសម្រេចផ្ទេរ និងទទួលអនុវត្តសាកល្បងនូវមុខងារជួសជុល និងថែទាំការងារផ្គត់ផ្គង់ទឹកស្អាតជនបទនៅស្រុកត្បូងឃ្មុំ មានគោលបំណងកំណត់នូវលក្ខណៈវិនិច្ឆ័យនៃការអនុវត្តកំណត់អំពីតួនាទីនិងការទទួលខុសត្រូវរបស់ស្ថាប័នពាក់ព័ន្ធ បង្កើតយន្តការ និងតាមដានត្រួតពិនិត្យក្នុងការអនុវត្តមុខងារសាកល្បង។

ការផ្ទេរ និងការទទួលអនុវត្តសាកល្បងនូវមុខងារនេះ គឺដើម្បីលើកកម្ពស់ប្រសិទ្ធិភាពនិងគណនេយ្យភាពក្នុងការផ្ដល់សេវាជួសជុល និងថៃទាំប្រព័ន្ធផ្គត់ផ្គង់ជនបទ។ អភិបាលនៃគណៈអភិបាលស្រុក ជាអ្នកដែលសម្រេចក្នុងការចាត់តាំងរដ្ឋបាលណាមួយ ដើម្បីទទួលខុសត្រូវលើដែនសមត្ថកិច្ចរបស់ខ្លួន ដោយមិនរាប់បញ្ចូលនូវប្រព័ន្ធផ្គត់ផ្គង់របស់វិស័យឯកជន។ នៅក្នុងការអនុវត្តមុខងារនេះរដ្ឋបាលស្រុក នឹងត្រូវធ្វើការជិតស្និទ្ធផ្ទាល់ជាមួយឃុំដែលជាប់ពាក់ព័ន្ធនៅក្នុងការធ្វើផែនការរួមសម្រាប់ការជួសជុល និងថៃទាំប្រព័ន្ធផ្គត់ផ្គង់របស់ស្រុក និងផ្ដល់ការគាំទ្រក្នុងការបង្កើតក្រុមអ្នកប្រើប្រាស់ទឹក និងអនាម័យ។ ការទទួលខុសត្រូវមុខងារនេះនឹងត្រូវអនុវត្តសាកល្បងចាប់ផ្ដើមពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ រហូតដល់ថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០១៦។




ដ្យាក្រាម ២.១. ដំណើរការក្នុងការផ្ទេរមុខងារពីរដ្ឋបាលថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិ (គ.ជ.អ.ប, ២០១៤)

## ២.៥ តួនាទីរបស់ស្ថាប័នពាក់ព័ន្ធ

នៅក្នុងដំណើរការនៃការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាជននៅតាមតំបន់ជនបទ មានស្ថាប័នជាច្រើនដែលពាក់ព័ន្ធ និងមានតួនាទី និងការទទួលខុសត្រូវខុសៗគ្នាដើម្បីឲ្យវិស័យផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ជនបទកាន់តែមានភាពល្អប្រសើរ។ ខាងក្រោមនេះជាស្ថាប័ន និងអ្នកពាក់ព័ន្ធលើវិស័យផ្គត់ផ្គង់ទឹកនៅតាមតំបន់ជនបទ និងតួនាទីរបស់ស្ថាប័ននីមួយៗ។

### ក. តួនាទីរបស់ស្ថាប័នពាក់ព័ន្ធ

តួនាទី និងការទទួលខុសត្រូវ លើវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យមានកំណត់នៅតាមក្រសួងពាក់ព័ន្ធនានា រួមមាន៖

តារាង ២.៤. តួនាទី និងការទទួលខុសត្រូវលើវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យស្ថាប័នរដ្ឋ

| ស្ថាប័នពាក់ព័ន្ធលើការផ្គត់ផ្គង់ទឹកស្អាត | តួនាទី និងការទទួលខុសត្រូវ |
|---|---|
| ក្រសួងអភិវឌ្ឍន៍ជនបទ | • ទទួលខុសត្រូវលើវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ |
| នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ (DRWS) | • ស្ថិតនៅក្រោមក្រសួងអភិវឌ្ឍន៍ជនបទ គឺមានទំនួលខុសត្រូវលើការផ្គត់ផ្គង់ទឹកនៅតាមសហគមន៍នៅតំបន់ជនបទ។ នាយកដ្ឋានផ្គត់ផ្គង់ទឹកស្អាតជនបទ សហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងវិស័យផ្គត់ផ្គង់ទឹកឯកជនក្នុងការអភិវឌ្ឍន៍វិស័យផ្គត់ផ្គង់ទឹកជនបទ។<br>• អប់រំពីការប្រើប្រាស់ទឹក និងអនាម័យគឺមានគោលបំណងលើកកម្ពស់ចំណេះដឹងក្នុងសហគមន៍ និងកាត់បន្ថយហានិភ័យនៃការប្រើប្រាស់ទឹកក្នុងវិស័យផ្គត់ផ្គង់ទឹកជនបទ ប៉ារ៉ាម៉ែត្រមួយចំនួនដូចជា កម្រិតអាស៊ីត-បាស(pH) ដែក(Fe) និងកម្រិតបរិមាណអំបិល (Salinity) ត្រូវបានគេស្តក្នុងការត្រួតពិនិត្រគុណភាពទឹកដោយផ្ទាល់លើឧបករណ៍ប្រើប្រាស់សម្រាប់បរិភោគ។ |
| ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | • ផ្គត់ផ្គង់ទឹកតាមទីប្រជុំជនរាជធានី និងក្រុងលើបទបញ្ញត្តិនៃប្រព័ន្ធផ្គត់ផ្គង់ទឹកតាមទុយោដោយ វិស័យឯកជនការកំណត់បទដ្ឋានគុណភាពទឹកបរិភោគ គុណភាពទឹកផ្គត់ផ្គង់តាមទុយោ។<br>• ទទួលខុសត្រូវលើគុណភាពទឹកតាមទុយោ ដែលផ្គត់ផ្គង់តាមទីសាធារណ:។ |
| ក្រសួងផែនការ | • តាមដានត្រួតពិនិត្យ ការអនុវត្តគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា។ |

| | |
|---|---|
| ក្រសួងធនធានទឹក និងឧតុនិយម | • មានតួនាទីគ្រប់គ្រងជារួម នៃប្រភពទឹកថ្នាក់ជាតិដោយមានគោលនយោបាយស្តីពីទឹកក្រោមដី និងទឹកលើផ្ទៃដី ជាពិសេសផ្តោតទៅលើប្រព័ន្ធធារាសាស្រ្ត។ នាយកដ្ឋាននេះគ្រប់គ្រងជលសាស្ត្រ និងសកម្មភាពក្នុងទន្លេមានតួនាទីត្រួតពិនិត្យលើសកម្មភាពនានានៅអាងទន្លេមេគង្គក្រោម។<br>• MOWRAM បានសម្រេចនូវគោលនយោបាយទឹកថ្នាក់ជាតិដែលទទួលបានការឧបត្ថម្ភពី ADB និងការចូលរួមពីស្ថាប័នពាក់ព័ន្ធនានា។<br>• ទម្រង់នៃគោលនយោបាយវិស័យទឹកថ្នាក់ជាតិ បានយកមកពិភាក្សាពីសំណាក់អ្នកពាក់ព័ន្ធក្នុងវិស័យទឹក ដើម្បីអភិវឌ្ឍន៍បទដ្ឋាននៃគុណភាពទឹកផឹកថ្នាក់ជាតិ។ |
| ក្រសួងបរិស្ថាន (MoE) | • ក្រសួងបរិស្ថានត្រូវបានប្រគល់សិទ្ធិ ក្នុងការការពាររបស់ប្រទេសកម្ពុជាធនធានធម្មជាតិ និងគុណភាពបរិស្ថានពីការវិចវិល។ បញ្ជីនៃប្រព័ន្ធផ្សព្វផ្សាយនេះ ដែលវាជាការទទួលខុសត្រូវរួមបញ្ចូលនូវទឹក។<br>• ទទួលខុសត្រូវចំពោះគុណភាពទឹក និងការត្រួតពិនិត្យការបំពុលទឹកសំណល់ដែលរួមមាន ការត្រួតពិនិត្យកំហាប់ និងការចេញប័ណ្ណ។<br>• ផែនការសកម្មភាពបរិស្ថានធម្មជាតិ រួមបញ្ចូលទាំងតំបន់បង្គោលចំនួនប្រាំមួយដែលជាវិស័យជលផល និងកសិកម្មតំបន់លិចទឹកនៅតំបន់បឹងទន្លេសាបបើមិនដូច្នេះទេទឹក ដែលទទួលបានការលើកឡើងដែលបានកំណត់។ |
| ក្រសួងសុខាភិបាល (MoH) | • ក្រសួងសុខាភិបាលទទួលខុសត្រូវចំពោះ ការគ្រប់គ្រងគុណភាពនៃផ្ទៃដីនិងទឹកត្រូវបានប្រើសម្រាប់ការផ្គត់ផ្គង់ទឹក ជាសាធារណៈ ដូចជាសម្រាប់ការអប់រំសុខភាពនិងបញ្ហាផ្សេងទៀតដែលទាក់ទងទៅនឹងសុខភាពសាធារណៈ។ |
| នាយកដ្ឋានឱសថ និងស្បៀង(Food and Drugs) | • នៅក្រោមក្រសួងសុខាភិបាលមានតួនាទី ក្នុងការធ្វើការស្រាវជ្រាវទាក់ទងនឹងជម្ងឺដែលបណ្តាលមកពីទឹក។ មជ្ឈមណ្ឌលជាតិស្តីពីការលើកកម្ពស់សុខភាព(NCHP) មានតួនាទីក្នុងការផ្សព្វផ្សាយពីសុខភាពនិងសកម្មភាពនៃការអប់រំនានា។ |
| រដ្ឋបាលឃុំ-សង្កាត់ | • មានតួនាទីជំរុ និងគាំពារអភិបាលកិច្ចល្អដោយចាត់ចែង |

| | |
|---|---|
| | ប្រើប្រាស់ ធនធាននានាដែលមានប្រកបដោយចេរភាព សម្រាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋាននៅក្នុងឃុំ សង្កាត់របស់ខ្លួន បម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ និងគោរពផលប្រយោជន៍របស់ជាតិស្របតាមគោលនយោបាយទូទៅរបស់រដ្ឋ។<br>• ឃុំសង្កាត់មានតួនាទី២ប្រភេទគឺៈ តួនាទីបម្រើការងារមូលដ្ឋានសម្រាប់ផលប្រយោជន៍ឃុំ សង្កាត់ និងប្រជាពលរដ្ឋនៅក្នុងឃុំសង្កាត់របស់ខ្លួន និងតួនាទីជាភ្នាក់ងារតំណាងរដ្ឋ ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អជ្ញាធររដ្ឋ។<br>• ឃុំសង្កាត់ជា អង្គតំណាងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់របស់ខ្លួនអំពីជម្រើសជាអទិភាព ដើម្បីធ្វើសេចក្តីសម្រេចទាក់ទងនឹងសកម្មភាពបម្រើ ផលប្រយោជន៍ទូទៅក្នុងឃុំ សង្កាត់របស់ខ្លួន។<br>• ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋាននានា។ |

ប្រភព: ក្រសួងអភិវឌ្ឍន៍ជនបទ, ២០១០ក

**ខ.តួនាទីរបស់ ថ្នាក់ជាតិ រាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់**

តួនាទី ថ្នាក់ជាតិ រាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់លើការគ្រប់គ្រងរួមមានៈ

តារាងៈ ២.៥. តួនាទី និងការផ្ទេរមុខងារ លើការគ្រប់គ្រង

| មុខងារ | តួនាទី |
|---|---|
| ថ្នាក់ជាតិ | • ក្នុងការបង្កើត និងរក្សាឱ្យបាននូវបរិយាកាស ដែលបង្កលក្ខណៈឱ្យរដ្ឋបាលនានា នៃរដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តបាននូវយុទ្ធសាស្រ្តតាមវិស័យជំរុញកិច្ចអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងរួមចំណែកកាត់បន្ថយភាពក្រីក្រតាមរយៈការបង្កើត និងដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តនានាសម្រាប់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដឹកនាំអនុវត្តដោយឈរលើមូលដ្ឋាននៃមូលដ្ឋាននៃការពារសិទ្ធិនិងផលប្រយោជន៍របស់ប្រជាជន។<br>• ដើម្បីធានានូវគុណភាព នៃសេវាកម្មសាធារណៈនានាថ្នាក់ជាតិត្រូវបង្កើតស្តង់ដារជាតិគោលនយោបាយជាតិ និងកំណត់អាទិភាពនានាសម្រាប់ការអភិវឌ្ឍប្រទេស។ |

| | |
|---|---|
| រាជធានីខេត្ត | • ធ្វើការសម្របសម្រួល និងរៀបចំផែនការ និងត្រូវធានាថាការសម្រេចបែងចែងធនធាននានារបស់ខ្លួន អាចដោះស្រាយបាននូវវិសមភាពនៅតាមតំបន់នានាក្នុងរាជធានី ខេត្ត។<br>• ចូលរួមបំពេញការងារដោយផ្ទាល់ជាមួយថ្នាក់ជាតិ និងត្រូវទទួលខុសត្រូវចំពោះការអនុវត្តគោលនយោបាយជាតិ ដែលនឹងត្រូវបានអនុវត្តដោយរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈ ការផ្ទេរមុខងារ និងធនធាន។ |
| ក្រុង ស្រុក | • ក្នុងការឆ្លើយតបចំពោះតម្រូវការជាអាទិភាពនានារបស់ឃុំ និងសង្កាត់។ ផ្អែកលើសេដ្ឋកិច្ចវិមាត្រមុខងារនានាត្រូវបានផ្ទេរទៅឱ្យក្រុងឬស្រុកហើយ ដែលមានមុខងារទាំងនោះមានការពាក់ពន្ធផ្ទាល់ដល់ក្រុងឬស្រុកឬមុខងារនោះជះឥទ្ធិពលដល់ឃុំឬសង្កាត់ច្រើនជាងមួយ។<br>• ធ្វើការរៀបចំកម្មវិធីអនុវត្ត និងត្រូវផ្តល់សេវាសាធារណៈដោយផ្ទាល់ដល់ឃុំ សង្កាត់នានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ |
| ខណ្ឌ | • ដាក់បញ្ចូលប្រព័ន្ធគ្រប់គ្រងឯកភាពតែមួយរបស់ រដ្ឋបាលរាជធានីភ្នំពេញក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍក្នុងក្របខ័ណ្ឌនៃរដ្ឋបាលរាជធានីភ្នំពេញ។ |
| ឃុំ-សង្កាត់ | • តំណាងឱ្យសំឡេងរបស់ប្រជាជនក្នុងនាមជា គណៈកម្មាធិការសម្របសម្រួល បច្ចេកទេស និងតាមរយៈសិទ្ធិទទួលបាន ព័ត៌មានសិទ្ធិតាមដាន និងសិទ្ធិទទួលបានរបាយការណ៍ស្តីពីសកម្មភាពនានារបស់រដ្ឋបាល។ |

ប្រភព: ក្រសួងអភិជឍន៍ជនបទ, ២០១០

### គ. តួនាទីមុន និងក្រោយការធ្វើប្រតិភូកម្មមុខងារជួសជុលនិងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ

តួនាទី មុននិងក្រោយការទទួលមុខងារជួសជុលនិងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ

តារាង ២.៦. មុខងារមុននិងក្រោយការផ្ទេរមុខងាររបស់ស្ថាប័នទាក់ទងធ្វើប្រតិភូកម្មមុខងារជួសជុលនិងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ

| ស្ថាប័ន | មុនផ្ទេរមុខងារ | ក្រោយផ្ទេរមុខងារ |
|---|---|---|
| ក្រសួងអភិវឌ្ឍន៍ជនបទ | • ធានាឱ្យមានហិរញ្ញប្បទាន សម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ<br>• បង្កើតផ្សព្វផ្សាយ និងអនុវត្ត គោលនយោបាយ បទបញ្ញត្តិ និងយុទ្ធសាស្ត្រផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ<br>• រៀបចំផែនការ សម្រាប់ដាក់អនុវត្តគោលនយោបាយ<br>• សម្របសម្រួល ជំនួយពីខាងក្នុង និងពីខាងក្រៅព្រមទាំង កិច្ចអន្តរាគមន៍លើវិស័យនេះ<br>• អភិវឌ្ឍន៍និងលើកកម្ពស់ជំនួយ បច្ចេកទេសក្នុងវិស័យធនធានមនុស្ស<br>• បង្កើតកម្មវិធីអភិវឌ្ឍន៍ ស្រាវជ្រាវ និងអប់រំសហគមន៍<br>• កសាង និងពង្រឹងយន្តការ ឬ ប្រព័ន្ធតាមដានត្រួតពិនិត្យ និង វាយតម្លៃសមត្ថភាពបំពេញ ការងាររបស់ វិស័យនេះដើម្បីធានា វឌ្ឍនភាព ឆ្ពោះទៅរកទស្សនវិស័យ របស់ វិស័យនេះតាមចំណុចគោលដៅ<br>• ការស្វែងរកការគាំទ្រ<br>• ដឹកនាំ និងសម្របសម្រួលដល់ | • រៀបចំ និងចែកចាយនូវគោលនយោបាយយុទ្ធសាស្ត្រ និងច្បាប់បទដ្ឋាន ដែលទាក់ទងនិង RWS ការថែទាំ និងត្រួតពនិត្យគុណភាពទឹក<br>• បង្កើតបទដ្ឋានបច្ចេកទេស និងស្តង់ដា សម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាតជនបទ តាមដានអំពីអនុលោមភាពនៃបទដ្ឋាន និងស្តង់ដា<br>• គាំទ្រដល់ការធ្វើវិមជ្ឈការ នៃការងារថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទទៅថ្នាក់ក្រោមជាតិ<br>• ផ្តល់ព័ត៌មាន ត្រឹមត្រូវអំពីគ្រឿងបន្លាស់ និងអំពីអ្នកផ្តល់សេវាជួសជុលដែលមានបទពិសោធន៍ទៅឱ្យថ្នាក់ក្រោមជាតិ<br>• ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសសម្ភារៈ និងកិច្ចការរដ្ឋបាលឱ្យ ដល់ថ្នាក់ក្រោមជាតិតាមតម្រូវការ<br>• តាមដានពីអនុលោម គោលនយោបាយ និងយុទ្ធសាស្ត្រ និងផ្តល់ការណែនាំកែតម្រូវដល់ថ្នាក់ក្រោមជាតិ<br>• ធ្វើទំនាក់ទំនងរវាងអន្តរស្ថាប័ន នៅថ្នាក់ជាតិ ជាមួយភ្នាក់ងារ និងស្ថាប័នរដ្ឋពាក់ព័ន្ធផ្សេងទៀតដែលសមស្រប<br>• ធ្វើវិភាជន៍ថវិកាប្រចាំឆ្នាំរបស់ខ្លួន និង បែងចែកទៅតាមរដ្ឋបាលស្រុកនីមួយៗ និងជួយផ្តល់ការគាំទ្រផ្នែក រដ្ឋបាល |

| | | |
|---|---|---|
| | ការផ្តល់សេវាកម្មទឹកស្អាត និងអនាម័យ។ | បច្ចេកទេស និងការគាំទ្រដទៃទៀតដល់រដ្ឋបាលគ្រប់ថ្នាក់ ព្រមទាំងដាក់ចេញនូវសេចក្តីណែនាំលម្អិត ស្តីពីការគ្រប់គ្រងមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទទៅឱ្យរដ្ឋបាលស្រុក។ |
| មន្ទីរអភិវឌ្ឍន៍ជនបទ | • ប្រមូលទិន្នន័យ និងព័ត៌មានចាំបាច់សម្រាប់ធ្វើផែនការ<br>• រៀបចំផែនការអភិវឌ្ឍន៍ខេត្ត និងថវិកាដែលពាក់ព័ន្ធ<br>• សម្របសម្រួល តាមដានត្រួតពិនិត្យនិងវាយតម្លៃគ្រប់កម្មវិធីនិងគម្រោងអភិវឌ្ឍន៍ជនបទ<br>• ផ្តល់ការគាំទ្រដល់សហប្រតិបត្តិការនិងការសម្របសម្រួលអន្តរនាយកដ្ឋាន នៅក្នុងវិស័យសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទថ្នាក់ខេត្ត<br>• ផ្តល់ការគាំទ្រ ដល់ការអភិវឌ្ឍវិស័យឯកជន ជាពិសេសការអភិវឌ្ឍវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ<br>• ការស្វែងរកការគាំទ្រ។ | • ផ្តល់ការណែនាំ បច្ចេកទេសការងារប្រតិបត្តិ និងការងារគ្រប់គ្រងលើការថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទដល់រដ្ឋបាលស្រុក<br>• ផ្តល់ការណែនាំ លើការរៀបចំគម្រោង និងធ្វើផែនការថវិការដល់រដ្ឋបាលស្រុក<br>• ផ្តល់ការណែនាំ លើដំណើរការរៀបចំលទ្ធកម្ម សម្រាប់គ្រឿងបន្លាស់ និងសេវាជួសជុលអណ្តូងស្នប់<br>• ជួសជុលអណ្តូងស្នប់ (តូច ធំ) តាមសំណើរ/កិច្ចសន្យាពីរដ្ឋបាលស្រុក<br>• កសាងសមត្ថភាពមន្ត្រីសាលាស្រុកលើការជួសជុលតូច និងធំការបង្កើតក្រុមអ្នកប្រើប្រាស់ទឹក ការធ្វើផែនការ និងប្រមូលទិន្នន័យ<br>• ពិនិត្យរបាយការណ៍ និងបញ្ជីសារពើភ័ណ្ឌដែលរដ្ឋបាលស្រុកបាន ផ្តល់ជូន និងធ្វើការណែនាំបន្ថែមបើមាន<br>• រាយការណ៍អំពីស្ថានភាព ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ និងរឿងទាក់ទងផ្សេងទៀតក្នុងខេត្តទៅ នាយកដ្ឋានផ្គត់ផ្គង់ទឹកស្អាតនៃក្រសួងអភិវឌ្ឍន៍ជនបទ<br>• ផ្តល់ព័ត៌មានត្រឹមត្រូវ មិនលំអៀងពីគ្រឿងបន្លាស់ និងអ្នកផ្តល់សេវាជួសជុលដែលមាន បទពិសោធន៍ទៅថ្នាក់ស្រុក |

| | | |
|---|---|---|
| | | • ផ្ដល់ការណែនាំ បច្ចេកទេសសេវាឯកទេស ឬឧបករណ៍ឯកទេសទៅសាលាស្រុកតាមការស្នើសុំ របស់រដ្ឋបាលស្រុក<br>• មានតួនាទីផ្ដល់នូវ ការណែនាំយុទ្ធសាស្រ្ត និងជួយជម្រុញដល់ការអនុវត្ត ដោយផ្អែកតាមរបាយការណ៍ដែលខ្លួនបានទទួល និងផ្ដល់នូវការត្រួតពិនិត្យមើលបច្ចេកទេសជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។ |
| ការិយាល័យអភិវឌ្ឍន៍ស្រុក | • ការអភិវឌ្ឍសមត្ថភាពរបស់ក្រុមប្រើប្រាស់ទឹក និងអនាម័យ គាំទ្រក្រុមប្រើប្រាស់ទឹក និងអនាម័យ (ណែនាំលើការគ្រប់គ្រងហិរញ្ញវត្ថុនិងការថែទាំ ការដោះស្រាយជម្លោះ)<br>• ការឃ្លាំមើល និងត្រួតពិនិត្យគុណភាពទឹក<br>• ការប្រមូលទិន្នន័យសម្រាប់ប្រព័ន្ធគ្រប់គ្រងព័ត៌មាន<br>• ការប្រឹក្សាបច្ចេកទេសសម្រាប់ការស្ថាបនា និងការគ្រប់គ្រងគុណភាពរបស់ ហេដ្ឋារចនាសម្ព័ន្ធថ្មី<br>• ការគ្រប់គ្រងលើគុណភាពនៃការផ្ដល់ហេដ្ឋារចនាសម្ព័ន្ធថ្មី<br>• លើកកម្ពស់អនាម័យផ្ទាល់ខ្លួន។ | • ការជួសជុលតូច និងការជួសជុលធំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតដូចជា៖ អណ្ដូងស្នប់ អណ្ដូងលូ អណ្ដូងចម្រុះ ស្រះសហគមន៍ និងបណ្ដាញចែកចាយទឹកតាមទុយោដល់សហគមន៍<br>• ការធ្វើតេស្តគុណភាពដោយប្រើឧបករណ៍យួរដៃតូចៗ<br>• គាំទ្រដល់ដំណើរការបង្កើត ក្រុមអ្នកប្រើប្រាស់ទឹក និងអនាម័យ<br>• ពង្រឹងសមត្ថភាព ក្រុមអ្នកប្រើប្រាស់ទឹក និងអនាម័យក្នុងការថែទាំ គ្រប់គ្រងបញ្ជីសារពើភណ្ឌរាល់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតទាំងអស់ក្នុងដែនសមត្ថកិច្ច រដ្ឋបាលស្រុក។<br>• មានតួនាទីជួយ ដល់រដ្ឋបាលស្រុកក្នុងការអនុវត្តមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។ |

ប្រភព: ក្រសួងអភិវឌ្ឍន៍ជនបទ, ២០១០

គ. តួនាទី និងទំនួលខុសត្រូវនៃសមាជិកក្រុមស្នូលនៃក្រុមអ្នកប្រើប្រាស់ទឹក និងអនាម័យ

ការចងក្រងជាក្រុមអ្នកប្រើប្រាស់ទឹក និងអនាម័យ ត្រូវបានបែងចែកទៅតាមតារាងដែលបាននិយាយពីតួនាទី និងទំនួលខុសត្រូវនៃសមាជិកនីមួយៗ។

តារាង២.៧.តួនាទីនិងទំនួលខុសត្រូវនៃសមាជិកក្រុមស្នូលនៃក្រុមអ្នកប្រើប្រាស់ទឹកនិងអនាម័យ

| តួនាទី | មុខងារ |
|---|---|
| ប្រធាន | • ជាអ្នកពិគ្រោះយោបល់ និងពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋាន ភ្នាក់ងារផ្តល់ជំនួយនានា ព្រមទាំងរក្សាទំនាក់ទំនងឱ្យបានល្អជាមួយតំណាងភ្នាក់ងារទាំងនោះលើ បញ្ហាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ<br>• ដឹកនាំការប្រជុំដោយទៀងទាត់នូវរៀងរាល់៣ខែម្តង ឬជាមួយក្រុមអ្នកប្រើប្រាស់ទឹក ប្រសិនបើមានការចាំបាច់<br>• ធានាថាប្រភពធនធាន ដែលផ្តល់ដោយភ្នាក់ងារគាំទ្រពីខាងក្រៅត្រូវបានគ្រប់គ្រងយ៉ាងល្អ និងត្រួតពិនិត្យយ៉ាងហ្មត់ចត់<br>• វាយតម្លៃលើសេវាកម្មផ្គត់ផ្គង់ទឹក និងអនាម័យ<br>• ការផ្តល់របាយកាណ៍ស្តីពីសេវាកម្មទាំនោះជូនដល់ប្រធានភូមិ ក្រុមប្រឹក្សាឃុំ និងស្ថាប័នពាក់ព័ន្ធដើម្បីជួយសម្របសម្រួល និងដោះស្រាយនូវបញ្ហាផ្សេងៗដូចជាករណីខូចប្រភពទឹកស្អាត (អណ្តូងខូចជាដើម)<br>• ទំនាក់ទំនងនិងសហាការឱ្យបានល្អជាមួយស្ថាប័នពាក់ព័ន ឬអង្គការនានាដែលមាននៅមូលដ្ឋាន<br>• ចូលរួមក្នុងការកំណត់តម្លៃនៃការចូលរួម បដិភាគពីសហាគមន៍ដែលត្រូវចូលរួមសម្រាប់ធ្វើការជួសជុល និងថៃទាំប្រភពទឹក។ |
| អនុប្រធាន | • ជាជំនួយការឱ្យប្រធាន និងបំពេញភារកិច្ចទាំងអស់នៅពេលដែលប្រធានអវត្តមាន<br>• ទទួលបន្ទុកការងារបច្ចេកទេសក្នុងការងារជួសជុលតិចតួចនៃប្រភពទឹក<br>• ថៃរក្សាសម្ភារៈជួសជុលឱ្យបានគង់វង្ស<br>• ត្រួតពិនិត្យលទ្ធផលនៃការប្រមូលទុនក្នុងការចូលរួមរបស់សហាគមន៍<br>• បំពេញភារកិច្ច និងការទទួលខុសត្រូវផ្សេងៗទៅតាមការចាត់តាំងដែលប្រធានប្រគល់។<br>• ចូលរួមប្រជុំផ្សេងៗតាមការអញ្ជើញរបស់ប្រធាន។ |
| សមាជិកទទួលបន្ទុកហិរញ្ញិកឬ | • បំផុសឱ្យអ្នកភូមិចូលរួមបដិភោគ ជាថវិកា សម្ភារៈ និងកម្លាំងពលកម្មផ្សេងៗសម្រាប់ការចូលរួមអនុវត្តន៍គម្រោង<br>• ប្រមូល និងថៃរក្សាថវិកាទាំងនោះ ទុកសម្រាប់ការងារសាងសង់ ជួសជុល |

| | |
|---|---|
| បេឡា | និងថែទាំប្រភពទឹកស្អាត<br>• ពិនិត្យនិងរាយការណ៍ពីលទ្ធផល នៃការប្រមូលវិភាគទានរបស់អ្នកភូមិនៅតាមចំណុចទឹកនីមួយៗទៅឲឱ្យប្រធាន ឬអនុប្រធាន<br>• រៀបចំបញ្ជីស្នាមនិងកត់ត្រាចំណូលចំណាយ ក្នុងការប្រើប្រាស់ថវិកាដែលសហគមន៍ ចូលរួមសម្រាប់ការសាងសង់ជួសជុលនិងថែទាំ<br>• ចូលរួមការប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុម។ |
| សមាជិក ទទួល បន្ទុក ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត(ផ្នែកបច្ចេកទេស) | • ចូលរួមសហការសម្រួបសម្រួល ជាមួយអ្នកបច្ចេកទេសលើការផ្តល់សេវាកម្មអនាម័យដូចជាការសាងសង់បង្គន់អនាម័យការធ្វើអនាម័យទូទៅ និងការបង្ហូរទឹកសំអុយ ការលប់រណ្តៅភក់ជ្រាំ រណ្តៅដាក់សំរាម<br>• គ្រប់គ្រង និងថែរក្សាសំភារៈបរិក្ខារសម្រាប់ជួសជុលអណ្តូង<br>• តាមដាននិងជម្រុញការថែរក្សាប្រភ ឬចំណុចទឹកស្អាតក្នុងភូមិ និងការអនុវត្តអនាម័យតាមលំនៅដ្ឋានដូចជា ធ្វើរបងព័ទ្ធជុំវិញអណ្តូង បំផុសប្រជាពលរដ្ឋចូលរួមក្នុងការថែរក្សា<br>• រាយការណ៍ពីការខូចខាតសេវាផ្គត់ផ្គង់ទឹកស្អាត និងការងារផ្នែកអនាម័យជូនទៅប្រធាន<br>• ចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីការថែរក្សា និងជួសជុលអណ្តូង ឬបណ្តាញទឹកពីអ្នកបច្ចេកទេស និងជាអ្នកទទួលខុសត្រូវផ្ទាល់ក្នុងការថែរក្សា និងជួសជុលអណ្តូងទឹក<br>• ចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ |
| សមាជិក ទទួល បន្ទុក ផ្នែកអនាម័យ | • ចូលរួមសហការសម្របសម្រួលជាមួយ អ្នកបច្ចេកទេសលើការផ្តល់សេវាកម្មអនាម័យដូចជាការសាងសង់បង្គន់អនាម័យ ការធ្វើអនាម័យទូទៅ និងការលប់ រណ្តៅភក់ជ្រាំ ការជីករណ្តៅដាក់សម្រាមជាដើម។ល។<br>• តាមដាននិងជម្រុញ ការអនុវត្តអនាម័យលំនៅដ្ឋានដូចជាធ្វើរបងជុំវិញអណ្តូង និងបោសសម្អាតជាប្រចាំ<br>• ធ្វើការអប់រំ និងផ្សព្វផ្សាយពីការប្រើប្រាស់ទឹកស្អាតនិងអនាម័យនិងជម្រុញលើកទឹកចិត្ត ដល់សមាជិកក្រុមឱ្យសាងសង់បង្គន់អនាម័យតាមគ្រួសារនិង ជួយអប់រំគាត់ឱ្យចេះប្រើប្រាស់ ថែរក្សាបង្គន់ និងត្រូវបត់ជើងក្នុងបង្គន់គ្រប់ៗគ្នាជាប្រចាំ<br>• ចូលរួមក្នុងសកម្មភាពផ្សព្វផ្សាយពត៌មាន ស្តីពីអនាម័យឱ្យសហគមន៍បានយល់ដឹង និងចូលរួមក្នុងការសាងសង់បង្គន់ប្រើប្រាស់តាមគ្រួសារ<br>• ចូលរួមក្នុងការបណ្តុះបណ្តាល់ ស្តីពីការងារអនាម័យដោយមានការចូលរួម |

| | |
|---|---|
| | ពីសហគមន៍ និងជួយផ្សព្វផ្សាយអប់រំបន្តទៅអ្នកភូមិ<br>• រាយការណ៍ពីបញ្ហាខ្វះខាតផ្នែកអនាម័យ ជូនទៅប្រធានក្នុងករណីណាដែលសមាជិកណាមិនកែប្រែនូវអំពើ ដែលខ្លួនបានធ្វើឱ្យប៉ះពាល់ដល់សុខភាពសាធារណៈ ក្នុងសហគមន៍<br>• ជួយជម្រុញសហគមន៍ឱ្យសាងសង់បង្គន់អនាម័យ និងថែរក្សាបង្គន់អនាម័យតាមផ្ទះរៀងៗខ្លួនឱ្យបានស្អាតជាប្រចាំ<br>• ចូលរួមប្រជុំផ្សេងៗ តាមការអញ្ជើញរបស់ប្រធានក្រុម។ |
| សមាជិកនៃក្រុមអ្នកប្រើប្រាស់ទឹក និងអនាម័យ | • ជាអ្នកកំណត់អាទិភាពនិងជ្រើសរើសប្រភេទប្រព័ន្ធផ្គត់ផ្គង់ទឹកនៅតាមភូមិ<br>• ចូលរួមក្នុងការជ្រើសរើសប្រព័ន្ធផ្គត់ផ្គង់ទឹក ដែលពួកគាត់ចង់បាន និងមានលទ្ធភាពចូលរួម<br>• ត្រូវចូលរួមជាមួយគម្រោង ជាថវិកា កម្លាំងពលកម្ម សម្ភារៈ និងការបរិច្ចាគដែរសម្រាប់ការសាងសង់ ប្រព័ន្ធ<br>• ចូលរួមក្នុងការថែទាំ និងគ្រប់គ្រង<br>• ចូលរួមនូវគ្រប់សកម្មភាពគម្រោង<br>• មានទំនាក់ទំនងនូវរាល់ការងារថែទាំប្រភពទឹក<br>• ប្រសិនបើ មានករណីចាំបាច់សមាជិកនៃក្រុមអ្នកប្រើប្រាស់ទឹកនិងអនាម័យ និងធ្វើការកំណត់នូវគ្រួសារដែលក្រីក្រជាងគេនៅក្នុងអង្គប្រជុំដើម្បីកុំឱ្យពួកគាត់ចូលរួមថវិកា ប៉ុន្តែពួកគាត់ត្រូវចូលរួមជាកម្លាំងពលកម្មនៅក្នុងការសាងសង់អណ្តូងទឹកនេះ<br>• សមាជិកនៃក្រុមអ្នកប្រើប្រាស់ទឹក និងអនាម័យ និងរៀបចំជាគោលការណ៍ក្នុងការវិនិច្ឆ័យ ចំពោះគ្រួសារដែលក្រីក្រ។ |

ប្រភព: សៀវភៅជំនួយស្មារតីសហគមន៍ការប្រើប្រាស់ទឹកស្អាត និងការអនុវត្តអនាម័យល្អ, ២០១៤

# ជំពូក ៣
# វិធីសាស្ត្រស្រាវជ្រាវ

## ៣.១ សេចក្តីផ្តើម

ការសិក្សាខាងលើត្រូវបានជ្រើសរើសឃុំមង់រៀវ និងឃុំជីគរ ស្រុកត្បូងឃ្មុំ នៃខេត្តត្បូងឃ្មុំ សម្រាប់ធ្វើជាតំបន់សិក្សា ដែលធ្វើឡើងតាមបែបគុណវិស័យ។ ដើម្បីសម្រេចបានតាមគោលបំណងនៃការសិក្សាខាងលើនេះ ក្រុមសិក្សាបានធ្វើការប្រមូលទិន្នន័យបឋម តាមរយៈការសម្ភាសជនបង្គោលដោយប្រើប្រាស់នូវកម្រងសំណួរគោល និងប្រើប្រាស់វិធីសាស្ត្រ Snowball ដើម្បីសម្ភាសន៍ ក្រុមអ្នកប្រើប្រាស់ទឹក ដោយប្រើប្រាស់នូវកម្រងសំណួរ និងការប្រមូលទិន្នន័យបន្ទាប់បន្សំ។ ការសម្ភាសជនបង្គោល ត្រូវបានធ្វើឡើងដោយជ្រើសរើសជនណាម្នាក់ និងស្ថាប័នពាក់ព័ន្ធដែលបានដឹង និងអាចផ្តល់ ស្ថិតិនិងប្រភពប្រព័ន្ធផ្គត់ផ្គង់ទឹក និងប្រសិទ្ធផលនៃការអនុវត្តមុខងារជួសជុល និងតម្រូវការ ជាពិសេសប្រជាជន និងស្ថាប័នដែលបានទទួល និងផ្តល់សេវាផ្គត់ផ្គង់ទឹក ដំណើរការនៃការផ្ទេរមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទនេះ។ ក្រុមជនបង្គោលដែលបានជ្រើសរើស សម្រាប់ការសម្ភាសរួមមានទី១ គណៈអភិបាលស្រុកត្បូងឃ្មុំ ទី២ មន្ទីរអភិវឌ្ឍន៍ជនបទស្រុកត្បូងឃ្មុំ ទី៣ ក្រុមប្រឹក្សាឃុំ និងក្រុមអ្នកប្រើប្រាស់ទឹក។ ចំនែកទិន្នន័យបន្ទាប់បន្សំ ត្រូវបានប្រមូលពីស្ថាប័នដែលទាក់ទងនឹងប្រកាសស្តីពីការធ្វើប្រតិភូកម្មមុខងារថែទាំ និងជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ របាយការណ៍ស្តីពីការងាររដ្ឋបាល កម្មវិធីវិនិយោគប្រចាំឆ្នាំ សៀវភៅឃុំសង្កាត់ឆ្នាំ(ឃុំមង់រៀវ) ផែនទីមង់រៀវ និងស្រុកត្បូងឃុំ។ ទិន្នន័យប្រភពប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ ការជួសជុលអណ្តូង សេចក្តីប្រកាសរួមស្តីពីការអនុវត្តមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទត្រូវបានស្នើសុំទៅស្ថាប័នពាក់ព័ន្ធ (មន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ និងរដ្ឋបាលស្រុកត្បូងឃ្មុំ)។ វិធីសាស្ត្រសិក្សាស្រាវជ្រាវសង្ខេប ត្រូវបានសង្ខេបដូចក្នុងដ្យាក្រាមខាងក្រោម៖




ដ្យាក្រាម ៣.១. សង្ខេបវិធីសាស្ត្រសិក្សាស្រាវជ្រាវ

## ៣.២ តំបន់សិក្សា

### ៣.២.១ មូលហេតុនៃការជ្រើសរើសតំបន់សិក្សា

ស្រុកត្បូងឃ្មុំ គឺត្រូវបានជ្រើសរើសការសិក្សាស្រាវជ្រាវ ពីព្រោះស្រុកត្បូងឃ្មុំជាស្រុកមួយស្ថិតក្រោមយុទ្ធសាស្ត្ររបស់ក្រសួងអភិវឌ្ឍន៍ជនបទ ដែលត្រូវបានជ្រើសរើសធ្វើជាគំរូដើម្បីសាកល្បងកំណែទម្រង់ថ្មីរបស់រាជរដ្ឋាភិបាលក្នុងការធ្វើប្រតិភូម្មមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកជនបទ (ក្រសួងអភិវឌ្ឍន៍ជនបទ, ២០១៥ក)។ បន្ថែមពីលើនេះទៀត ឃុំមង់រៀវ និងឃុំជីគរ ត្រូវបានជ្រើសរើស ដោយឃុំទាំងពីរមានស្ថានភាព សេដ្ឋកិច្ច សង្គមកិច្ច ស្រដៀងគ្នាចំនែកឯ ការប្រើប្រាស់ប្រភពទឹកចំម្បង របស់ប្រជាជននៃឃុំទាំងពីរ គឺពឹងផ្អែកទៅលើប្រភពទឹកអណ្តូងដូចគ្នា ដែលឃុំម៉ង់រៀវមានចំនួនអណ្តូងសរុបចំនួន១៥៣៥អណ្តូង និងឃុំជីគរមានចំនួន១៧៩៣អណ្តូង (CDB, 2014)។ លើសពីនេះទៀតឃុំមង់រៀវជាឃុំ ដែលបានអនុវត្តការជួសជុលនិងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទនេះ និងមានបញ្ហាខូចខាតអណ្តូងច្រើនជាងឃុំនានា (មន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ, ២០១៦ខ)។ និងឃុំជីគរជាឃុំមិនទាន់មានការអនុវត្តមុខងារជួសជុលនិងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ ដើម្បីដឹងពីប្រសិទ្ធផលនៃការផ្ទេរមុខងារ។

### ៣.២.២ ផែនទីតំបន់សិក្សា

ខាងក្រោមនេះជាផែនទីតំបន់សិក្សាដែលត្រូវបានជ្រើសរើស។ តំបន់សិក្សា ឃុំមង់រៀវ និងឃុំជីគរ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។




រូបភាព ៣.១. ផែនទីទីតាំងតំបន់សិក្សា

## ៣. ៣ ទំហំ និងវិធីសាស្ត្រក្នុងការជ្រើសរើសសំណាក

ការសិក្សានេះកំណត់ជ្រើសរើសជនបង្គោល ដោយផ្ទាល់អាស្រ័យទៅលើអ្នកពាក់ព័ន្ធទៅនឹងការសិក្សា (Key Informant Interview) ក្នុងការជ្រើសរើសជនបង្គោលទាំងនោះត្រូវបានបែងចែកជាប្រភេទផ្សេងៗគ្នាដើម្បីធ្វើការសម្ភាស។ ក្រុមជនបង្គោលដែលត្រូវបានកំណត់ជ្រើសរើសដោយផ្ទាល់ទាំងនោះមានចំនួន ៣ក្រុម ដែលក្រុម៖ ទី១គឺ គណៈអភិបាលស្រុកត្បូងឃ្មុំ ទី២គឺមន្ទីរអភិវឌ្ឍន៍ជនបទស្រុកត្បូងឃ្មុំ ទី៣គឺ ក្រុមប្រឹក្សាឃុំ។ ដែលក្នុងនោះរួមមាន ប្រធានក្រុមការងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទមួយរូប ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំមួយរូប ក្រុមប្រឹក្សាឃុំមង់រៀវនិងឃុំជីគរពីររូប។ ចំនែកឯ ក្រុមផ្សេងមួយទៀតគឺ ក្រុមអ្នកប្រើប្រាស់ទឹក ដែលក្រុមទាំងនេះ ត្រូវបានជ្រើសរើសដោយវិធីសាស្ត្រ Snowball ហើយក្រុមនោះដែរត្រូវបានជើសរើសចំនួន ៣នាក់ដែលជាមេក្រុម ជាតំណាងឱ្យក្រុមនីមួយៗ។

## ៣.៤ វិធីសាស្ត្រប្រមូលព័ត៌មាន

ការសិក្សាស្រាវជ្រាវនេះគឺតាមបែបគុណវិស័យ ដូច្នោះហើយការប្រមូលទិន្នន័យមានពីរប្រភេទសំខាន់ គឺទិន្នន័យបឋម និងទិន្នន័យបន្ទាប់បន្សំ ដើម្បីទទួលបាននូវព័ត៌មានសិក្សាស្រាវជ្រាវ និងដើម្បីឆ្លើយតបនិងគោលបំណងជំពូកទី១។

### ៣.៤.១ ប្រភេទទិន្នន័យបឋម

ទិន្នន័យបឋមត្រូវបានប្រើប្រាស់កម្រងសំណួរគោលធ្វើការសម្ភាស និងឧបករណ៍ថតសម្លេង ដើម្បីឆ្លើយតបទៅនិងគោលបំណងទាំងពីរនៅជំពូកទី១។ ក្រុមបានទំនាក់ទំនងតាមទូរស័ព្ទទៅជនបង្គោលមុន ដើម្បីណាត់ជួប កំណត់ពេលវេលា និងទីតាំងច្បាស់លាស់មុននឹងចុះទៅសម្ភាសន៍ផ្ទាល់។ បន្ទាប់មក ក្រុមបានណាត់ជួបសម្ភាសន៍ជនបង្គោល ទៅតាមស្ថាប័នរបស់ពួកគាត់ផ្ទាល់ ហើយបានចំណាយរយៈពេល១ម៉ោង ក្នុងការធ្វើបទសម្ភាសន៍នីមួយៗ។ ក្រុមគោលដៅសម្រាប់ការសម្ភាសមានចំនួន៥ក្រុមផ្សេងគ្នា ទៅតាមការទទួលខុសត្រូវលើមុខងារផ្សេងៗគ្នា។

- **អ្នកតំណាងមន្ទីរអភិវឌ្ឍន៍ជនបទ**

ក្រុមបានណាត់សម្ភាសន៍ផ្ទាល់ ដើម្បីប្រមូលព័ត៌មានទាក់ទងនឹង រចនាសម្ព័ន្ធរបស់មន្ទីរអភិវឌ្ឍន៍ជនបទលើផ្នែកជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ ការទទួលខុសត្រូវរបស់មន្ទីរមុននិងក្រោយការធ្វើប្រតិភូកម្មមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទសមិទ្ធផលការអនុវត្តប្រតិភូកម្មមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទក្នុងស្រុកត្បូងឃ្មុំ ផែនការសកម្មភាពរបស់មន្ទីរ កិច្ចសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ អង្គការ និងតម្រូវការផ្សេងៗរបស់មន្ទីរ។

- **គណៈអភិបាលស្រុក**

ក្រុមបានណាត់សម្ភាសន៍ផ្ទាល់ ដើម្បីប្រមូលព័ត៌មានទាក់ទងនិង កាលបរិច្ឆេទការអនុវត្តការផ្ទេរមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ ការបង្កើតគណៈកម្មាធិការការជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ រចនាសម្ព័ន្ធនៃការគ្រប់គ្រង ដំណើរការជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ គុណសម្បត្តិ គុណវិបត្តិក្នុងការអនុវត្ត និងតម្រូវការផ្សេងៗ។

- **ក្រុមប្រឹក្សាឃុំ**

ក្រុមបានណាត់សម្ភាសន៍ផ្ទាល់ ដើម្បីប្រមូលព័ត៌មានទាក់ទងនឹងប្រភពនៃការប្រើប្រាស់ទឹក ចំនួនអណ្តូងសរុបមុខងារបន្ថែមថ្មីក្នុងការជួសជុលអណ្តូង ដំណើរការស្នើសុំការជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទមុននិងក្រោយការអនុវត្ត សមិទ្ធិផលដែលឃុំសម្រេចបានក្រោយពេលធ្វើការអនុវត្តការផ្ទេរមុខងារ ដៃគូអភិវឌ្ឍន៍ អង្គការពាក់ព័ន្ធ និងតម្រូវការ។

❖ ក្រុមអ្នកប្រើប្រាស់ទឹក

ក្រុមបានចុះទៅសម្ភាសន៍ផ្ទាល់ក្រុមអ្នកប្រើប្រាស់ទឹកចំនួន៣រូប (១ក្រុមតំណាងឱ្យ ១៥គ្រួសារ) ដើម្បីប្រមូលព័ត៌មានទាក់ទងនឹង ស្ថានភាពទូទៅរបស់ក្រុមអ្នកប្រើប្រាស់ ព័ត៌មានទូទៅនៃការប្រើប្រាស់ប្រភពទឹក និងសំណូមពរ។

### ៣.៤.២ ប្រភេទទិន្នន័យបន្ទាប់បន្សំ

ចំពោះទិន្នន័យបន្ទាប់បន្សំ ជាប្រភេទទិន្នន័យដែលមានស្រាប់ នៅតាមស្ថាប័ន បណ្ណាល័យ និងបណ្តាញអ៊ិនធ័រណេត។

ទិន្នន័យ មានដូចជា៖

- ប្រវត្តិនៃការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៃព្រះរាជាណាចក្រកម្ពុជា
- បញ្ហាការផ្គត់ផ្គង់ទឹកស្អាតជនបទនៅកម្ពុជា
- ប្រកាសស្តីពីការធ្វើប្រតិភូកម្មមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ
- ផែនការយុទ្ធសាស្ត្រក្នុងការផ្គត់ផ្គង់ទឹកស្អាតជនបទ
- ប្រកាសស្តីពីការផ្ទេរតណោទានថវិកាកម្មវិធីទៅស្រុកគោលដៅចំនួន៧ ក្នុងខេត្តត្បូងឃ្មុំ និងខេត្តកំពត
- សេចក្តីសម្រេចស្តីពីការរៀបចំក្រុមការងារទទួលមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទស្រុកត្បូងឃ្មុំ។

## ៣.៥ ការរៀបចំ និងវិភាគទិន្នន័យ

ការសិក្សាស្រាវជ្រាវនេះ ក្រុមបានប្រើប្រាស់នូវវិធីសាស្ត្រវិភាគបែបគុណវិស័យ។ ទិន្នន័យបន្ទាប់បន្សំ និងទិន្នន័យបឋម ត្រូវបានវិភាគតាមរយៈឧបករណ៍វិភាគមាតិកា (Content Analysis) និងឧបករណ៍វិភាគពីភាពស្ថានភាព SWOT (ភាពខ្លាំង ភាពខ្សោយ ឱកាស និងភាពប្រឈម) របស់ប្រព័ន្ធគោលនយោបាលថ្មីនេះ។ ឧបករណ៍វិភាគមាតិកាគឺ នីតិវិធីមួយ សម្រាប់ប្រភេទទិន្នន័យ ពាក្យសំដី ឬអាកប្បកិរិយា សម្រាប់គោលបំណងក្នុងការចាត់ថ្នាក់ សង្ខេប និងតារាង។

ដំណើរការនៃការវិភាគមាតិកា គឺមានរយៈពេលយូរ និងអាចតម្រូវឱ្យអ្នកស្រាវជ្រាវមើលទិន្នន័យដដែលៗច្រើនដងដើម្បីធានាថាបានថាការវិភាគបានយ៉ាងមត់ចត់។

ឧបករណ៍វិភាគតាមមាតិកានេះមាន១០ជំហានដូចខាងក្រោម៖




ដ្យាក្រោម ៣.២. ការវិភាគតាមឧបករណ៍វិភាគមាតិកា

# ជំពូក ៤
# លទ្ធផល និងការពិភាក្សា

## ៤.១ សេចក្តីផ្តើម

ការសិក្សាស្រាវជ្រាវ គឺផ្តោតសំខាន់ទៅលើប្រសិទ្ធផលនៃការអនុវត្តមុខងារជួសជុលថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ និងសិក្សាអំពីតម្រូវការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ដើម្បីឆ្លើយតបទៅនឹងលទ្ធផល និងការពិភាក្សាអំពីប្រសិទ្ធផលនៃការអនុវត្តមុខងារខាងលើការសិក្សាបានធ្វើការបកស្រាយដោយផ្អែកលើការប្រៀបធៀបមុខងារ និងរយៈពេលនៃការស្នើសុំជួសជុលអណ្តូង។ ចំពោះលទ្ធផល និងការពិភាក្សាអំពីតម្រូវការនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ យើងនឹងធ្វើការរៀបរាប់លម្អិតអំពីសមត្ថភាពដែលមានស្រាប់របស់មន្រ្តីថ្នាក់ក្រោមជាតិ និងតម្រូវការរវាងឃុំដែលទទួលបានការអនុវត្ត និងមិនទាន់អនុវត្ត សម្រាប់បំពេញនូវចន្លោះខាតមួយចំនួននៅក្នុងដំណើរការនៃការធ្វើប្រតិភូកម្មមុខងារផងដែរ។

## ៤.២ ស្ថានភាពទូទៅនៃស្រុកត្បូងឃ្មុំ

ស្រុកត្បូងឃ្មុំ គឺជាស្រុកមួយដែលស្ថិតភាគខាងលិច ចំងាយ២០គីឡូម៉ែត្រ ពីទីរួមខេត្តត្បូងឃ្មុំ។ ស្រុកត្បូងឃ្មុំមានឃុំសរុបចំនួន១៥ឃុំ និងភូមិសរុប២១១ភូមិ ដែលមានចំនួនគ្រួសារសរុប៤៥,១១៣គ្រួសារ ស្មើនឹង១៩៨,៤១៨នាក់ ស្រី១០០,៦០៦នាក់ និងប្រុស៩៧,៨១២នាក់ (មន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ, ២០១៥ក)។ ចំពោះរចនាសម្ព័ន្ធការងាររបស់រដ្ឋបាលស្រុកត្បូងឃ្មុំក៏ដូចគ្នាទៅនឹងរដ្ឋបាលស្រុកដ៏ទៃផ្សេងទៀតដែរ គឺមានការចែងចែកនូវមុខងារ និងតួនាទីច្បាស់លាស់។ ម្យ៉ាងវិញទៀត ចំពោះប្រភពទឹកដែលចំបងសម្រាប់ការប្រើប្រាស់របស់ប្រជាជនគឺទឹកអណ្តូង (មិនរាប់បញ្ចូលទឹកភ្លៀង)។ ប្រភពទឹកទាំងនោះត្រូវបានបែងចែកទៅតាមប្រភេទនៃអណ្តូងដែលមានដូចជា អណ្តូងស្នប់ប្រភេទ AFRIDEV (អណ្តូងសហគមន៍) អណ្តូងស្នប់ខ្មៅលេខ៦ ឬ(អណ្តូងក្បាលខ្មៅ) អណ្តូងចម្រុះ និងអណ្តូងលូ (អាចជារបស់សហគមន៍ និងឯកជន) ជាដើម។ ជាក់ស្តែង បើយោងទៅតាមទិន្នន័យប្រភពទឹក របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំបានបង្ហាញថា នៅក្នុងស្រុកត្បូងឃ្មុំ មានប្រភេទអណ្តូងស្នប់រួម AFRIDEV (អណ្តូងសហគមន៍) ចំនួន៤៣៦អណ្តូងដែលអាចប្រើបាន និងខូចចំនួន១៥៦អណ្តូង ប្រភេទអណ្តូងស្នប់រួមខ្មៅលេខ៦ដែលអាចប្រើបានមានចំនួន២,០៤៨ និងខូចចំនួន១៩៤អណ្តូង ប្រភេទអណ្តូងចម្រុះ ដែលអាចប្រើបានមានចំនួន៧៦៨អណ្តូង និងខូចចំនួន២០២ ប្រភេអណ្តូងស្នប់ឯកជនមានចំនួន៩,៦០៦អណ្តូង និងអណ្តូងលូឯកជនមានចំនួន៨,៩១៦អណ្តូងព្រមទាំងអាងរងទឹកភ្លៀងចំនួន៨៥ ប្រឡាយមេទឹកចំនួន១១៣ខ្សែស្រះសហគមន៍ចំនួន២៣និងស្ថានីយផលិតទឹកសុទ្ធចំនួន៧។

តារាងខាងក្រោមបង្ហាញពីប្រភពទឹកនីមួយៗនៅក្នុងស្រុកត្បូងឃ្មុំ និងដ្យាក្រាម ៤.១ ដែលបង្ហាញពីរចនាសម្ព័ន្ធការងាររបស់រដ្ឋបាលស្រុកត្បូងឃ្មុំ។

តារាង ៤.១. សង្ខេបទិន្នន័យប្រភពទឹកក្នុងស្រុកត្បូងឃ្មុំ

| ល.រ | ស្រុក | គ្រួសារសរុប | ខ្នងផ្ទះ | ចំនួនប្រជាជន | | អណ្តូងស្នប់ រួម អាហ្វីដេស៍ | | អណ្តូងស្នប់ រួម ខ្មៅលេខ ៦ | | អណ្តូងចម្រុះ | | អណ្តូងឯកជន | | អាងទឹកភ្លៀង | ប្រឡាយគិតជាខ្សែ | ស្រះសហគមន៍ | ស្ថានីយផលិតទឹកសុទ្ធ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | សរុប | ស្រី | ប្រើបាន | ខូច | ប្រើបាន | ខូច | ប្រើបាន | ខូច | ស្នប់ | លូ | | | | |
| ១ | ត្បូងឃ្មុំ | ៤៥១១៤ | ៣៨១៣៩ | ១៩៦៣០១ | ១០០៦០៧ | ៤៣៦ | ១៥៦ | ២០៤៨ | ១៩៤ | ៧៦៨ | ២០២ | ៩៦០៦ | ៨៩១៦ | ៨៥ | ១១៣ | ២៣ | ៧ |

ប្រភព: មន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ, ២០១៥ក




ដ្យាក្រាម ៤.១. រចនាសម្ព័ន្ធការងាររបស់រដ្ឋបាលស្រុកត្បូងឃ្មុំ (សាលាស្រុកត្បូងឃ្មុំ, ២០១៦)

ចំណាំ៖ ក្រុមប្រឹក្សាស្រុកមានសមាជិក១៩រូប និងគណៈអភិបាលមានសមាជិក។

## ៤.៣ តួនាទី និងមុខងារ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ នៃការគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ

នៅក្នុងដំណើរការផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាជននៅតំបន់រដ្ឋបាលស្រុកត្បូងឃ្មុំ ក៏ដូចជាមន្ទីរអភិវឌ្ឍន៍ខេត្តត្បូងឃ្មុំ ដែលមានការិយាល័យផ្គត់ផ្គង់ទឹកស្អាតខេត្តត្បូងឃ្មុំ ជាតំណាងបានដើរតួយ៉ាងសំខាន់ក្នុងគោលបំណង ធ្វើយ៉ាងណាឱ្យប្រជាជននៅតំបន់ជនបទទទួលបាននូវប្រភពទឹកស្អាតប្រើប្រាស់ប្រកបដោយសុវត្ថិភាព និងនិរន្តរភាពស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាល។ សព្វថ្ងៃនេះទោះបី រាជរដ្ឋាភិបាលកម្ពុជាសម្រេចបាននូវផែនការអភិវឌ្ឍន៍សហសវត្សន៍កម្ពុជាដែលកំណត់ថានឹងធ្វើឱ្យអត្រាផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជាឡើងដល់ ៥០%នៅក្នុងឆ្នាំ២០១៥ និង១០០% នៅឆ្នាំ២០២៥ ក៏ពិតមែន ប៉ុន្តែប្រសិនបើយើងក្រឡេកមើលទៅលើវឌ្ឍនភាព នៃអត្រាកំណើនគឺនៅមានកម្រិតទាបនៅឡើយបើប្រៀបធៀបទៅនឹងប្រទេសជិតខាងក្នុងតំបន់(ក្រសួងអភិវឌ្ឍន៍ជនបទ, ២០១៦គ)។ ដូចនេះរដ្ឋាភិបាលកម្ពុជាក៏បានធ្វើការកែប្រែនូវគោលនយោបាយតាម រយៈការធ្វើកំណែទម្រង់មុខងារមួយចំនួនដោយក្នុងនោះ ក៏មានមុខងារជួសជុលនិងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ ការអនុវត្តសាកល្បងផងដែរ។ ជាក់ស្តែងស្រុកត្បូងឃ្មុំ ក៏ជាស្រុកមួយក្នុងចំណោមស្រុកទាំង៧ ដែលបានទទួលសេចក្តីប្រកាសស្តីពីការអនុវត្តសាកល្បងនូវការផ្ទេរមុខងារនេះផងដែរ។ ជាមួយគ្នានេះដែរ រដ្ឋបាលស្រុកត្បូងឃ្មុំក៏ត្រូវការចាត់តាំងឱ្យរៀបចំបង្កើតនូវក្រុមការងារទទួលមុខងារជួសជុលនិងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ ដោយយោងទៅតាមសេចក្តីសម្រេចលេខ ១៤៨/១៥ របស់ក.អ.ជ ដើម្បីទទួលបន្ទុកលើការអនុវត្តមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទផងដែរ។ ម្យ៉ាងវិញទៀត មន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំក៏ត្រូវបានបង្កើតក្រុមការងាររបស់ខ្លួនមួយផងដែរដើម្បីជួយជម្រុញគាំទ្រការងារដល់រដ្ឋបាលស្រុកគោលដៅទាំងនោះឱ្យបានទទួលជោគជ័យក្នុងការអនុវត្តលើការផ្ទេរមុខងារនេះជាចាំបាច់។ ទន្ទឹមនឹងការជួយគាំទ្រពីមន្ទីរអភិវឌ្ឍន៍ជនបទ ក្រសួងអភិវឌ្ឍន៍ជនបទមានការសហការជាមួយ អង្គការអភិវឌ្ឍន៍ហូឡង់ ដែលបានបង្កើតវគ្គបណ្តុះបណ្តាលខ្លីមួយស្តីពីការណែនាំពីលក្ខណៈបច្ចេកទេសទូទៅ កាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៥។ ហើយថ្មីៗនេះ កម្មវិធីវគ្គបណ្តុះបណ្តាលឆ្នាំ២០១៦ នេះមានរយៈពេល៧ថ្ងៃ ដែលមានសមាជិកចូលរួមពីខាងមន្ត្រីថ្នាក់ក្រោមជាតិមានចំនួន៦នាក់ ដោយ ៣នាក់មកពីខាងមន្ទីរ និង៣នាក់ទៀតមកពីខាងស្រុក។ គោលបំណងនៃការសិក្សានេះ គឺចង់ពង្រឹងសមត្ថភាពសម្រាប់វិមជ្ឈការនៃការថែទាំនិងជួសជុលវិស័យផ្គត់ផ្គង់ទឹកស្អាតជនបទ។ វគ្គបណ្តុះបណ្តាលមានដូចជា៖ យល់ដឹងពីការអភិវឌ្ឍសមត្ថភាពក្នុងការថែទាំ និងជួសជុលនៃប្រព័ន្ធផ្គត់ផ្គង់ទឹកជនបទ ការយល់ដឹងពីបរិបទនៃដំណើរការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ជាតិទំនាក់ទំនងរវាងទឹក អនាម័យ ការថែទាំខ្លួនប្រាណ ការយល់ដឹងពីផ្នែកយេនឌ័រក្នុង វិស័យទឹកនិងអនាម័យ (WASH) ការយល់ដឹងពីការថែទាំនិង ជួសជុលក្នុងប្រព័ន្ធផ្គត់ផ្គង់ទឹកជនបទនិរន្តរភាព

នៃប្រព័ន្ធផ្គត់ផ្គង់ទឹកជនក្នុងឧបស្ព័ន្ធ ច ប្រព័ន្ធច្រើនថ្នាក់នៃការប្រើប្រាស់និងថែទាំក្នុងប្រព័ន្ធផ្គត់ផ្គង់ទឹកជនបទ វិភាគអ្នកពាក់ព័ន្ធសំខាន់ៗ ទិដ្ឋភាពបច្ចេកទេសនៃថែទាំ និងជួសជុល ការធ្វើបញ្ជីសារពើភ័ណ្ឌនៃកម្មវិធីផ្គត់ផ្គង់ទឹកជនបទមានក្នុងឧបស្ព័ន្ធ ឆ ការបង្កើតក្រុមប្រើប្រាស់ទឹក និងអនាម័យ(WSUGs) ការរៀបចំផែនការ និងថវិការសម្រាប់អនុវត្តន៍មុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការទំនាក់ទំនងរវាងក្រុមប្រឹក្សាស្រុកក្នុងការថែទាំ និងជួសជុលនៃប្រព័ន្ធផ្គត់ផ្គង់ទឹកជនបទ លំហូរថវិការ និងការគ្រប់គ្រងហិរញ្ញវត្ថុក្នុងការថែទាំ និងជួសជុលជំនាញការទំនាក់ទំនង និងការរុញលើកទឹកចិត្ត។ ជាលទ្ធផលយើងឃើញថាប្រសិទ្ធិភាពនៃការអនុវត្តគោលនយោបាយថ្មី តាមរយៈការធ្វើប្រតិភូកម្មមុខងារមួយចំនួនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិជាអ្នកគ្រប់គ្រង ចាត់ចែង និងអនុវត្តលើមុខងារនេះគឺពិតជាទទួលបានលទ្ធផលល្អប្រសើរជាងមុនមែន ពីព្រោះវាអាចធ្វើឱ្យមានការបង្កិតសេចក្តីសម្រេចចិត្តទៅជិតប្រជាពលរដ្ឋ ការបង្រួញគណនេយ្យភាព មានការបែងចែកការទទួលខុសត្រូវច្បាស់លាស់ និងដាច់ពីគ្នា និងការរៀបចំផែនការកាន់តែមានប្រសិទ្ធិភាពខ្ពស់ជាងមុនដែលជាហេតុធ្វើឱ្យដំណើរការ និងរយៈពេលឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជនមានភាពឆាប់រហ័សជាងមុន។

### ៤.៣.១ តួនាទី និងមុខងារមុន និងក្រោយការផ្ទេរមុខងាររបស់រដ្ឋបាលស្រុកត្បូងឃ្មុំ

#### ក. មុខងារមុនពេលទទួលបានការធ្វើប្រតិភូកម្ម

ក្នុងនាមជាអជ្ញាធរមូលដ្ឋាន រដ្ឋបាលស្រុក មានមុខងារ តួនាទី និងការទទួលខុសត្រូវជាច្រើន ក្នុងការធ្វើឱ្យប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនទទួលបាននូវការអភិវឌ្ឍ។ ជាក់ស្តែង បើយោងទៅតាមមាត្រាទី ១១៥ នៃអនុក្រឹត្យលេខ ២១៦អនក្រ.បក ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពី តួនាទី និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សាគណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក ក្រុមប្រឹក្សាស្រុក គឺត្រូវបង្កើត ជម្រុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ដោយក្រុមប្រឹក្សាស្រុកត្រូវ៖

- ជួយក្រុមប្រឹក្សាឃុំ-សង្កាត់ក្នុងស្រុក ដើម្បីជម្រុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។
- រួមជាមួយក្រុមប្រឹក្សាឃុំ- សង្កាត់ក្នុងស្រុក ដើម្បីជម្រុញឱ្យមានការចូលរួមពីសាធារណជនក្នុងដំណើរការអភិបាលកិច្ចនៅក្នុងស្រុក និងឃុំ សង្កាត់ក្នុងស្រុក
- ស្វែងយល់ និងឆ្លើយតបចំពោះតម្រូវការក្នុងស្រុករបស់ខ្លួន និងចំពោះសំណើរបស់ក្រុមប្រឹក្សា-សង្កាត់ក្នុងស្រុក។

ក្នុងនោះផងដែរ ដើម្បីឱ្យការអនុវត្តទទួលបានជោគជ័យ ក្រុមប្រឹក្សាស្រុក ក៏ត្រូវមានគណៈ កម្មាធិការពិគ្រោះយោបល់ចំនួនបី (០៣) ដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រង រដ្ឋបាលរាជធានី ខេត្ត-ក្រុង ស្រុក-ខណ្ឌដែលរួមមាន៖

- គណៈកម្មាធិការបច្ចេកទេស
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ
- គណៈកម្មាធិការលទ្ធកម្ម។

ក្រៅពីនេះក្រុមប្រឹក្សាស្រុក អាចបង្កើតគណៈកម្មាធិការបន្ថែមទៀតតាមការចាំបាច់។

**ខ. មុខងារក្រោយពេលទទួលបានការផ្ទេរប្រតិភូកម្ម**

ក្រៅពីមុខងារ និងតួនាទីដូចដែលមានស្រាប់ នៅក្នុងអនុក្រឹត្យលេខ ២១៦អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក រដ្ឋបាលស្រុកក៏បានទទួលនូវការផ្ទេរមុខងារមួយផ្សេងទៀត ដោយយោងតាមប្រការ២ នៃសេចក្តីប្រកាសស្តីពីការផ្ទេរប្រតិភូកម្មមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទទៅដល់រដ្ឋបាលស្រុកគោលដៅ។ នៅក្នុងនោះដែរ ក្រសួងអភិវឌ្ឍន៍ជនបទបានកំណត់នូវមុខងារចំនួន៥ ដែលស្ថិតនៅក្នុងមុខងារជួសជុលនិងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ (ក្រសួងអភិវឌ្ឍន៍ជនបទ, ២០១៥ក) ដែលមុខងារទាំងនោះរួមមាន៖

- ការជួសជុលតូច និងការជួសជុលធំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតដូចជា៖ អណ្តូងស្នប់ អណ្តូងលូ អណ្តូងចម្រុះ ស្រះសហគមន៍និងបណ្តាញចែកចាយទឹកតាមទុយោដល់សហគមន៍
- ការធ្វើតេស្តគុណភាព ដោយប្រើឧបករណ៍យួរដៃតូចៗ
- គាំទ្រដល់ដំណើរការបង្កើតក្រុមអ្នកប្រើប្រាស់ទឹក និងអនាម័យ
- ពង្រឹងសមត្ថភាពក្រុមអ្នកប្រើប្រាស់ទឹក និងអនាម័យក្នុងការថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត
- គ្រប់គ្រងបញ្ជីសារពើភ័ណ្ឌរាល់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតទាំងអស់ ក្នុងដែនសមត្ថកិច្ចរដ្ឋបាលស្រុក (រាជរដ្ឋាភិបាលកម្ពុជា ២០០៩)។

តារាង ៤.២. ប្រៀបធៀបពីមុខងារចាស់ និងមុខងារបន្ថែមថ្មីរបស់រដ្ឋបាលស្រុកត្បូងឃ្មុំ

| **មុខងារចាស់** | **មុខងារបន្ថែមថ្មី** |
|---|---|
| • ជួយក្រុមប្រឹក្សាឃុំ-សង្កាត់ក្នុងស្រុក ដើម្បីជម្រុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។<br>• រួមជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ក្នុងស្រុក ដើម្បីជម្រុញឱ្យមានការចូលរួមពីសាធារណជន ក្នុងដំណើរការអភិបាលកិច្ចនៅក្នុងស្រុក និងឃុំ-សង្កាត់ក្នុងស្រុក<br>• ស្វែងយល់ និងឆ្លើយតបចំពោះតម្រូវការក្នុងស្រុករបស់ខ្លួន និងចំពោះសំណើរបស់ក្រុមប្រឹក្សាឃុំ- សង្កាត់ក្នុងស្រុក។ | • ការជួសជុលតូចនិងការជួសជុលធំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតដូចជា៖ អណ្តូងស្នប់ អណ្តូងលូ អណ្តូងចម្រុះ ស្រះសហគមន៍និងបណ្តាញចែកចាយទឹកតាមទុយោដល់សហគមន៍<br>• ការធ្វើតេស្តគុណភាព ដោយប្រើឧបករណ៍យួរដៃតូចៗ<br>• គាំទ្រដល់ដំណើរការបង្កើតក្រុមអ្នកប្រើប្រាស់ទឹក និងអនាម័យ<br>• ពង្រឹងសមត្ថភាពក្រុមអ្នកប្រើប្រាស់ទឹក និងអនាម័យក្នុងការថែទាំប្រព័ន្ធផ្គត់ផ្គង់ធនធានទឹកស្អាត<br>• គ្រប់គ្រងបញ្ជីសារពើភ័ណ្ឌរាល់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតទាំងអស់ក្នុងដែនសមត្ថកិច្ចរដ្ឋបាលស្រុក។ |

ដូចដែលបានរៀបរាប់នៅខាងលើរួចមកហើយ ទោះបីជាមានការបន្ថែមមុខងារមួយចំនួនក្រោយពេលការធ្វើប្រតិភូកម្មមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទយ៉ាងណាក្តីក៏**រដ្ឋបាលស្រុកត្បូងឃ្មុំ នៅតែមានតួនាទី និងទំនួលខុសត្រូវលើមុខងារចាស់ដដែល** ពីព្រោះដោយសារសមាសភាពនៃក្រុមការងារទទួលមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទស្រុកត្បូងឃ្មុំ គឺត្រូវបានជ្រើសតាំងពីបុគ្គលិកនៃរដ្ឋបាលស្រុកដដែល និងរួមជាមួយមន្ត្រី នៃការិយាល័យអភិវឌ្ឍន៍ជនបទស្រុក ព្រមទាំងប្រធានក្រុមប្រឹក្សាឃុំទាំងអស់ដែលជាសមាជិក។ ទាំងនេះ សរបញ្ជាក់ឱ្យឃើញថា ក្រោយពីការធ្វើប្រតិភូកម្មមុខងារថ្មីនេះបានធ្វើឱ្យទំហំនៃការទទួលខុសត្រូវរបស់រដ្ឋបាលស្រុកត្បូងឃ្មុំគឺកាន់តែច្រើនឡើង ពុំសមស្របទៅនឹងទំហំនៃបុគ្គលិករបស់រដ្ឋបាលស្រុក ដែលអាចបណ្តាលឱ្យការអនុវត្តលើការងារទូទៅអាចនឹងមានចន្លោះខ្វះខាតច្រើនជាងមុន។ យ៉ាងណាមិញ ទោះបីជាបុគ្គលិកដែលត្រូវបានចាត់តាំងទាំងនោះទទួលបាននូវការបណ្តុះបណ្តាលស្តីពីការអនុវត្តតួនាទីយ៉ាងណាក្តី ក៏ប៉ុន្តែយើងឃើញថា ការអនុវត្តលើមុខងារថ្មីទាំងនេះ គឺមានភាពខុសគ្នាទៅនឹងជំនាញ និងបទពិសោធន៍ការងាររបស់ពួកគាត់យ៉ាងខ្លាំង ពីព្រោះបើយើងពិនិត្យទៅមើលលើមុខងារចាស់របស់ពួកគាត់ យើងឃើញថា វាជាការងារទូទៅដែលពាក់ព័ន្ធទៅនឹងការធ្វើអភិបាលកិច្ចលើ

ដែនសមត្ថកិច្ចរបស់ខ្លួន ប៉ុន្តែផ្ទុយទៅវិញ បើយើងពិនិត្យមើលលើមុខងារថ្មីដែលបានបន្ថែម យើងឃើញថា វាជាការងារដែលទាក់ទិនទៅនឹងបច្ចេកទេស និងទាមទារឱ្យមានបទពិសោធន៍ច្រើនក្នុងការអនុវត្ត។ ប៉ុន្តែយ៉ាងណាមិញ បើទោះបីជាក្រុមការងារថ្មីនេះ ពុំទាន់មានបទពិសោធន៍ការងារ លើការអនុវត្តលើមុខងារថ្មីនេះក្តី ក៏ដំណើរការនៃការអនុវត្តលើមុខងារថ្មីនេះនៅតែមានភាពរលូន។ ទាំងនេះគឺដោយសារតែ មានការចូលរួមគាំទ្រនូវផ្នែកបច្ចេកទេសពីមន្ទីរអភិវឌ្ឍន៍ជនបទខេត្តក៏ដូចជាស្ថាប័នពាក់ព័ន្ធមួយចំនួនទៀត។ ក្រុមការងារនេះ គឺត្រូវបានជ្រើសតាំងចេញពីការប្រជុំគណៈអភិបាលស្រុក ហើយក្រុមបុគ្គលិកមន្ត្រីរាជការគឺត្រូវជ្រើសតាំងតាមបែបនីតិវិធីជ្រើសរើសមន្ត្រីដែលមានជាប់កិច្ចសន្យាស្រាប់ ពោលគឺបុគ្គលិកខាងរដ្ឋបាលស្រុកដែលមានស្រាប់ ដើម្បីជួយក្នុងមុខងារថ្មីនេះ។ ហើយការជ្រើសតាំងនេះគឺឈរលើសេចក្តីសម្រេចរួមស្តីពីការអនុវត្តមុខងារសាកល្បងជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទប្រការទី៩ ″ការផ្ទេរបុគ្គលិក″ (រាជរដ្ឋាភិបាលកម្ពុជា, ២០១៣)។

ដូចគ្នានេះដែរ ដ្យាក្រាមខាងក្រោមនេះ បង្ហាញពីរចនាសម្ព័ន្ធរបស់ក្រុមការងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទនៃរដ្ឋបាលស្រុកត្បូងឃ្មុំផងដែរ។




ដ្យាក្រាម ៤.២. រចនាសម្ព័ន្ធក្រុមការងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទនៃរដ្ឋបាលស្រុកត្បូងឃ្មុំ (ក្រសួងអភិវឌ្ឍន៍ជនបទ, ២០១៥ខ)

ដូចដែលបានរៀបរាប់ខាងលើក្រុមការងារនេះត្រូវសម្រេចចាត់តាំងដោយអភិបាលនៃគណៈអភិបាលស្រុកត្បូងឃ្មុំនិងមានសមាសភាពដូចតារាងខាងក្រោម៖




ដ្យាក្រាម ៤.៣. សមាសភាពនៃក្រុមការងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ របស់ រដ្ឋបាលស្រុកត្បូងឃ្មុំ

ចំពោះសមិទ្ធផលដែលរដ្ឋបាលស្រុក សម្រេចបានក្រោយពេលធ្វើប្រតិភូកម្មមុខងារក្នុងរយៈពេលកន្លងមកគឺមានដូចជាការជួសជុល នូវអណ្តូងស្នប់សហគមន៍ប្រភេទ អាហ្វ្រីដេវ (AFRIDEV) បានចំនួន ៥អណ្តូង និងប្រភេទអណ្តូងរួមខ្មៅលេខ ៦ (ក្បាលខ្មៅ) ចំនួន៤អណ្តូង។ ក្រៅពីនោះ រដ្ឋបាលស្រុកត្បូងឃ្មុំក៏កំពុងនឹងបានចុះធ្វើការសិក្សា និងប្រមូលព័ត៌មានអំពីចំនួនអណ្តូងសហគមន៍ដែលមានបញ្ហាផ្សេងទៀត ដើម្បីធ្វើផែនការក្នុងការជួសជុលបន្តទៀតផងដែរ។ ខាងក្រោមនេះជាសមិទ្ធផលដែលរដ្ឋបាលស្រុកសម្រេចបានក្រោយពេលការធ្វើប្រតិភូកម្មមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ នៅក្នុងស្រុកត្បូងឃ្មុំ។

តារាង ៤.៣. សមិទ្ធផលដែលរដ្ឋបាលស្រុកសម្រេចបាន

<table>
<tr><th>ល.រ</th><th>ស្រុក</th><th>ឃុំ</th><th>ភូមិ</th><th>ប្រភេទអណ្តូង</th><th>ចំនួនអណ្តូង</th></tr>
<tr><td>១</td><td rowspan="3">ត្បូងឃ្មុំ</td><td>មង់រៀវ</td><td>មង់ទី៧</td><td>អាហ្វ្រីដេវ (AFRIDEV)</td><td>៥</td></tr>
<tr><td rowspan="2">២</td><td rowspan="2">ជប់</td><td>ស្លាបក្អោង</td><td>អាហ្វ្រីដេវ (AFRIDEV)</td><td>២</td></tr>
<tr><td>ទួលទ្រា</td><td>ខ្មៅលេខ៦ (ក្បាលខ្មៅ)</td><td>២</td></tr>
</table>

តាមរយៈសមិទ្ធផលខាងលើ យើងឃើញថាវាពុំទាន់នឹងបានឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជន ក៏ដូចជាក្រុមអ្នកប្រើប្រាស់ទឹកនៅឡើយទេ ពីព្រោះបើយើងពិនិត្យទៅលើចំនួនអណ្តូងសហគមន៍នៅក្នុងស្រុកយើងឃើញថា មានចំនួនច្រើនរហូតដល់ទៅ ៤៣៦អណ្តូង និងអណ្តូងដែលមានបញ្ហាក៏មានចំនួនច្រើនផងដែររហូតដល់ទៅ ១៣៦អណ្តូង ដែលភាគច្រើនគឺត្រូវការការជួសជុលជាចាំបាច់។ ប៉ុន្តែទោះបីជាយ៉ាងណាក្តី តាមរយៈសមិទ្ធផលខាងលើនេះ យើងក៏អាចសន្និដ្ឋានបានថា ការអនុវត្តលើការធ្វើប្រតិភូកម្មមុខងារថ្មីនេះ គឺពិតជាមានផលប្រយោជន៍យ៉ាងខ្លាំងសម្រាប់ការផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាជននៅតំបន់ជនបទ ជាពិសេសប្រជាជនដែលពុំមានលទ្ធភាពប្រើប្រាស់ប្រភពទឹកផ្ទាល់ខ្លួន។ ជាមួយគ្នានេះដែរ តាមរយៈសមិទ្ធផលដែលសម្រេចបានខាងលើ យើងក៏អាចធ្វើការសន្និដ្ឋានបានដែរថា ការអនុវត្តសាកល្បងលើមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទនៅក្នុងស្រុកត្បូងឃ្មុំនេះ អាចនឹងទទួលបានភាពជោគជ័យ១០០% និងស្របតាមពេលវេលាដែលបានកំណត់។ ជាក់ស្តែង លទ្ធផលខាងលើបានបង្ហាញថាចំនួនអណ្តូងដែលបានធ្វើការជួសជុលនាពេលកន្លងមកនេះ គឺសម្រេចបានប្រមាណជា ៨០% នៃផែនការដែលបានកំណត់សម្រាប់ ការអនុវត្តសាកល្បងលើមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទពិតប្រាកដមែន។

### ៤.៣.២ តួនាទី និងមុខងារមុន និងក្រោយការផ្ទេរមុខងាររបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ

នៅក្នុងដំណើរការនៃការអនុវត្តលើការងារផ្គត់ផ្គង់ទឹកស្អាតជនបទ និងក្រោយពេលដែលទទួលបាននូវមុខងារថ្មីនេះ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំមានតួនាទី និងការទទួលខុសត្រូវមួយចំនួនដូចជា៖

#### ក. មុខងារមុនពេលធ្វើប្រតិទ្ធកម្មមុខងារ៖

ដើម្បីឱ្យវិស័យផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ជនបទ ទទួលបានភាពល្អប្រសើររាជរដ្ឋាភិបាលកម្ពុជាបានកំណត់ឱ្យបង្កើតនូវការិយាល័យផ្គត់ផ្គង់ទឹកស្អាតជនបទ នៅតាមមន្ទីរអភិវឌ្ឍន៍ជនបទគ្រប់ខេត្ត/ក្រុង ទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា ស្របទៅតាមអនុក្រឹត្យលេខ៧៨ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ពីព្រោះរាជរដ្ឋាភិបាលកម្ពុជាមានទស្សនៈវិស័យយ៉ាងមុតមាំ ដោយមើលឃើញថា ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទគឺជាវិស័យដែលចាំបាច់បំផុតសម្រាប់ធ្វើឱ្យមានការលើកកម្ពស់ សេដ្ឋកិច្ច សុខមាលភាពជីវភាពប្រជាជននៅតាមតំបន់ជនបទ។ ជាមួយគ្នានេះដែរ ដើម្បីឱ្យដំណើរការការងារមានភាពរលូនគ្រប់ការិយាល័យផ្គត់ផ្គង់ទឹកស្អាតជនបទទាំងអស់ រួមទាំងការិយាល័យផ្គត់ផ្គង់ទឹកស្អាតជនបទ ខេត្តត្បូងឃ្មុំផងដែរត្រូវបានចាត់តាំងឱ្យទទួលខុសត្រូវលើតួនាទី និងមុខងារមួយចំនួនដូចខាងក្រោម៖

- **ប្រមូលទិន្នន័យនិងព័ត៌មានចាំបាច់សម្រាប់ធ្វើផែនការ៖** ការិយាល័យផ្គត់ផ្គង់ទឹកស្អាតជនបទត្រូវចាំបាច់ចុះប្រមូលទិន្នន័យ និងព័ត៌មានអំពីចំនួនប្រភពទឹកចំនួនប្រភពទឹកដែលខូចចំនួនប្រភពទឹកដែលអាចប្រើប្រាស់បាន និងព័ត៌មានចាំបាច់ផ្សេងៗទៀតនៅមូលដ្ឋានឱ្យបានទៀងទាត់ដើម្បីងាយស្រួលក្នុង ការធ្វើផែនការអភិវឌ្ឍន៍ឱ្យត្រូវនឹងតម្រូវការរបស់ប្រជាជន។
- **រៀបចំផែនការអភិវឌ្ឍន៍ខេត្ត និងថវិកាដែលពាក់ព័ន្ធ៖** ក្រោយពីការប្រមូលទិន្នន័យ ឬព័ត៌មានដែលចាំបាច់ និងកំណត់ផែនការអភិវឌ្ឍន៍រួមមកការិយាល័យផ្គត់ផ្គង់ទឹកស្អាតជនបទនឹងកំណត់គោលដៅសម្រាប់ ធ្វើការអភិវឌ្ឍមូលដ្ឋានដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួនដោយផ្អែកទៅលើកញ្ចប់ថវិការបស់ក្រសួងអភិវឌ្ឍន៍ជនបទ ឬកញ្ចប់ថវិកាដែលទទួលបានពីវិស័យឯកជនឬសប្បុរសជនផ្សេងៗប្រកបដោយតម្លាភាព និងប្រសិទ្ធិភាពបំផុត។
- **សម្របសម្រួលតាមដានត្រួតពិនិត្យនិងវាយតម្លៃគ្រប់កម្មវិធីនិងគម្រោងអភិវឌ្ឍន៍ជនបទ៖** ការិយាល័យផ្គត់ផ្គង់ទឹកស្អាតជនបទ គឺជាស្ថាប័នមួយដែលដើរតួជាអ្នកធ្វើការសម្របសម្រួលលើការងារផ្សេងៗ ព្រមទាំងមានតួនាទីជាអ្នកតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងាររបស់ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក និងអង្គការ ដៃគូអភិវឌ្ឍន៍ ឬវិស័យឯកជននានាដែលចូលរួមគាំទ្រលើការផ្គត់ផ្គង់ទឹកនៅក្នុងមូលដ្ឋានរបស់ខ្លួនផងដែរ ដើម្បី

ឱ្យធានាថាតើការអនុវត្តស្របតាមចក្ខុវិស័យការងាររបស់ខ្លួន ឬប្រសិទ្ធិភាពការងាររបស់ស្ថាប័នទាំងនោះទទួលបាន កម្រិតណា?

- **ផ្តល់ការគាំទ្រដល់សហប្រតិបត្តិការ និងការសម្របសម្រួលអន្តរនាយកដ្ឋាននៅក្នុងវិស័យសេវាផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទថ្នាក់ខេត្ត៖** ក្រៅពីអ្នកពាក់ព័ន្ធគាំទ្រលើវិស័យផ្គត់ផ្គង់ទឹកស្អាតជនបទការិយាល័យផ្គត់ផ្គង់ទឹកជនបទក៏បានបង្កើន និងគាំទ្រនូវរាល់កិច្ចសហប្រតិបត្តិការផ្សេងៗ ជាមួយនាយកដ្ឋាននានាដែលជាប់ពាក់ព័ន្ធផងដែរ។ ជាក់ស្តែង ការិយាល័យផ្គត់ផ្គង់ទឹកស្អាតខេត្តត្បូងឃ្មុំ ក៏បានធ្វើការសម្របសម្រួលជាអន្តរនាយកដ្ឋានជាមួយនាយកដ្ឋានមួយចំនួនផងដែរដូចជា នាយកដ្ឋានថែទាំសុខភាពជនបទ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ និងនាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទលើការងារពាក់ព័ន្ធមួយចំនួនផងដែរ។
- **ផ្តល់ការគាំទ្រដល់ការអភិវឌ្ឍវិស័យឯកជន ជាពិសេសការអភិវឌ្ឍវិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ៖** ក្រៅពីស្ថាប័នអង្គការ ដៃគូអភិវឌ្ឍន៍ យើងឃើញថា វិស័យឯកជនក៏បានដើរតួយ៉ាងសំខាន់ក្នុងដំណើរការផ្គត់ផ្គង់ទឹកស្អាតផងដែរ។ វិស័យឯកជនជាវិស័យមួយដែលមានឯករាជ្យ ដោយពឹងផ្អែកលើធនធានផ្ទាល់ខ្លួនក្នុងការវិនិយោគទុនផ្សេងៗ។ ដោយសារហេតុផល និងលក្ខខណ្ឌដ៏ប្រសើរនេះហើយទើបធ្វើឱ្យការិយាល័យផ្គត់ផ្គង់ទឹកស្អាតជនបទខេត្តត្បូងឃ្មុំ បានព្យាយាមប្រឹងប្រែងស្វែងរកនូវការគាំទ្រ ឬវិនិយោគទុនពីវិស័យឯកជន ដើម្បីជួយឱ្យដំណើរការផ្គត់ផ្គង់ទឹកស្អាតនៅក្នុងមូលដ្ឋានរបស់ខ្លួនទទួលបានលទ្ធផលគាប់ប្រសើរនិងស្របតាម ផែនការសកម្មភាពដែលបានកំណត់ទុករួចជាស្រេច។ ជាក់ស្តែង នៅក្នុងស្រុកត្បូងឃ្មុំយើងឃើញថាមានវិស័យឯកជនមួយចំនួនក៏បានចូលរួមវិនិយោគលើការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋមួយចំនួនផងដែរ។
- **ការស្វែងរកការគាំទ្រ៖** ដើម្បីឱ្យការផ្គត់ផ្គង់ទឹកស្អាតទទួលបានភាពល្អប្រសើរ និងអត្រានៃ ប្រជាជនដែលទទួលបានទឹកស្អាតប្រើប្រាស់មានការកើនឡើង ការិយាល័យផ្គត់ផ្គង់ទឹក ស្អាតជនបទ ក៏បានខិតខំស្វែងរកនូវការគាំទ្របន្ថែមពីគ្រប់វិស័យ មិនថាវិស័យឯកជន អង្គការ ដៃគូអភិវឌ្ឍន៍ ក៏ដូចជាសប្បុរសជននានាផងដែរ។

### ខ. មុខងារក្រោយពេលធ្វើប្រតិភូកម្មមុខងារ៖

ដោយយោងទៅតាមប្រការ ៥ នៃសេចក្តីប្រកាសរបស់ ក.អ.ជ លេខ០៤៣/១៥ ក.អ.ជ.ប្រក ចុះថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ ២០១៥ ស្តីពីការធ្វើប្រតិភូកម្មមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទជូនដល់ខេត្តត្បូងឃ្មុំ និងខេត្តកំពត យើងឃើញថា មន្ទីរអភិវឌ្ឍន៍ជនបទត្រូវទទួលខុសត្រូវលើការចាត់តាំងមន្ត្រីជំនាញ និងមន្ត្រីការិយាល័យអភិវឌ្ឍន៍ជនបទស្រុកដើម្បីជួយគាំទ្រផ្នែក បច្ចេកទេសដល់រដ្ឋបាលស្រុកគោលដៅក្នុងរយៈពេលអនុវត្តសាកល្បងនេះឱ្យបានជោគជ័យ។ ជាការពិតណាស់ ដើម្បីឱ្យដំណើរការអនុវត្តសាកល្បងលើការផ្ទេរមុខងារ

ដល់រដ្ឋបាលស្រុកទទួលបានភាពជោគជ័យ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ ក៏បានទទួលនូវតួនាទីថ្មីមួយទៀតផងដែរ ដោយត្រូវបង្កើតនូវ គណៈកម្មាធិការមួយដែលទទួលបន្ទុកលើការអនុវត្តសាកល្បងផ្ទេរមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកជនបទ។ ជាមួយគ្នានេះដែរ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ ក៏បានបង្កើតនូវរចនាសម្ព័ន្ធគណៈកម្មាធិការថ្មីនេះឡើងដោយបានចាត់តាំងអនុប្រធាន មន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ ឱ្យទទួលនូវមុខងារ ជាប្រធានគណៈកម្មាធិការទទួលបន្ទុកជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទខេត្តត្បូងឃ្មុំ និងបុគ្គលិកផ្សេងទៀតមកពីការិយាល័យផ្គត់ផ្គង់ទឹកស្អាតជាសមាជិក និងជាជំនួយការលើការងារជួសជុលនិងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ នៅក្នុងស្រុកគោលដៅទាំងបីនៃខេត្តត្បូងឃ្មុំនេះផងដែរ។ ក្នុងនាមជាអ្នកជំនួយគាំទ្រផ្នែកបច្ចេកទេសដល់រដ្ឋបាលស្រុកគោលដៅទាំងនោះ មន្ទីរអភិវឌ្ឍន៍ ក៏បាននឹងទទួលនូវមុខងារ និងការទទួលខុសត្រូវមួយចំនួនទៀតផងដែរ។ ខាងក្រោមនេះជាមុខងារដែលមន្ទីរអភិវឌ្ឍន៍នឹងធ្វើការទទួលខុសត្រូវ ក្រោយពេលមានការផ្ទេរមុខងារ៖

- ការជួសជុលអណ្តូងស្នប់ តូច ធំ តាមសំណើររបស់រដ្ឋបាលថ្នាក់ស្រុក
- ផ្តល់ការណែនាំបច្ចេកទេស ការងារប្រតិបត្តិ និងការងារគ្រប់គ្រងលើការថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកជនបទ ដល់រដ្ឋបាលស្រុក
- ផ្តល់ការណែនាំ លើការរៀបចំគម្រោង និងធ្វើផែនការថវិការដល់រដ្ឋបាលស្រុក
- ផ្តល់ការណែនាំ លើដំណើរការរៀបចំលទ្ធកម្ម សម្រាប់គ្រឿងបន្លាស់ និងសេវាជួសជុលអណ្តូងស្នប់
- កសាងសមត្ថភាពមន្ត្រីសាលាស្រុក លើការជួសជុលតូច និងធំ ការបង្កើតក្រុមអ្នកប្រើប្រាស់ទឹក ការធ្វើផែនការ និងប្រមូលទិន្នន័យ
- ផ្តល់ព័ត៌មានត្រឹមត្រូវមិនលំអៀងពីគ្រឿងបន្លាស់ និងអ្នកផ្តល់សេវាជួសជុលដែលមានបទពិសោធន៍ទៅថ្នាក់ស្រុក
- ផ្តល់ការណែនាំបច្ចេកទេស សេវាឯកទេស ឬឧបករណ៍ឯកទេសទៅសាលាស្រុកតាមការស្នើសុំរបស់រដ្ឋបាលស្រុក
- មានតួនាទីផ្តល់នូវការណែនាំយុទ្ធសាស្ត្រ និងជួយជម្រុញដល់ការអនុវត្តដោយផ្អែកតាមរបាយការណ៍ដែលខ្លួនបានទទួល និងផ្តល់នូវការត្រួតពិនិត្យមើលបច្ចេកទេសជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។
- រាយកាណ៍អំពីស្ថានភាពប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ និងរឿងទាក់ទងផ្សេងទៀតក្នុងខេត្តទៅ នាយកដ្ឋានផ្គត់ផ្គង់ទឹកស្អាតជនបទនៃក្រសួងអភិវឌ្ឍន៍ជនបទ។

តារាង ៤.៤. ប្រៀបធៀបមុខងារមុន និងក្រោយការធ្វើប្រតិភូកម្មរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ

| មុខងារចាស់ | មុខងារបន្ថែមថ្មី |
|---|---|
| • ប្រមូលទិន្នន័យ និងព័ត៌មានចាំបាច់សម្រាប់ធ្វើផែនការ<br>• រៀបចំផែនការអភិវឌ្ឍន៍ខេត្ត និងថវិកាដែលពាក់ព័ន្ធ<br>• សម្របសម្រួល តាមដានត្រួត ពិនិត្យនិងវាយតម្លៃគ្រប់កម្មវិធី និងគម្រោងអភិវឌ្ឍន៍ជនបទ<br>• ផ្តល់ការគាំទ្រដល់សហប្រតិបត្តិការ និងការសម្របសម្រួលអន្តរនាយកដ្ឋាន នៅក្នុងវិស័យសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទថ្នាក់ខេត្ត<br>• ផ្តល់ការគាំទ្រ ដល់ការអភិវឌ្ឍវិស័យឯកជន ជាពិសេសការអភិវឌ្ឍវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ<br>• ការស្វែងរកការគាំទ្រ។ | • ជួសជុលអណ្តូងស្នប់(ខូចធំ) តាមសំណើរ/កិច្ចសន្យាពីរដ្ឋបាលស្រុក<br>• ផ្តល់ការណែនាំបច្ចេកទេស ការងារប្រតិបត្តិ និងការងារគ្រប់គ្រងលើ ការថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ ដល់រដ្ឋបាលស្រុក<br>• ផ្តល់ការណែនាំ លើការរៀបចំគម្រោង និងធ្វើផែនការថវិការដល់រដ្ឋបាលស្រុក<br>• ផ្តល់ការណែនាំ លើដំណើរការរៀបចំលទ្ធកម្មសម្រាប់គ្រឿងបន្លាស់ និងសេវាជួសជុលអណ្តូងស្នប់<br>• កសាងសមត្ថភាពមន្ត្រីសាលាស្រុកលើការជួសជុលតូច និងធំការបង្កើតក្រុមអ្នកប្រើប្រាស់ទឹក ការធ្វើផែនការ និងប្រមូលទិន្នន័យ<br>• ពិនិត្យរបាយការណ៍និងបញ្ជីសារពើភ័ណ្ឌ ដែលរដ្ឋបាលស្រុកបានផ្តល់ជូននិងធ្វើការណែនាំបន្ថែមបើមាន<br>• រាយការណ៍ អំពីស្ថានភាពប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ និងរឿងទាក់ទងផ្សេងៗទៀតក្នុងខេត្តទៅនាយកដ្ឋានផ្គត់ផ្គង់ទឹកស្អាតជនបទនៃក្រសួងអភិវឌ្ឍន៍ជនបទ<br>• ផ្តល់ព័ត៌មានត្រឹមត្រូវ មិនលំអៀងពីគ្រឿងបន្លាស់ និងអ្នកផ្តល់សេវាជួសជុលដែលមានបទពិសោធន៍ទៅថ្នាក់ស្រុក<br>• ផ្តល់ការណែនាំបច្ចេកទេស សេវាឯកទេស ឬឧបករណ៍ឯកទេសទៅសាលាស្រុកតាមការស្នើសុំរបស់រដ្ឋបាលស្រុក<br>• មានតួនាទីផ្តល់នូវការណែនាំយុទ្ធសាស្ត្រ និងជួយជម្រុញដល់ការអនុវត្តដោយផ្អែកតាម |

| | |
|---|---|
| | របាយការណ៍ដែលខ្លួនបានទទួល និងផ្តល់នូវការត្រួតពិនិត្យមើលបច្ចេកទេសជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។ |

ដូចគ្នាទៅនឹងរដ្ឋបាលស្រុកត្បូងឃ្មុំ ដែរក្រោយពីទទួលបានសេចក្តីប្រកាសស្តីពីការធ្វើប្រតិភូកម្មមុខងារមក មន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ ក៏បានទទួលនូវមុខងារ និងការទទួលត្រូវមួយចំនួន ដែលវាជាបន្ទុកមួយថែមទៀតលើការអនុវត្តមុខងារចាស់ដែលមានពីមុនមកផងដែរ។ តាមរយៈមុខងារបន្ថែមថ្មី និងការបង្កើតគណៈកម្មាធិការមួយដែលទទួលបន្ទុកលើការអនុវត្តសាកល្បងផ្ទេរមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកជនបទនេះ យើងឃើញថា សមាសភាពនៃគណៈកម្មាធិការនេះត្រូវបានចាត់តាំងពីថ្នាក់ដឹកនាំ និងបុគ្គលិកពីការិយាល័យមួយចំនួនរបស់មន្ទីរដើម្បីអនុវត្តន៍លើមុខងារនេះ ដែលក្នុងនោះវាបណ្តាលឱ្យបញ្ហារាំងស្ទះដល់ដំណើរការការងារមួយចំនួននៅក្នុងអង្គភាព ដោយសារសមាសភាពនៃគណៈកម្មាធិការនេះ ត្រូវមានភារកិច្ចក្នុងការអនុវត្តលើតួនាទីរបស់ខ្លួនដែលមានស្រាប់ផង និងអនុវត្តតួនាទីលើមុខងារថ្មីនេះផង។ ថ្វីត្បិតតែគណៈកម្មាធិការនេះ ធ្លាប់មានបទពិសោធន៍យ៉ាងក្រាស់ក្រែលលើការងារជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកកន្លងមកមែន ប៉ុន្តែបើពិនិត្យមើលតាមស្ថានភាពជាក់ស្តែងយើងឃើញថា ទំហំនៃការទទួលខុសត្រូវរបស់ពួកគាត់គឺមានភាពធំទូលាយ និងដែនសមត្ថកិច្ចក្នុងការអនុវត្តមុខងារគឺមានភាពខុសគ្នាមួយចំនួនរវាងមុខងារចាស់ និងមុខងារថ្មីនេះ ដែលជាហេតុធ្វើឱ្យមានចន្លោះខ្វះខាតមួយចំនួនក្នុងពេលបំពេញមុខងារ និងជួនកាលក៏អាចធ្វើការងារមួយចំនួនមានភាពរាំងស្ទះផងដែរ។ ប៉ុន្តែទោះបីជាយ៉ាងនេះក្តី គណៈ កម្មាធិការនេះបានចូលរួមគាំទ្រយ៉ាងខ្នះខ្នែង លើផ្នែកបច្ចេកទេស និងជួយសម្រួលដល់ដំណើរការរដ្ឋបាលនានាដល់រដ្ឋបាលស្រុកគោលដៅទាំងបី ក្នុងការធ្វើឱ្យដំណើរការអនុវត្តលើមុខងារថ្មីនេះទទួលបានជោគជ័យ។ យ៉ាងណាមិញ តាមរយៈការចូលរួមជាមួយរដ្ឋបាលស្រុកគោលដៅ និងតាមរយៈសមិទ្ធផលដែលស្រុកទាំងនោះសម្រេចបាន យើងអាចសន្និដ្ឋានបានថា ការបង្កើតឡើងនូវគណៈកម្មាធិការសម្រាប់ជាជំនួយគាំទ្ររបស់មន្ទីរអភិវឌ្ឍន៍ជនបទ ពិតជាចូលរួម ក្នុងការធ្វើឱ្យការអនុវត្តនេះបានជោគជ័យពិតប្រាកដមែន។ ខាងក្រោមនេះជាតារាងបង្ហាញពីការអនុវត្តលើមុខងារចាស់ និងការទទួលបានមុខងារថ្មីបន្ថែមទៀតក្រោយការធ្វើប្រតិភូកម្មមុខងារ ព្រមទាំងតារាងបង្ហាញពីសមាសភាពរបស់គណៈកម្មាធិការទទួលបន្ទុកជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ នៃមន្ទីរអភិវឌ្ឍន៍ខេត្តត្បូងឃ្មុំផងដែរ។

តារាង ៤.៥. ភាពខុសគ្នារវាងការអនុវត្តលើមុខងារចាស់ និងមុខងារដែលបានបន្ថែមថ្មីរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ

| មុខងារចាស់ | មុខងារថ្មី |
|---|---|
| • គ្រប់គ្រង និងធ្វើផែនការអភិវឌ្ឍន៍ទូទៅលើការផ្គត់ផ្គង់ទឹកនៅក្នុងខេត្ត<br>• រៀបចំកញ្ចប់ថវិកាដូចដែលបានកំណត់នៅក្នុងផែនការ<br>• ត្រួតពិនិត្យ និងវាយតម្លៃលើគ្រប់គម្រោងលើវិស័យផ្គត់ផ្គង់ទឹក<br>• ធ្វើការជាអន្តរនាយកដ្ឋានដែលពាក់ព័ន្ធ<br>• គាំទ្រនិងស្វែងរកការគាំទ្រដល់វិស័យឯកជនក្នុងការវិនិយោគលើវិស័យផ្គត់ផ្គង់ទឹក។ | • ជួសជុលអណ្តូងក្នុងស្រុកគោលដៅទាំងបីតាមការស្នើសុំ<br>• ណែនាំនិងកសាងសមត្ថភាពផ្នែកបច្ចេកទេសលើការជួសជុល និងថែទាំដល់រដ្ឋបាលស្រុក<br>• ផ្តល់ព័ត៌មានពីអ្នកឯកទេស និងអ្នកផ្គត់ផ្គង់គ្រឿងបន្លាស់ដល់រដ្ឋបាលស្រុក។ |

តារាង ៤.៦. បង្ហាញពីសមាសភាពរបស់គណៈកម្មាធិការទទួលបន្ទុកជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ

| សមាសភាព | កម្រិតវប្បធម៌ |
|---|---|
| អនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ | បរិញ្ញាបត្រផ្នែកគ្រប់គ្រង (មានបទពិសោធន៍ ២១ឆ្នាំលើការជួសជុលផ្លូវ និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ) |
| ប្រធានការិយាល័យផ្គត់ផ្គង់ទឹកស្អាតជនបទខេត្តត្បូងឃ្មុំ | មានបទពិសោធន៍២០ឆ្នាំ លើការជួសជុលផ្លូវថ្នល់និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ ជាមួយអង្គការ ប្រាសាក់ យូនីសេព និងមន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ |
| ជំនួយការការិយាល័យផ្គត់ផ្គង់ទឹកស្អាត | បរិញ្ញាបត្រផ្នែកទឹកក្រោមដី |
| ប្រធានការិយាល័យជនជាតិភាគតិច | មានបទពិសោធន៍ច្រើនឆ្នាំលើការអនុវត្តការងារ។ |

## ៤.៤ ដំណើរការជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទរបស់រដ្ឋបាលស្រុកត្បូងឃ្មុំ

### ៤.៤.១ ប្រៀបធៀបពីរយៈពេលនៃដំណើរការស្នើសុំជួសជុលនៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត

ក្នុងដំណើរការជួសជុលអណ្តូងទឹកសហគមន៍មុនពេលមិនទាន់ផ្ទេរមុខងារ និងដំណើរការជួសជុលអណ្តូងទឹកសហគមន៍ ក្រោយពេលផ្ទេរមុខងារគឺមានលក្ខណៈខុសគ្នា បើយោងទៅតាមដំណាក់កាលនីមួយៗ និងរយៈពេលនៃការអនុវត្តក្នុងដំណាក់កាលទាំងនោះ។ ចំពោះ **ដំណើរការក្នុងការជួសជុលអណ្តូងសហគមន៍មុនពេលមិនទាន់ផ្ទេរមុខងារ** គឺមានចំនួន **៤ ដំណាក់កាល** ដែលក្នុងដំណាក់កាលទាំង ៤នេះគឺប្រើរយៈពេលសរុប**៦ខែ** ហើយត្រូវបានអនុវត្តន៍ផ្ទាល់ពីខាងមន្ទីអភិវឌ្ឍន៍ជនបទ។ **ដំណាក់កាលទី១ គឺសំណើរអណ្តូងដែលត្រូវជួសជុល** ៖ ក្នុងដំណាក់កាលនៃសំណើរអណ្តូងដែលត្រូវជួសជុលគឺចំណាយរយៈពេលសរុប៣ខែ ដែលធ្វើការស្នើសុំ ពីក្រុមអ្នកប្រើប្រាស់ទឹកទៅគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ បន្ទាប់មកទៀត គណៈកម្មាធិការអភិវឌ្ឍន៍ភូមិនីមួយៗមានសំណើរ ដែលត្រូវបានស្នើពីក្រុមអ្នកប្រើប្រាស់ទឹកទាំងនោះ ធ្វើបញ្ជីរបាយការណ៍ និងធ្វើការបញ្ជូនបន្តទៅក្រុមប្រឹក្សាឃុំ ក្នុងការត្រួតពិនិត្យ។ ក្រោយមកទៀត ប្រធានក្រុមប្រឹក្សាឃុំបញ្ជូនសំណើរឡើងបន្តទៅខាងមន្ទីអភិវឌ្ឍន៍ជនបទ។ មន្ទីអភិវឌ្ឍន៍ជនបទបានដាក់សំណើរនៃចំនួនអណ្តូងខូច ដែលបានស្នើទៅក្នុងបញ្ជីផែនការអភិវឌ្ឍន៍វិស័យផ្គត់ផ្គង់ទឹកស្អាតជនបទ រួចបញ្ជូនទៅនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទនៃក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីធ្វើការត្រួតពិនិត្យរបាយការណ៍បន្ទាប់មកទៀតនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទបញ្ជូនសំណើរដែលស្នើនោះទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីផ្ទេរកញ្ចប់ថវិការ ទៅឲ្យមន្ទីរអភិវឌ្ឍន៍ជនបទវិញ។ ក្រោយពីទទួលបានការផ្ទេរថវិការ ពីខាងនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ មន្ទីរអភិវឌ្ឍន៍ជនបទ បានចាប់ផ្តើមបន្តចូលដំណាក់ការទី២។ **ដំណាក់កាលទី២ គឺសិក្សាពីទំហំស្ថានភាពខូចខាតនៃអណ្តូង**ដែលចំណាយរយៈពេលសរុប ៣០ថ្ងៃ ក្នុងដំណាក់កាលទី២នេះ ចែកចេញជាពីរជំហាន។ ជំហានទីមួយ គឺខាងមន្ទីរចុះធ្វើការត្រួតពិនិត្យស្ថានភាពជាក់ស្តែងនៃអណ្តូងដែលខូចខាត។ ជំហានទីពីរ គឺធ្វើការប្រមូលទិន្នន័យ។ **ដំណាក់កាលទី៣ គឺប្រជុំជ្រើសរើសតំបន់អទិភាព** ដែលចំណាយរយៈពេលសរុប ១សប្តាហ៍ ហើយចែកចេញជាពីរជំហាន។ ជំហានទីមួយ គឺត្រូវពិនិត្យលើតម្រូវការអទិភាព ដែលយោងទៅតាមគោលការណ៍នៃដំណាក់កាលទី១ និងដំណាក់កាលទី២(សំណើរជាក់ស្តែង និងទំហំជាក់ស្តែងនៃស្ថានភាពខូច)។ ជំហានទីពីរ គឺជ្រើសរើសតំបន់ដែលមានតម្រូវការអទិភាពច្រើនជាងគេ។ ដំណាក់កាលចុងក្រោយ **គឺដំណាក់កាលទី៤ ការជួសជុលជាសាធារណៈ** ដែលដំណាក់ការនៃការជួសជុលគឺចំណាយរយៈពេល២ខែ។ ខាងក្រុមបច្ចេកទេសរបស់មន្ទីរចុះធ្វើការជួសជុលអណ្តូងតាមតំបន់គោលដៅ ដែលជ្រើសរើសនៅដំណាក់កាលទី៣ដែលក្នុងនោះក៏មានការចូលរួមជួយពីមន្ត្រីខាង ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក និងក្រុមអ្នកប្រើប្រាស់ទឹកផងដែរ។ ចំនែកឯដំណើរការនៃការជួសជុលអណ្តូងសហគមន៍ ក្រោយពេលអនុវត្តន៍ការផ្ទេរមុខងារមាន៥ដំណាក់កាល

សំខាន់ៗ ដែលមានតាំងពីការស្នើសុំការជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹក ពីសំណាក់ក្រុមអ្នកប្រើប្រាស់ទឹករហូតដល់ដំណាក់កាលនៃការជួសជុលជាសាធារណៈនៃក្រុមហ៊ុន ដែលទទួលបានសិទ្ធិក្នុងការជួសជុល ដែលចំណាយរយៈពេលសរុបក្នុង៥ ដំណាក់កាលត្រឹមតែ**៣ខែ** ប៉ុណ្ណោះ និងត្រូវបានអនុវត្តផ្ទាល់ពីខាងរដ្ឋបាលស្រុក។ ជាក់ស្តែង បើយើងរៀបរាប់ឲ្យលម្អិតនៃដំណើរការ យើងឃើញថា **ដំណាក់កាលទី១ គឺជាដំណាក់កាលនៃការធ្វើការស្នើសុំការជួសជុល** ដោយចាប់ផ្តើមចេញពីការស្នើឡើងពីក្រុមអ្នកប្រើប្រាស់ទឹក ទៅគណៈកម្មាធិការអភិវឌ្ឍន៍ភូមិបន្ទាប់មកទៀត គណៈកម្មាធិការអភិវឌ្ឍន៍ភូមិនីមួយៗដែលមានសំណើរសុំពីក្រុមអ្នកប្រើប្រាស់ទឹកទាំងនោះ ត្រូវធ្វើបញ្ជីរបាយការណ៍នឹងធ្វើការបញ្ជូនបន្តទៅក្រុមប្រឹក្សាឃុំ ក្នុងការត្រួតពិនិត្យ។ ក្រោយពីការត្រួតពិនិត្យលើសំណើរសុំពីសំណាក់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិដែលជាតំណាងប្រជាជនរួចមក ប្រធានក្រុមប្រឹក្សាឃុំ នឹងបញ្ជូនសំណើនោះផ្ទាល់ទៅកាន់រដ្ឋបាលស្រុកដើម្បីត្រួតពិនិត្យ នឹងចុះមកធ្វើការសិក្សាមុននឹងការជួសជុល ដោយជារួមនៅក្នុងដំណាក់កាលនេះត្រូវការចំណាយរយៈពេល ១សប្តាហ៍ដើម្បីស្នើសុំនេះ។ នៅក្នុង**ដំណាក់កាលទី២ គឺសិក្សាពីទំហំឬស្ថានភាពជាក់ស្តែងនៃការខូចខាតនៃប្រភពទឹកនីមួយៗ៖** យើងឃើញថា ក្រោយពីទទួលបានការស្នើសុំពីសំណាក់ក្រុមប្រឹក្សាឃុំរួចមក រដ្ឋបាលស្រុកដែលមានប្រធានក្រុមការងារជួសជុល និងថៃទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទជាតំណាង នឹងចុះទៅធ្វើការសិក្សាពីទំហំឬស្ថានភាពជាក់ស្តែងនៃការខូចខាតនៃប្រភពទឹកនីមួយៗ ដោយមានការចូលរួមជួយគាំទ្រពីសំណាក់មន្ត្រី បច្ចេកទេសពីមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ចំណែកឯរយៈពេលនៃការចុះទៅធ្វើការត្រួតពិនិត្យ/ប្រមូលទិន្នន័យនេះ គឺត្រូវចំណាយរយៈពេល ១សប្តាហ៍ដូចគ្នា។ បន្ទាប់មកទៀតនៅក្នុង**ដំណាក់កាលទី៣ គឺប្រជុំគណៈអភិបាលដើម្បីធ្វើការជ្រើសរើសឃុំអទិភាព៖** ក្រោយពីការចុះសិក្សាពីទំហំ/ស្ថានភាព នៃការខូចខាតជាក់ស្តែងរួមមក រដ្ឋបាលស្រុកនឹងធ្វើការប្រជុំគណៈអភិបាលស្រុក ដើម្បីធ្វើការជ្រើសរើសនូវឃុំដែលមានអទិភាពក្នុងការជួសជុល ហើយការជ្រើសរើសយកឃុំដែលមានអទិភាពនោះ គឺឈរទៅលើលក្ខណៈវិនិច្ឆ័យចំនួន២ធំៗ គឺទី១ សំណើរសុំជាក់ស្តែងពីក្រុមប្រឹក្សាឃុំ នូវតម្រូវការចាំបាច់របស់ប្រជាជន និងទី២ គឺផ្អែកទៅលើការចុះទៅសិក្សា ត្រួតពិនិត្យមើលស្ថានភាពខូចខាត និងតម្រូវការប្រើប្រាស់ជាក់ស្តែងរបស់ប្រជាជន។ ដូចគ្នានេះដែរ នៅក្នុងដំណាក់កាលទី៣នេះ ក៏ត្រូវចំណាយរយៈពេល ១សប្តាហ៍ដូចគ្នា ក្នុងការសម្រេចចិត្តជ្រើសរើសយកឃុំដែលមានអទិភាព មុនពេលធ្វើការដាក់ដេញថ្លៃលើការជួសជុល។ នៅក្នុង**ដំណាក់កាលទី ៤នេះ គឺជាដំណាក់កាលនៃការដេញថ្លៃពី**សំណាក់ក្រុមហ៊ុនមួយចំនួន។ នៅក្នុងដំណើរនៃការដេញថ្លៃ គឺមានលក្ខណៈខុសគ្នាមួយចំនួនអាស្រ័យទៅលើប្រភេទនៃលទ្ធកម្ម។ ក្នុងដំណើរការនៃលទ្ធកម្មគឺបែកចែកចែកជាបីប្រភេទ ដែលចំណាយរយៈពេលខុសគ្នាអាស្រ័យតាមប្រភេទផងដែរ។ ក្នុងតារាង ៤.៧ នឹងរៀបរាប់លម្អិតពីប្រភេទនៃលទ្ធកម្មទាំងនោះ។ **ជាចុងបញ្ចប់ គឺដំណាក់កាលទី៥ នៃការជួសជុលជាសាធារណៈ៖**

ក្រោយពីទទួលបានសិទ្ធិ ក្នុងដេញថ្លៃព្រមទាំងការចុះទៅសិក្សាពីគុណសម្បត្តិរបស់ក្រុមហ៊ុន ដែលទទួលបានការដេញថ្លៃ ពីសំណាក់រដ្ឋបាលស្រុកត្បូងឃ្មុំនិងមន្រ្តីបច្ចេកទេសពីមន្ទីរ-អភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំរួចមកក្រុមហ៊ុន ដែលទទួលសិទ្ធិក្នុងការដេញថ្លៃនឹងចុះទៅធ្វើការជួសជុលអណ្តូងជាសាធារណៈ ដោយមានការចូលរួមត្រួតពិនិត្យ និងវាយតម្លៃការងារពីអ្នកពាក់ព័ន្ធមួយចំនួនដូចជា ក្រុមការងារទទួលបន្ទុកជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទនៃរដ្ឋបាលស្រុកត្បូងឃ្មុំ គណៈកម្មាធិការទទួលបន្ទុកជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទនៃមន្ទីរអភិវឌ្ឍន៍ខេត្តត្បូងឃ្មុំ អាជ្ញាធរមូលដ្ឋាន និងប្រជាជនមួយចំនួនទៀតផងដែរ។ ដូចគ្នានេះដែរ នៅក្នុងដំណាក់កាលនៃការជួសជុលនេះ ត្រូវចំណាយពេលវេលាអាចចាប់ពី១៥ ទៅ ៣០ថ្ងៃ អាស្រ័យទៅដោយចំនួន និងទំហំនៃការខូចខាតរបស់ប្រព័ន្ធផ្គត់ផ្គង់ទឹកទាំងនោះ។ បន្ថែមពីនេះទៀត សម្រាប់កិច្ចសន្យានៃការជួសជុលដេញថ្លៃ គឺក្រុមហ៊ុននឹងធ្វើការធានានូវការជួសជុលចំនួន៦ខែ ទៅលើប្រព័ន្ធផ្គត់ផ្គង់ទឹកដែលខ្លួនបានជួសជុល ប៉ុន្តែរយៈពេលនេះ មិនរាប់បញ្ចូលទៅក្នុងដំណើរការនៃការជួសជុលទេ។ ជារួម នៅក្នុងដំណើរការនៃការជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទនៅក្នុងស្រុកត្បូងឃ្មុំនេះ គឺត្រូវប្រើប្រាស់រយៈពេលឆាប់បំផុតចាប់ពី៣ខែ នឹងយូរបំផុតគឺ៤ខែ ជាកំហិត។

ខាងក្រោមនេះជាដ្យាក្រាមដែលបង្ហាញពី ដំណើរការជួសជុលអណ្តូងសហគមន៍នៅមុនពេលមិនទាន់អនុវត្តន៍ការផ្ទេរមុខងារ និងក្រោយពេលផ្ទេរមុខងារសាកល្បង៖




ដ្យាក្រាម ៤.៤. ដំណើរការជួសជុលអណ្តូងសហគមន៍របស់មន្ទីរអភិវឌ្ឍន៍ជនបទ




ដ្យាក្រាម ៤.៥. ដំណើរការជួសជុលអណ្តូងសហគមន៍របស់រដ្ឋបាលស្រុក

**នៅក្នុងដំណាក់កាលទី៤** ដំណាក់កាលនៃការដេញថ្លៃពីសំណាក់ក្រុមហ៊ុនមួយចំនួន។ នៅក្នុងដំណើរនៃការដេញថ្លៃ ត្រូវបានបែងចែកជា ២ប្រភេទ គឺប្រភេទគម្រោងតូច ដែលមានចំនួនទឹកប្រាក់ចាប់ពី ១០លានរៀលទៅ ២០លានរៀល នឹងត្រូវការរយៈពេលនៃការដេញថ្លៃចំនួន៥២ថ្ងៃទៅ២ខែ។ ចំណែកឯប្រភេទគម្រោងធំ គឺចាប់ពីទឹកប្រាក់ ២០លានរៀន រហូតដល់ ១០០លានរៀល ដោយដំណើរការនេះត្រូវចំណាយរយៈពេលចំនួន៣ខែ។ ជាក់ស្តែងនៅក្នុងស្រុកត្បូងឃ្មុំដោយសារកញ្ចប់ថវិការសម្រាប់ការជួសជុលមានកម្រិតទាប ( ៩,១៧០,០០០ រៀល) គឺត្រូវបានចាត់ចូលទៅក្នុងប្រភេទនៃការដេញថ្លៃគម្រោងតូច ដែលការដេញថ្លៃនេះត្រូវចំណាយរយៈពេលសរុបចំនួន២ខែ ក្នុងនេះ ត្រូវបានបែងចែកទៅតាមដំណាក់កាលផ្សេងៗគ្នាដោយទី១ ការប្រកាសដេញថ្លៃត្រូវចំណាយរយៈពេល១៥ថ្ងៃជាកំហិត ទី២ ការចុះបញ្ជីក្រុមហ៊ុនដេញថ្លៃ ដែលត្រូវចំណាយរយៈពេល ១៥ថ្ងៃដូចគ្នា និងទី៣ ដំណាក់កាលនៃការ ស្នង់តម្លៃ ការដេញថ្លៃ និងការចុះកិច្ចសន្យាទទួលខុសត្រូវក្នុងការជួសជុល ដែលដំណាក់ការនេះត្រូវប្រើប្រាស់ពេលវេលាចំនួន៣០ថ្ងៃ មុននឹងការចុះទៅធ្វើការជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកដែលមានការខូចខាត ពីសំណាក់ក្រុមហ៊ុនដែលទទួលបានសិទ្ធិក្នុងការជួសជុល។ ជាចុងបញ្ចប់ គឺដំណាក់កាលនៃការជួសជុលជាសាធារណៈ។

តារាង៤.៧. ប្រភេទនៃលទ្ធកម្ម

| **ប្រភេទនៃលទ្ធកម្ម** | **ថវិការ (លានរៀល)** | **រយៈពេល (ថ្ងៃ)** |
|---|---|---|
| ប្រភេទគម្រោងតូច | ១០ ទៅ ២០ | ៦០ |
| ប្រភេទគម្រោងធំ | ២០ ទៅ ១០០ | ៩០ |

### ៤.៤.២ ភាពខ្លាំងនៃដំណើរការជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹក

ភាពខ្លាំងនៃប្រព័ន្ធគោលនយោបាយនេះត្រូវបានគេឃើញថាមាន ៧ចំណុចធំៗមាន៖

- **បង្វិតការសម្រេចចិត្តនៅកៀកប្រជាជនៈ** នៅក្នុងដំណើរការនៃការផ្ទេរមុខងារជូនរដ្ឋបាលថ្នាក់ក្រោមជាតិ បានធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិអំណាច ក្នុងការចាត់ចែងគ្រប់គ្រងលើការជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅក្នុងមូលដ្ឋានរបស់ខ្លួន និងបំពេញតាមតម្រូវការរបស់ប្រជាជនបានច្បាស់លាស់ ដោយសាររដ្ឋបាលថ្នាក់ក្រោមជាតិគឺជាស្ថាប័នដែលនៅផ្ទាល់នឹងប្រជាពលរដ្ឋ និងអាចដឹងពីតម្រូវការចាំបាច់របស់ពួកគាត់ផ្ទាល់តែម្តង។ ដូច្នេះ រាល់ការសម្រេចចិត្តនានារបស់រដ្ឋបាលថ្នាក់ក្រុមជាតិ គឺពិតជាអាចបំពេញនូវតម្រូវការចាំបាច់របស់ប្រជាជនពិតប្រាកដមែន។
- **កាត់បន្ថយការិយាល័យធិបតេយ្យៈ** ការផ្ទេរមុខងារនេះគឺអាចនឹងធ្វើឱ្យមានការកាត់បន្ថយការិយាល័យធិបតេយ្យ ហើយរាល់ដំណើរការទាំងអស់គឺត្រូវបានធ្វើឡើងនៅនឹងមូលដ្ឋានផ្ទាល់តែម្តង ដោយពុំស្វះឆ្លងកាត់នូវការសម្រេចចិត្តច្រើនដំណាក់កាលដូចពីមុន។

- **បង្រួញខ្សែគណនេយ្យភាព:** ការបង្រួញខ្សែគណនេយ្យភាពត្រូវបានកើតឡើងនៅពេលដែលមានការផ្ទេរអំណាចជូនរដ្ឋបាលថ្នាក់ក្រោមជាតិ។ គណនេយ្យភាពក្នុងន័យនេះត្រូវបានសំដៅទៅលើការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធនីមួយៗ ទៅលើការងារដែលខ្លួនបានធ្វើ។ ជារួមមានន័យថា ដំណើរការនេះបានកាត់បន្ថយនូវខ្សែនៃការទទួលខុសត្រូវរបស់ខ្លួន ដោយមុនពេលនៃការផ្ទេរមុខងារ គឺខ្សែគណនេយ្យភាពនេះត្រូវបានធ្វើឡើងតាំងពីក្រុមប្រឹក្សាឃុំ រហូតដល់ក្រសួងអភិវឌ្ឍន៍ជនបទ ប៉ុន្តែក្រោយពេលផ្ទេរមុខងារ គឺខ្សែគណនេយ្យភាពត្រូវបានកាត់បន្ថយនៅត្រឹមតែរដ្ឋបាលស្រុកតែប៉ុណ្ណោះ ដែលនេះជាមូលហេតុដែលនាំឱ្យដំណើរការនៃការជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទកាន់តែមានភាពល្អប្រសើរ និងឆាប់រហ័សជាងមុន។
- **ការបែងចែកការទទួលខុសត្រូវ ដាច់ពីគ្នា:** ដោយសារនៅក្នុងដំណើរការនៃការផ្ទេរមុខងារនេះទាមទារឱ្យមន្ត្រីដែលទទួលបន្ទុកមានជំនាញ និងបទពិសោធន៍ច្រើនលើការងារ ដូច្នេះដំណើរការការងារទាំងនោះត្រូវបានបែងចែកទៅតាមភារកិច្ច តួនាទី និងជំនាញរបស់ខ្លួន។
- **ការរៀបចំផែនការកាន់តែទទួលបានផលប្រយោជន៍ខ្ពស់** មានទំនាក់ទំនងគ្នា និងសម្របសម្រួលគ្នាក្នុងចំណោមវិស័យពាក់ព័ន្ធនានា។
- **ការបន្ថែមធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ**តាមរយៈមូលនិធិផ្ទេរគ្មានលក្ខខណ្ឌ ដើម្បីអនុវត្តមុខងារ។
- **ជម្រុញបរិមាណគុណភាពនិងការផ្តល់សេវាកម្មសាធារណៈ**ឱ្យកាន់តែប្រសើរឡើង។

### ៤.៤.៣ ភាពខ្សោយនៃដំណើរការជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹក

ភាពខ្សោយនៃប្រព័ន្ធថ្មីនេះត្រូវបានកត់សម្គាល់ឃើញថាមានដូចជា៖

- **ត្រូវការហិរញ្ញវត្ថុជាកត្តាសំខាន់សម្រាប់ដំណើរការប្រព័ន្ធ:** ដោយសារប្រព័ន្ធនៃការផ្ទេរមុខងារនេះគឺធ្វើការផ្ទេរនូវធនធានសំខាន់ពីរដែលក្នុងនោះរួមមាន ការផ្ទេរធនធានហិរញ្ញវត្ថុ និងការផ្ទេរធនធានមនុស្ស។ ជាក់ស្តែងការជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកនោះក៏អាចធ្វើឡើងបាននៅពេលដែលរដ្ឋបាលស្រុកមានកញ្ចប់ថវិកានៅក្នុងដៃដែរ។ នេះអាចបញ្ជាក់បានថាប្រសិនបើគ្មានថវិការនៅក្នុងដៃរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏មិនអាចធ្វើឱ្យដំណើរការនេះដើរទៅបានដូចគ្នា ដែលអាចធ្វើឱ្យប្រព័ន្ធគោលនយោបាយនេះមិនទទួលបានភាពជោគជ័យ និងមិនមាននិរន្តរភាព។
- **តម្រូវការធនធានមនុស្ស:** ដោយសារការផ្ទេរមុខងារនេះជាការអនុវត្តសាកល្បងដែលជាហេតុធ្វើឱ្យមានតម្រូវការបង្កើតនូវក្រុមការងារមួយ ដើម្បីទទួលបន្ទុកលើការងារផងដែរ។ ជាក់ស្តែង ក្រុមការងារដែលបង្កើតបានគឺគ្រាន់តែមានតែឈ្មោះតែប៉ុណ្ណោះ តែពុំមានបុគ្គលិកក្នុងការអនុវត្តពេញលេញទេ។ ម្យ៉ាងទៀត ដោយសារសមាសភាពនៃក្រុមការងារទទួលបន្ទុកទាំងនោះ ពុំមានជំនាញគ្រប់គ្រាន់លើការងារជួសជុល និងថែទាំ

ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទពីមុនមកទេ ដែលនេះតម្រូវឱ្យមានការចាត់តាំងបុគ្គលិកផ្សេងទៀតដែលមានជំនាញ ច្បាស់លាស់លើការងារទាំងនោះសម្រាប់ការទទួលបន្ទុកការងារថ្មីនេះជាចាំបាច់ នៅពេលដែលគម្រោងអនុវត្តសាកល្បងនេះទទួលបានជោគជ័យ និងបានដាក់ចេញឱ្យអនុវត្តន៍ពេញលេញ។

- **តម្រូវការធនធានបច្ចេកទេស:** ការងារជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជាការងារដែលផ្អែកលើការងារបច្ចេកទេស ដូច្នេះរាល់មន្ត្រីក្រុមការងារទទួលបន្ទុកទាំងអស់ត្រូវតែមានចំណេះដឹង ចំនាញ និងបទពិសោធន៍គ្រប់គ្រាន់ដើម្បីធ្វើការដំណើរការការងារកាន់តែមានភាពរលូន និងទទួលបានជោគជ័យ។ ជាក់ស្តែងនៅក្នុងប្រព័ន្ធនៃការផ្ទេរមុខងារថ្មីនេះគឺពុំបានផ្ទេរនូវមន្ត្រីដែលមានចំនាញ និងបទពិសោធន៍ច្បាស់លាស់សម្រាប់ការអនុវត្តនៅឡើយទេ ដោយរាល់ដំណើរការការងារបច្ចេកទេសទាំងអស់ ត្រូវពឹងផ្អែកលើការគាំទ្រពីមន្ត្រីមន្ទីរអភិវឌ្ឍន៍នៅឡើយទេ ដែលជាហេតុអាចធ្វើឱ្យដំណើរការការងារមួយចំនួនអាចនឹងមានភាពរាំងស្ទះ និងមានភាពយឺតយ៉ាវដល់ការងារស្ទួលមួយចំនួន។
- **ពុំបានកំណត់នូវ គម្រោងពេលវេលា (Timeframe) ឱ្យបានច្បាស់លាស់:** រាល់ដំណើរការនៃការជួលជុលនីមួយៗពុំបានកំណត់ពេលវេលាច្បាស់លាស់ទេ ដោយដំណើរការនោះមានសកម្មភាពការងារនៅពេលតែមានថវិការប្រើប្រាស់តែប៉ុណ្ណោះ។

### ៤.៤.៤ ឱកាសនៃដំណើរការជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹក

មានឱកាសមួយចំនួន ដែលអាចធ្វើប្រព័ន្ធនៃការផ្ទេរមុខងារថ្មីនេះទទួលបានភាពជោគ-ជ័យ។ ឱកាសទាំងនោះមានដូចជា:

- **អាចបង្កើនជំនាញ និងបច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិ:** ដោយសារការផ្ទេរមុខងារដល់រដ្ឋបាលថ្នាក់ក្រោមជាតិជាអ្នកអនុវត្តន៍ការងារ ដូច្នេះរដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវទទួលបានការបណ្តុះបណ្តាលជំនាញ និងបច្ចេកទេសផ្សេងៗ ស្តីពីការជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ដែលអាចធ្វើឱ្យពួកគាត់មានចំណេះដឹង និងសមត្ថភាពកាន់តែទូលំទូលាយជាងមុន។
- **អាចធ្វើឱ្យមានគណនេយ្យភាពក្នុងការបែងចែងការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ អាចបង្កើនការចូលរួម កិច្ចសហប្រតិបត្តិការគ្នារវាងរដ្ឋបាលមូលដ្ឋាន និងប្រជាពលរដ្ឋ និងម្ចាស់ជំនួយ:** នៅក្នុងដំណើរការនៃការផ្ទេរមុខងារនេះទាមទារឱ្យមានការចូលរួមជាចាំបាច់រវាងអ្នកពាក់ព័ន្ធមួយចំនួន។ ដោយសារតែដំណើរការនេះត្រូវបានអនុវត្តន៍ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយរដ្ឋបាលថ្នាក់ក្រោមជាតិពុំទាន់មានចំណេះដឹងជំនាញឬបច្ចេកទេសក្នុងដំណើរជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទេ ដែលជាហេតុធ្វើឱ្យរដ្ឋបាលថ្នាក់ស្រុកត្រូវការការចូលរួម គាំទ្រ និងផ្តល់ជាជំនួយបច្ចេកទេសផ្សេងៗពីស្ថាប័ន

មួយចំនួនផងដែរ ដែលនេះធ្វើឱ្យកិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ កាន់តែមានភាពល្អប្រសើរជាមួយស្ថាប័នទាំងនេះថែមទៀតផង។ ម្យ៉ាងទៀត ដោយសាររដ្ឋបាលថ្នាក់ក្រោមជាតិត្រូវចុះទៅធ្វើការសិក្សាពីស្ថានភាពនៃប្រព័ន្ធផ្គត់ផ្គង់ទឹក ការជួសជុល និងសិក្សាពីតម្រូវការរបស់ប្រជាជន ដោយផ្ទាល់ផងនេះ ជាហេតុអាចធ្វើឱ្យដំណើរការនៃកិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋក្នុងមូលដ្ឋាន ក៏កាន់តែមានភាពជិតស្និទ្ធ និងល្អប្រសើរផងដែរ។

### ៤.៤.៥ ភាពប្រឈមលើដំណើរការអនុវត្តការផ្ទេរមុខងារ

ភាពប្រឈមរបស់ប្រព័ន្ធគោលនយោបាយថ្មីនេះមានដូចជា:

- **ភាពយឺតយ៉ាវនៃការរៀបចំសេចក្តីសម្រេចរួមនិងនីតិវិធីនៃកិច្ចដំណើរការរៀបចំត្រូវចំណាយពេលច្រើន:**ដោយសារការធ្វើប្រតិភូកម្មមុខងារទៅឱ្យរដ្ឋបាលថ្នាក់ជាតិ ជាគោលនយោបាលថ្មី ដូច្នេះរាល់ដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តរួមគ្នា និងដំណើរការនៃការចាត់តាំង ជ្រើសរើសក្រុមការងារទទួលបន្ទុកគឺនៅមានភាពស្មុគស្មាញ និងស៊ាំញ៉ាំ ដែលជាមូលហេតុមួយដែលធ្វើឱ្យដំណើរការសម្រាប់ការអនុវត្តមានភាពយឺតយ៉ាវ។
- **ក្រុមការងាររបស់ក្រសួង និងស្ថាប័នដែលពាក់ព័ន្ធមានភាពមមាញឹកនឹងការងារស្នូលរបស់ខ្លួន:** ក្រោយពីការបង្កើតឱ្យមានការធ្វើតិភូកម្មមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទជូនរដ្ឋបាលថ្នាក់ក្រោមជាតិរួចមក បានធ្វើឱ្យគ្រប់ស្ថាប័នដែលមានការពាក់ព័ន្ធមានភាពមមាញឹកកាន់តែខ្លាំង ពីព្រោះស្ថាប័នទាំងនោះត្រូវមានភារកិច្ច និងទទួលខុសត្រូវលើមុខងារចាស់របស់ខ្លួនផង និងត្រូវទទួលខុសត្រូវលើការអនុវត្តមុខងារថ្មីដែលទទួលបានផង ដែលជាហេតុអាចធ្វើឱ្យដំណើរការការងារមានភាពយឺតយ៉ាវ។
- **យន្តការនៃការផ្ទេរធនធានមនុស្សនិងហិរញ្ញវត្ថុមានភាពយឺតយ៉ាវ:** ដោយសារតែប្រព័ន្ធនៃការធ្វើប្រតិភូកម្មថ្មីនេះ គឺធ្វើការផ្ទេរតែធនធានសំខាន់ៗពីរគឺ ធនធានមនុស្សនិងធនធានហិរញ្ញវត្ថុ ដូច្នេះប្រសិនបើដំណើរការផ្ទេរធនធានទាំងនេះមានភពយឺតយ៉ាវនោះវាអាចនឹងធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំង ដល់ដំណើរការប្រព័ន្ធទាំងមូលដែលអាចធ្វើឱ្យដំណើរការនៃការអនុវត្តការធ្វប្រតិភូកម្មមុខងារដលរដ្ឋបាលថ្នាក់ក្រោមជាតិនេះមានភាពរាំងស្ទះ និងមិនទទួលបានភាពជោគជ័យ។

តារាង ៤.៨. តារាងវិភាគ SWOT នៃការធ្វើប្រតិភូកម្មមុខងារជូនរដ្ឋបាលថ្នាក់ក្រោមជាតិ

| ផលប៉ះពាល់ក្នុង | | ផលប៉ះពាល់ក្រៅ | |
|---|---|---|---|
| **ភាពខ្លាំង** | **ភាពខ្សោយ** | **ឱកាស** | **ភាពប្រឈម** |
| • បង្កិតការសម្រេចចិត្តនៅកៀកប្រជាជន<br>• កាត់បន្ថយការិយាល័យធិបតេយ្យ<br>• បង្រួញខ្សែគណនេយ្យភាព<br>• ការបែងចែកការទទួលខុសត្រូវដាច់ពីគ្នា<br>• ការរៀបចំផែនការ កាន់តែទទួលបានផលប្រយោជន៍ខ្ពស់ មានទំនាក់ទំនងគ្នានិងសម្របសម្រួលគ្នា ក្នុងចំណោមវិស័យ ពាក់ព័ន្ធនានា<br>• បន្ថែមធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈមូលនិធិផ្ទេរ គ្មានលក្ខខណ្ឌ ដើម្បីអនុវត្តន៍មុខងារ<br>• ជម្រុញបរិមាណគុណភាពនិងការផ្តល់សេវាកម្មសាធារណៈឱ្យកាន់តែប្រសើរឡើង។ | • ពុំបានកំណត់នូវ គម្រោងពេលវេលា (timeframe) ឱ្យបានច្បាស់លាស់<br>• ហិរញ្ញវត្ថុជាកត្តាសំខាន់ (ចំនួននៃការជួសជុលអណ្តូង អាស្រ័យទៅនឹងថវិកាដែលមាន)<br>• តម្រូវការធនធានបច្ចេកទេស<br>• តម្រូវការធនធានមនុស្ស។ | • អាចបង្កើនជំនាញនិងបច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ធ្វើឱ្យមានគណនេយ្យភាពក្នុងការបែងចែង គ្រប់គ្រងការងាររបស់ រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• អាចបង្កើនការចូលរួមកិច្ចសហប្រតិបត្តិការគ្នា រវាងរដ្ឋបាលមូលដ្ឋាន និងប្រជាពលរដ្ឋ និងម្ចាស់ជំនួយ។ | • ភាពយឺតយ៉ាវនៃការរៀបចំសេចក្តីសម្រេចរួម និងនីតិវិធីនៃកិច្ចដំណើរការរៀបចំត្រូវចំណាយពេលច្រើន<br>• ក្រុមការងាររបស់ក្រសួង និងស្ថាប័ន ដែលពាក់ព័ន្ធមានភាពមមាញឹកនឹង ការងារស្នូលរបស់ខ្លួន<br>• យន្តការនៃការផ្ទេរធនធានមនុស្ស និងហិរញ្ញវត្ថុមានភាពយឺតយ៉ាវ។ |

## ៤.៥ ស្ថានភាពឃុំដែលបានអនុវត្តនិងឃុំដែលមិនទាន់បានអនុវត្ត

### ៤.៥.១ ស្ថានភាពឃុំដែលបានអនុវត្តផ្ទេរមុខងារ (ឃុំមង់រៀវ)

ឃុំមង់រៀវ គឺជាឃុំមួយក្នុងចំណោមឃុំទាំង១៤ នៃស្រុកត្បូងឃ្មុំដែលបានកំណត់ថាជាឃុំគោលដៅ ដែលទទួលបានការអនុវត្តផ្ទាល់លើការផ្ទេរមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទនិងជាឃុំ ដែលមានបញ្ហាខូចខាតប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទច្រើនជាងគេក្នុងស្រុកត្បូងឃ្មុំ។ ឃុំមង់រៀវមានប្រជាជន សរុបចំនួន១០,៧៧២នាក់ ដែលត្រូវនឹងចំនួន២,១៧៨គ្រួសារ។ ឃុំមង់រៀវមានភូមិចំនួន១១ភូមិ ហើយប្រជាជន ស្ទើតែ៨៥% នៃប្រជាជនសរុបប្រកបរបរធ្វើស្រែចំការ។ ប្រភពទឹកចំបងដែលប្រជាជនប្រើប្រាស់នៅក្នុងឃុំ គឺអណ្តូងលូ និងអណ្តូងស្នប់។ ប្រជាជនប្រហែលជិត៨០% ប្រើប្រាស់អណ្តូងស្នប់ និង២០%ទៀតប្រើប្រាស់អណ្តូងលូ និងអណ្តូងចម្រុះ (ដោយមិនគិតពីការប្រើប្រាស់ទឹកភ្លៀង)។ នៅក្នុងឃុំមានអណ្តូងសរុបចំនួន ១,៥៣៥អណ្តូង ដែលនៅក្នុងនោះបែងចែកជាអណ្តូងស្នប់រូមអាហ្វ្រីដេស៍ (AFRIDEV) មានចំនួន ១៨អណ្តូង អណ្តូងចម្រុះចំនួន៣៧អណ្តូង អណ្តូងលូចំនួន៣០០អណ្តូង អណ្តូងស្នប់ឯកជនចំនួន១,១៧៥ អណ្តូង (តារាង៤.១)។

តារាង ៤.៩. ចំនួនអណ្តូងឃុំមង់រៀវឆ្នាំ២០១៦

| ឃុំ | អណ្តូងស្នប់រូម អាហ្វីដេស៍ | | អណ្តូងស្នប់រូម ខ្មៅលេខ៦ | | អណ្តូងចម្រុះ | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | ប្រើបាន | ខូច | ប្រើបាន | ខូច | ប្រើបាន | ខូច | |
| មង់រៀវ | 18 | 5 | 0 | 0 | 37 | 0 | |

ប្រភព: មន្ទីរអភិវឌ្ឍន៍ជនបទ, ២០១៦

ក្រុមប្រឹក្សាឃុំបានទទួលសេក្តីចប្រកាសការផ្ទេរមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គង់ផ្គង់ទឹកស្អាតជនបទ នៅថ្ងៃ០១ ខែមករា ឆ្នាំ២០១៥។ ឃុំ មានតួនាទី និងមុខងារយ៉ាងទូលំទូលាយក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដែលក្នុងនោះមានមុខងារ និងតួនាទីជាមូលដ្ឋាន គឺរក្សាសន្តិសុខនិងសណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ ចាត់ចែងសេវាសាធារណៈចាំបាច់ និងមើលការខុសត្រូវឱ្យកិច្ចការនោះដំណើរការបានល្អ លើកទឹកចិត្តឱ្យមានការបង្កើនជាសុខភាព និងសុខមាលភាពប្រជាពលរដ្ឋ ជម្រុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច ហើយលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យប្រសើរឡើងជាលំដាប់ព្រមទាំង ការពារនិងថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភ័ណ្ឌជាតិ ផ្សះផ្សារការខ្វែងមតិយោបល់គ្នា ហើយជម្រុញឱ្យមានការយោគយល់អត់ឱនទៅវិញទៅមក និងទទួលរ៉ាប់រងលើកិច្ចការបន្ថែមទៀត ដើម្បីបំពេញទៅតាមតម្រូវការរបស់ប្រជាពលរដ្ឋ (គ.ជ.អ.ប, ២០០២)។

បន្ថែមពីលើមុខងាររបស់ឃុំដែលមានស្រាប់ ក្រោយពីមានការផ្ទេរមុខងារ ប្រធានក្រុមប្រឹក្សាឃុំមានមុខងារបន្ថែមជាសមាជិកនៃគណៈកម្មាធិការជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ។ ប្រធានក្រុមប្រឹក្សាឃុំ និងគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ បានដើរតួជាអ្នករាយការណ៍នូវរាល់បញ្ហាដែលប្រជាពលរដ្ឋជួបប្រទះទាក់ទងទៅនឹងការជួសជុលអណ្តូង ដើម្បីធ្វើការផ្តល់ព័ត៌មានដល់រដ្ឋបាលស្រុក អំពីបញ្ហា និងតម្រូវការចាំបាច់ដែលត្រូវយកចិត្តទុកដាក់ នេះបើតាមសម្តីលោក ប្រធានក្រុមប្រឹក្សាឃុំមង់រៀវ។ ចំពោះមុខងារបន្ថែមនេះដែល គឺពិតជាអាចជួយពន្លឿនដល់ដំណើរការជួសជុលនិងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ។ ក្រោយពីបានទទួលការផ្ទេរមុខងារ យើងសង្កេតឃើញថាសមិទ្ធផល ដែលឃុំទទួលបានគឺការជួសជុល អណ្តូងស្នប់ប្រភេទអាហ្វ្រីដេវ ចំនួន ៥អណ្តូង។ ការជួសជុលនេះត្រូវបានធ្វើឡើងដោយមានការចូលរួមពីមន្ត្រីមន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ មន្ត្រីការិយាល័យអភិវឌ្ឍន៍ស្រុក និងមន្ត្រីរដ្ឋបាលស្រុក ដោយបានធ្វើការជួសជុលនូវអណ្តូងទាំងនោះទៅតាមស្ថានភាពជាក់ស្តែង ដោយអណ្តូងខ្លះមានការខូចខាតទម្រង់តូច និងខ្លះទៀតមានការខូចខាតទម្រង់ធំ និងជាទូទៅអណ្តូងទាំងនោះមានបញ្ហាដោយសារសន្ទះទប់ទឹកខូច ភ្លាត់ស្បែកស្នប់ សឹកទ្រនាប់កៅស៊ូ និងដាច់កៅស៊ូទប់បណ្តូលស្នប់ (សាលាស្រុកត្បូងឃ្មុំ, ២០១៦)។

ជាទៀងទាត់ គម្រោងវិនិយោគឃុំធ្វើត្រូវបានធ្វើឡើងក្នុងមួយឆ្នាំម្តង គឺធ្វើការត្រួតពិនិត្យបញ្ហា ឬតម្រូវការជាមួយប្រជាពលរដ្ឋ ការរៀបចំគម្រោងវិនិយោគឃុំ សិក្ខាសាលាសមាហរណកម្មផែនការស្រុក ការអនុម័តកម្មវិធីវិនិយោគឃុំ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោងវិនិយោគឃុំ។ ជំហានក្នុងការអនុវត្តគម្រោងវិនិយោគឃុំមានច្រើនជំហាន និងប្រើរយៈពេលយូរក្នុងសម្រេចបានសមិទ្ធផលគម្រោងនីមួយៗ។

យោងតាមការសម្ភាសលោកប្រធានក្រុមប្រឹក្សាឃុំមង់រៀវ បានឱ្យដឹងថាមុនពេលការផ្ទេរមុខងារគាត់បានដាក់ការស្នើសុំ ធ្វើការជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទតាមរយៈមន្ទីរអភិវឌ្ឍន៍ជនបទដោយបានធ្វើឡើងនៅខែឧសភា ឆ្នាំ២០១៥ ដោយមើលឃើញថាប្រជាពលរដ្ឋពិបាកក្នុងការប្រើប្រាស់ និងមិនអាចផ្គត់ផ្គង់តាមតម្រូវការប្រជាពលរដ្ឋ។ ហើយខាងមន្ទីរអភិវឌ្ឍន៍ជនបទបានជូនដំណឹងមកវិញថា នៅខែវិច្ឆិកា ឆ្នាំ២០១៥ និងចុះមកធ្វើការជួសជុល ប៉ុន្តែបែរជាមិនមានឃើញខាងមន្ទីរចុះមកជួសជុលទេ។

បន្ទាប់ពីមានការប្រកាសផ្ទេរមុខងារ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ ទើបខាងមន្ទីរអភិវឌ្ឍន៍ជនបទនិងរដ្ឋបាលស្រុកត្បូងឃ្មុំបានចុះមកត្រួតពិនិត្យ ស្រង់ស្ថិតិពីប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទដែលមានបញ្ហា និងវាយតម្លៃពីទំហំនៃការជួសជុល។ ក្រោយមកមន្ទីរអភិវឌ្ឍន៍ជនបទ និងរដ្ឋបាលស្រុកបានចុះមកធ្វើការជួសជុល។ ដូចនេះយើងអាចបញ្ជាក់បានថា មុនពេលនឹងមានការផ្ទេរមុខងារ បែបបទនៃការងាររដ្ឋបាលក្នុងដំណើរការស្នើសុំត្រូវការរយៈពេលយូរដើម្បីសុំទៅដល់ថ្នាក់ជាតិក្នុងទំលាក់កញ្ចប់ថវិកាក្នុងការជួសជុល។ ប៉ុន្តែក្រោយពីមានការផ្ទេរមុខងារ

មកដល់រដ្ឋបាលថ្នាក់ស្រុក ធ្វើឱ្យដំណើរការជួសជុលបានលឿនជាងមុន។ តារាងខាងក្រោមនេះបង្ហាញពីភាពខុសគ្នារវាងមុខងារចាស់ និងមុខងារថ្មីរបស់ក្រុមប្រឹក្សាឃុំ៖

តារាង ៤.១០. ភាពខុសគ្នារវាងមុខងារចាស់ និងមុខងារថ្មីរបស់ក្រុមប្រឹក្សាឃុំមង់រៀវ

| មុខងារចាស់ | មុខងារថ្មី |
|---|---|
| • រក្សាសន្តិសុខនិងសណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ<br>• ចាត់ចែងសេវាសាធារណៈចាំបាច់<br>• លើកទឹកចិត្ត ឱ្យមានការបង្កើនផាសុខភាព និងសុខមាលភាពប្រជាពលរដ្ឋ<br>• ជម្រុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច<br>• ការពារ និងថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភ័ណ្ឌជាតិ<br>• ផ្សះផ្សារការខ្វែងមតិយោបល់គ្នា។ | • រាយការណ៍នូវរាល់បញ្ហា ដែលប្រជាពលរដ្ឋជួបប្រទះទៅនឹងការជួសជុលអណ្តូង<br>• ស្នើសុំការជួសជុល<br>• ពិនិត្យមើល តម្រូវការចាំបាច់របស់ប្រជាពលរដ្ឋ<br>• ចូលរួមក្នុងដំណើរការជួសជុលអណ្តូងជាមួយមន្ទីរ និងស្រុក។ |

### ៤.៥.២ ស្ថានភាពឃុំដែលមិនទាន់ទទួលបានការអនុវត្តផ្ទេរមុខងារ (ឃុំជីគរ)

ឃុំជីគរ គឺជាឃុំមួយក្នុងចំណោមឃុំទាំង១៥នៃស្រុកត្បូងឃ្មុំដែលជាឃុំពុំទាន់ទទួលបានការផ្ទេរអំណាចអនុវត្តន៍មុខងារជួសជុលនិងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទសាកល្បង និងជាឃុំដែលមានបញ្ហាខូចខាតប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទច្រើនផងដែរបន្ទាប់ពីឃុំជប់។ ឃុំជីគរមានប្រជាជនសរុបចំនួន១០,៧៧២នាក់ ប្រមាណ២,១៧៨គ្រួសារ។ ឃុំជីគរមានភូមិចំនួន១៩ភូមិ នៅក្នុងឃុំមានអណ្តូងសរុបចំនួន១,៧៩៣អណ្តូង ដែលនៅក្នុងនោះបែងចែកជាអណ្តូងស្នប់រួមអាហ្វ្រិ-ដេស៍មានចំនួន១១អណ្តូងអណ្តូងស្នប់រួមខ្មៅលេខ៦ចំនួន១៣អណ្តូង អណ្តូងចម្រុះចំនួន៥អណ្តូង អណ្តូងលូចំនួន២៥១អណ្តូង អណ្តូងស្នប់ឯកជនចំនួន១,៥១៥អណ្តូង។

តារាង ៤.១១. ចំនួនអណ្តូងក្នុងឃុំជីគរឆ្នាំ២០១៦

| ឃុំ | អណ្តូងស្នប់រួម អាហ្វ្រីដេស៍ | | អណ្តូងស្នប់រួម ខ្មៅលេខ៦ | | អណ្តូងចម្រុះ | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | ប្រើបាន | ខូច | ប្រើបាន | ខូច | ប្រើបាន | ខូច | |
| ជីគរ | 11 | 11 | 13 | 5 | 4 | 1 | |

ប្រភព: មន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ, ២០១៦ខ

ឃុំជីគរជាឃុំដែលពុំទាន់បានទទួលផលពីការអនុវត្តមុខងារ ជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទនៅឡើយ បើយោងទៅតាមប្រសាសន៍លោកប្រធានក្រុមប្រឹក្សាឃុំជីគរផ្ទាល់តែម្តង។ នេះមិនមែនថា ពុំមានអណ្តូងខូចខាតនោះទេ ប៉ុន្តែការអនុវត្តមិនទាន់ដល់ឃុំរបស់គាត់។ ជាទូទៅ តាមរយៈការងារកន្លងមក ឃុំពុំធ្លាប់បានធ្វើការជួសជុលអណ្តូងនៅឡើយទេ ដោយហេតុថា កញ្ចប់ថវិកាអភិវឌ្ឍន៍ឃុំ មានកម្រិតតិច ហើយមានតម្រូវការអាទិភាពច្រើន។ ជាក់ស្តែង ចំពោះឃុំជីគរ កញ្ចប់ថវិកាអភិវឌ្ឍន៍ឃុំភាគច្រើនត្រូវបានយកទៅអភិវឌ្ឍន៍លើការសាងសង់ ជួសជុលផ្លូវថ្នល់ក៏ដូចជាការស្តារប្រព័ន្ធធារាស្រ្តជាដើម ដែលវាជាតម្រូវការចាំបាច់សម្រាប់ការរស់នៅ និងប្រកបរបររស់នៅរបស់ប្រជាជន ហេតុដូច្នេះហើយទើបធ្វើឱ្យឃុំពុំមានថវិកាគ្រប់គ្រាន់សម្រាប់ធ្វើការជួសជុលលើអណ្តូងទាំងនោះឡើយ។

ជាក់ស្តែង ដូចដែលបានរៀបរាប់ខាងលើ យើងឃើញថា ការងារជួសជុល នេះត្រូវទទួលបន្ទុក ដោយក្រុមអ្នកប្រើប្រាស់ទឹកផ្ទាល់ ជាមួយនឹងមន្ទីរអភិវឌ្ឍន៍ជនបទ។ កន្លងមក ក្រុមប្រឹក្សាឃុំក៏ធ្លាប់បានរាយការណ៍ពីចំនួន ប្រភពទឹកដែលខូចខាតដែរ ប៉ុន្តែនៅតែពុំឃើញមានការចុះទៅពិនិត្យមើលភ្លាមៗនោះទេ *«នេះបើតាមប្រសាសន៍លោកប្រធានក្រុមប្រឹក្សាឃុំ ជីគរ»*។

ជារួមតាមរយៈការប្រៀបធៀបឃុំទាំងពីរខាងលើ យើងឃើញថា សកម្មភាពក៏ដូចជារយៈពេលនៃការស្នើសុំធ្វើការជួសជុលអណ្តូង គឺមានភាពខុសប្លែកពីគ្នាប្រាកដមែន។ ជាក់ស្តែងសម្រាប់ឃុំមង់រៀវត្រូវបានមើលឃើញថា បែបបទនៃការងាររដ្ឋបាលក្នុងដំណើរការស្នើសុំការជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹក គឺត្រូវបានកាត់បន្ថយ ដែលជាហេតុធ្វើឱ្យរយៈពេលនៃការស្នើសុំក៏ដូចជារយៈពេលនៃការឆ្លើយតបក្នុងការជួសជុល ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ ក៏ត្រូវបានកាត់បន្ថយដូចគ្នាដែរ។ ផ្ទុយទៅវិញ ចំពោះឃុំជីគរ បែបបទនៃការងាររដ្ឋបាលក្នុងដំណើរការស្នើសុំការជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹក គឺនៅតែមានភាពស្មុគស្មាញ ដែលជាហេតុធ្វើឱ្យរយៈពេលនៃការស្នើសុំ ក៏ដូចជារយៈពេលនៃការឆ្លើយតប ការជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទគឺនៅតែមានភាពយឺតយ៉ាវដដែល។ សរុបមក ការអនុវត្តលើការផ្ទេរមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទមកដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ពិតជាបានធ្វើឱ្យមានភាពប្រសើរឡើងសម្រាប់ការអភិវឌ្ឍក្នុងតំបន់ពិតប្រាកដមែន។ ជាការពិតណាស់ ការផ្ទេរមុខងារទៅកាន់រដ្ឋបាលថ្នាក់ក្រោមជាតិនេះ បានធ្វើឱ្យមានការបង្វិតសេចក្តីសម្រេចចិត្តទៅជិតប្រជាពលរដ្ឋការបង្រួញគណនេយ្យភាពមានការបែងចែកការទទួលខុសត្រូវច្បាស់លាស់ និងដាច់ពីគ្នានិងការរៀបចំផែនការកាន់តែមានប្រសិទ្ធិភាពខ្ពស់ជាងមុនជាដើម។

សរុបមក តាមរយៈការរៀបរាប់ខាងលើពីតួនាទី និងរយៈពេលនៃការស្នើសុំលើការងារជួសជុលអណ្តូងរវាង ឃុំមង់រៀវដែលជាឃុំដែលបានទទួលការផ្ទេរមុខងារ និងឃុំជីគរដែលជាឃុំពុំទាន់បានទទួលការផ្ទេរមុខងារ យើងឃើញចំណុចខុសគ្នាមួយចំនួន។ ខាងក្រោមនេះជាតារាង

បង្ហាញពីភាពខុសគ្នារវាងឃុំ ដែលបានទទួលការផ្ទេរមុខងារនិងឃុំដែលពុំទាន់បានទទួលការផ្ទេរមុខងារៈ

តារាង ៤.១២. ភាពខុសគ្នារវាងឃុំដែលបានទទួលការផ្ទេរមុខងារ និងឃុំដែលពុំទាន់បានទទួលការផ្ទេរមុខងារ

| **ឃុំមង់រៀវ(បានអនុវត្តមុខងារ)** | **ឃុំជីគរ(ពុំទាន់អនុវត្តមុខងារ)** |
|---|---|
| • ទទួលបានការជួសជុលអណ្តូងច្រើនជាងមុន<br>• ដំណើរការនៃការស្នើសុំមានភាពងាយស្រួល មិនស្មុគស្មាញ<br>• រយៈពេលនៃការស្នើសុំលើការជួសជុលអណ្តូងខ្លីជាងមុន<br>• ការជួសជុលអណ្តូងត្រូវធ្វើឡើងដោយរដ្ឋបាលស្រុក។ | • ពុំធ្លាប់បានទទួលការជួសជុលអណ្តូងពីរដ្ឋបាលស្រុកឬពីមន្ទីរនៅឡើយទេ<br>• ដំណើរការនៃការស្នើសុំ មានភាពស្មុគស្មាញសាំញ៉ាំ<br>• រយៈពេលនៃការឆ្លើយតបយូរ<br>• ការជួសជុលអណ្តូងត្រូវធ្វើឡើងដោយក្រសួងអភិវឌ្ឍន៍ជនបទ។ |

## ៤.៦ សមត្ថភាពស្ថាប័នពាក់ព័ន្ធដែលមានស្រាប់ និងតម្រូវការ

### ៤.៦.១ សមត្ថភាពនិងតម្រូវការបន្ថែមសម្រាប់ពន្លឿនដំណើរការអនុវត្តរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ

#### ក. រចនាសម្ព័ន្ធការងារមុនការផ្ទេរមុខងារ ជួសជុល និងថែទាំ របស់មន្ទីរអភិវឌ្ឍន៍ជនបទ

ក្នុងនាមជាតំណាងរបស់ក្រសួងអភិវឌ្ឍន៍ជនបទ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំមានរចនាសម្ព័ន្ធការងារដូចខាងក្រោមៈ

- ប្រធានមន្ទីរអភិវឌ្ឍន៍
  - អនុប្រធានមន្ទីរអភិវឌ្ឍន៍
  - អនុប្រធានមន្ទីរអភិវឌ្ឍន៍
  - អនុប្រធានមន្ទីរអភិវឌ្ឍន៍

| | |
|---|---|
| ១. ការិយាល័យ អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ<br>២. ការិយាល័យរដ្ឋបាល<br>**៣. ការិយាល័យផ្គត់ផ្គង់ទឹកស្អាតជនបទ**<br>៤. ការិយាល័យគណនេយ្យ<br>៥.ការិយាល័យផែនការ និងស្ថិតិ | ៦. ការិយាល័យជនជាតិភាគតិច<br>៧. ការិយាល័យ អភិវឌ្ឍន៍សហគមន៍<br>៨.ការិយាល័យសុខភាពជនបទ<br>៩.ការិយាល័យផ្លូវជនបទ<br>១០. ការិយាល័យបណ្តុះបណ្តាល និងស្រាវជ្រាវ។ |

ដ្យាក្រាម ៤.៦. រចនាសម្ព័ន្ធការងាររបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ

ដូចដែលបានរៀបរាប់នៅក្នុងផ្នែកទី ៤.៣.១ ចំណុច ខ រួចមកហើយថា ការិយាល័យផ្គត់ផ្គង់ទឹកស្អាតជនបទខេត្តត្បូងឃ្មុំ ក្នុងមានជាតំណាងឱ្យមន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំលើការងារផ្គត់ផ្គង់ទឹកស្អាតជនបទគឺមានតួនាទី និងទទួលខុសត្រូវជាច្រើនដើម្បីឱ្យការងារផ្គត់ផ្គង់ទឹកស្អាតជនបទទទួលបានលទ្ធផលល្អប្រសើរ។ ដូចគ្នានេះដែរ ការិយាល័យផ្គត់ផ្គង់ទឹកស្អាតជនបទខេត្តត្បូងឃ្មុំមានសមាសភាពក្រុមការងារចំនួន៤នាក់ ដែលមានតួនាទីនិងការទទួលខុសត្រូវខុសៗគ្នា។ ជាក់ស្តែងបច្ចុប្បន្ននេះ ការិយាល័យនេះពុំទាន់មានប្រធានគ្រប់គ្រងនៅឡើយទេ ដោយសារប្រធានការិយាល័យចាស់បានចូលនិវត្តន៍។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ការិយាល័យផ្គត់ផ្គង់ទឹកស្អាតជនបទនៅតែមានដំណើរការដដែល ដោយសារការងារទាំងនោះត្រូវបានទទួលរ៉ាប់រងជំនួសបណ្តោះអាសន្នដោយអនុប្រធានការិយាល័យផ្ទាល់ ដែលជាហេតុធ្វើឱ្យគាត់មានការងារ និងការទទួលខុសត្រូវច្រើនជាងមុន។ យ៉ាងណាមិញ បើយើងពិនិត្យទៅលើសមត្ថភាពមន្ត្រីទទួលបន្ទុកទាំងនោះ យើងឃើញថា កម្រិតវប្បធម៌ ក៏ដូចជាបទពិសោធន៍របស់ពួកគាត់លើការងារនេះគឺមានបទពិសោធន៍យ៉ាងច្រើនលើការងារនេះដែរ។ ខាងក្រោមនេះជារចនាសម្ព័ន្ធការងាររបស់ការិយាល័យផ្គត់ផ្គង់ទឹកស្អាតជនបទខេត្តត្បូងឃ្មុំ និងតារាងស្តីពីតួនាទីនិងកម្រិតវប្បធម៌របស់មន្ត្រីនីមួយៗ។




ដ្យាក្រាម ៤.៧. រចនាសម្ព័ន្ធការងាររបស់ការិយាល័យផ្គត់ផ្គង់ទឹកស្អាតជនបទខេត្តត្បូងឃ្មុំ

តារាង ៤.១៣. តារាងបង្ហាញពីតួនាទី និងកម្រិតវប្បធម៌របស់មន្ត្រីការិយាល័យផ្គត់ផ្គង់ទឹកស្អាត

| **តួនាទី** | **កម្រិតវប្បធម៌** |
|---|---|
| ប្រធានការិយាល័យ | មានបទពិសោធន៍ជាង២០ឆ្នាំលើការងារទឹកស្អាតនិងអនាម័យជនបទ |
| អនុប្រធានការិយាល័យ | មានបទពិសោធន៍២០ឆ្នាំលើការជួសជុលផ្លូវថ្នល់និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទជាមួយ អង្គការ ប្រាសាក់ យូនីសេព និងមន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ |
| មន្ត្រីទទួលបន្ទុក | បរិញ្ញាបត្រផ្នែកទឹកក្រោមដី |
| មន្ត្រីទទួលបន្ទុក | បរិញ្ញាបត្រផ្នែកគ្រប់គ្រង(មានបទពិសោធន៍២១ឆ្នាំលើការជួសជុលផ្លូវនិងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ) |

ចំពោះកម្រិតវប្បធម៌របស់ក្រុមការងារខាងលើ យើងឃើញថាមានលក្ខណៈល្អប្រសើរ ពីព្រោះក្រុមការងារទាំងនោះសុទ្ធតែមានបទពិសោធន៍យ៉ាងក្រាស់ក្រែល លើការងារផ្គត់ផ្គង់ទឹកស្អាតជនបទជាពិសេសការងារជួសជុលនិងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ។

**ខ. តម្រូវការបន្ថែមសម្រាប់ការិយាល័យផ្គត់ផ្គង់ទឹកស្អាត និងមន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ**

ទោះបីជាដំណើរការអនុវត្តលើគម្រោងសាកល្បងលើ មុខងារជួសជុលនិងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទទទួលបានលទ្ធផលប្រមាណ៨០% នៃរយៈពេលសាកល្បងយ៉ាងណាក្តី ប៉ុន្តែក៏នៅតែមានតម្រូវការមួយចំនួនដើម្បី ធ្វើឱ្យការអនុវត្តលើការផ្ទេរមុខងារនេះទទួលបានភាពជោគជ័យ១០០% និងទាន់ពេលវេលា បើតាមប្រសាសន៍របស់លោក ប្រធានគណៈកម្មាធិការជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ។ ម្យ៉ាងវិញទៀត ដោយសារមន្ទីរអភិវឌ្ឍន៍ខេត្តត្បូងឃ្មុំទើបនឹងត្រូវបង្កើតថ្មី ដែលជាហេតុធ្វើឱ្យមានតម្រូវការមួយចំនួនចាំបាច់។ ខាងក្រោមនេះ គឺជាតម្រូវការមួយចំនួន ដែលមន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំស្នើសុំសម្រាប់បំពេញនូវចន្លោះខ្វះខាតនានានៅក្នុងដំណើរអនុវត្តលើការជួសជុលនិងថែទាំ។

- ស្នើសុំមន្ទីរពិសោធន៍គុណភាពទឹកផ្ទាល់ខ្លួនៈ ជាក់ស្តែងការធ្វើតេស្តទឹកកន្លងមកមន្ទីរពឹងផ្អែកទៅលើមន្ទីរពិសោធន៍គុណភាពទឹក របស់មន្ទីរខេត្តកំពង់ចាម។ វាពិតជាមានការ

លំបាកក្នុងការឆ្លងតប និងត្រូវការចំណាយរយៈពេលយូរ ក្នុងការយកសំណាកទៅវិភាគ។

- ស្នើសុំការផ្ទេរឯកសារ/ទិន្នន័យពាក់ព័ន្ធពីខេត្តកំពង់ចាមឱ្យបានឆាប់រហ័សៈ ជាការពិតណាស់ដោយហេតុថា ខេត្តត្បូងឃ្មុំជាជាខេត្តថ្មី រាល់ឯកសារចាស់ៗមួយចំនួនសុទ្ធតែនៅខេត្តកំពង់ចាមដែលជាហេតុធ្វើឱ្យមានការរាំងស្ទះការងារបន្ទាន់មួយចំនួន។
- ការផ្គត់ផ្គង់សម្ភារៈជួសជុល ជាសម្ភារៈដើមដែលមានគុណភាពល្អៈ ការផ្គត់ផ្គង់សម្ភារៈដែលមានគុណភាពអាចធានាបាននូវនិរន្តរភាពនៃការជួសជុលបាន។
- សូមឱ្យមានការចូលរួមរវាងដៃគូពាក់ព័ន្ធផ្សេងៗឱ្យបានកាន់តែច្រើន ដើម្បីជម្រុញការងារនិងសម្រេចបានគោលដៅដែលបានកំណត់ ជាក់ស្តែងវិស័យឯកជនក៏ជាកត្តាមួយជម្រុញនិងលើកម្ពស់កម្មវិធីទឹកស្អាតដល់សហគមន៍ផងដែរ (ក្រសួងអភិវឌ្ឍន៍ជនបទ, ២០១៣)។

ទោះបីជាខាងលើនេះជាតម្រូវការចាំបាច់របស់មន្ទីរអភិវឌ្ឍន៍ជនបទក្តីក៏ប៉ុន្តែ ប្រសិនបើយើងពិនិត្យមើលទៅលើភាពជាក់ស្តែងនៃធនធានបុគ្គលិកនៅក្នុងអង្គភាពមន្ទីរ យើងឃើញថានៅមានតម្រូវការបុគ្គលិកជំនាញមួយចំនួនទៀត។ យ៉ាងណាមិញ បើយោងទៅតាមការសម្ភាសយើងឃើញថា ការចាត់តាំងមុខងារ និងតួនាទីរបស់មន្ត្រីមួយចំនួននៅក្នុងអង្គភាព គឺមានភាពជាន់គ្នា។ ជាក់ស្តែង បើយើងក្រឡេកមើលទៅលើតួនាទីរបស់អនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទម្នាក់ យើងមើលឃើញថា គាត់ទទួលបន្ទុកលើតួនាទីចំនួនបី ក្នុងពេលតែមួយ ដោយក្នុងនោះគាត់មានតួនាទីជាអនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទផង ជាមន្ត្រីទទួលបន្ទុកផ្នែកទឹកស្អាតជនបទផងនិងជាប្រធានគណៈកម្មាធិការទទួលបន្ទុកលើការជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ ដែលជាហេតុធ្វើឱ្យគាត់មានទំនួលខុសត្រូវច្រើន និងជួនកាលអាចបណ្តាលឱ្យការអនុវត្តការងារពុំបានខ្ជាប់ខ្ជួន។ ម្យ៉ាងវិញទៀត បើយើងពិនិត្យទៅលើស្ថានភាពជាក់ស្តែងនៃការិយាល័យផ្គត់ផ្គង់ទឹកស្អាតជនបទ យើងឃើញថា ពុំទាន់មានការជ្រើសរើស ឬតែងតាំងបុគ្គលណាម្នាក់ឱ្យទទួលតួនាទីជាប្រធានការិយាល័យនៅឡើយទេ ដែលនេះអាចបណ្តាលឱ្យមានភាពខ្វះចន្លោះច្រើននៅក្នុងដំណើរការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ជនបទ ពីព្រោះទំហំការងារ និងចំនួនបុគ្គលិកទទួលខុសត្រូវគឺពុំមានតុល្យភាពឡើយ។ ជារួម យើងអាចបញ្ជាក់បានថា តម្រូវការបុគ្គលិកនៅក្នុងមន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ ក៏ដូចជាការិយាល័យផ្គត់ផ្គង់ទឹកស្អាតជនបទ គឺពិតជាតម្រូវការដ៏ចាំបាច់មួយសម្រាប់ការអនុវត្តលើការងារផ្គត់ផ្គង់ទឹកស្អាតជនបទពិតប្រាកដមែន។ ជាមួយគ្នានេះដែរ តម្រូវការមួយចំនួនទៀតដែលមន្ទីរអភិវឌ្ឍន៍ជនបទបានធ្វើការស្នើសុំនោះ គួរតែត្រូវទទួលបានឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន ពីព្រោះតម្រូវការទាំងនោះពិតជាអាចបំពេញនូវចន្លោះខ្វះខាតនានានៅក្នុងដំណើរការផ្គត់ផ្គង់ទឹកស្អាតជនបទពិតប្រាកដមែន។

### ៤.៦.២ សមត្ថភាពនិងតម្រូវការបន្ថែមសម្រាប់ពន្លឿនដំណើរការអនុវត្តរបស់រដ្ឋបាលស្រុកខេត្តត្បូងឃ្មុំ

#### ក. រចនាសម្ព័ន្ធស្រុក

ដូចគ្នានឹងការរៀបរាប់នៅក្នុងចំនុចទី៤.២ រួចមកហើយយើងឃើញថាសមាសភាពនៃបុគ្គលិកនៃរដ្ឋបាលស្រុកត្បូងឃ្មុំគឺពុំមានបញ្ហាចោទធំដុំទេ។ ដោយរដ្ឋបាលស្រុកមានរចនាសម្ព័ន្ធការងារច្បាស់លាស់ និងមានមន្រ្តីទទួលបន្ទុកការងារគ្រប់គ្រាន់ដែលជាហេតុធ្វើឱ្យដំណើរការការងាររបស់រដ្ឋបាលស្រុកមានភាពរលូន ម្យ៉ាងទៀតភាគច្រើននៃបុគ្គលិកទាំងនោះ គឺធ្វើការងារទៅតាមជំនាញ និងបទពិសោធន៍ត្រឹមត្រូវ។ខាងក្រោមនេះជារចនាសម្ព័ន្ធការងាររបស់រដ្ឋបាលស្រុកត្បូងឃ្មុំ៖




ដ្យាក្រាម ៤.៨. រចនាសម្ព័ន្ធការងាររបស់រដ្ឋបាលស្រុកត្បូងឃ្មុំ

#### ខ. តម្រូវការបន្ថែមសម្រាប់រដ្ឋបាលស្រុក

តាមរយៈការធ្វើប្រតិភូកម្មមុខងារថ្មីនេះ យើងអាចឃើញថា បច្ចុប្បន្ននេះរដ្ឋបាលស្រុកកំពុងជួបបញ្ហាមួយចំនួនពាក់ព័ន្ធជាមួយតម្រូវការបុគ្គលិក។ ជាក់ស្តែង ការផ្ទេរមុខងារជួសជុលនេះពុំមានការផ្ទេរបុគ្គលិកមកនៅឡើយទេ ដែលជាហេតុធ្វើឱ្យមានកង្វះខាតបុគ្គលិកមួយចំនួនសម្រាប់ដំណើរការការងារ។ យ៉ាងណាមិញ ដើម្បីឱ្យការងារជួសជុល និងថែទាំប្រព័ន្ធទឹកស្អាតជនបទនេះមានដំណើរការ ក្រុមប្រឹក្សារដ្ឋបាលស្រុកត្បូងឃ្មុំ ក៏បានធ្វើការប្រជុំដើម្បីធ្វើការចាត់តាំងក្រុមការងារថ្មីនេះស្របតាមការសម្រេចចិត្តរបស់អភិបាលនៃគណៈអភិបាលស្រុកត្បូងឃ្មុំ ហើយជាលទ្ធផលក្រុមការងារថ្មីនេះ គឺបង្កើតឡើងដោយជ្រើសយកបុគ្គលិកពីនាយកដ្ឋាន ក៏ដូចជាការិយាល័យមួយចំនួន ដែលធ្វើឱ្យការងាររបស់ពួកគាត់មានភាពត្រួតស៊ីគ្នានិងច្របូកច្របល់។

ក្នុងនោះដែរ ដើម្បីបំពេញចន្លោះខ្វះខាត និងបញ្ហាទាំងនោះពាក់ព័ន្ធនឹងការងារនៅក្នុងអង្គភាពរដ្ឋបាលស្រុកក៏មានសំណើមួយចំនួនផងដែរដែលមានដូចខាងក្រោម៖

- សំណើរផ្សេងៗទាក់ទងជាមួយធនធានមនុស្ស៖ ត្រូវការមន្ត្រីការិយាល័យដើម្បីជួយសម្របសម្រួលការងាររបស់គណៈកម្មាធិការជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ។
- ផ្តល់ការណែនាំបច្ចេកទេស និងការងារប្រតិបត្តិការថែទាំ៖ ត្រូវការវគ្គបណ្តុះបណ្តាលខ្លីដើម្បីជួយផ្តល់ជាចំណេះដឹងទៅការប្រតិបត្តិការងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ។
- ជួយរៀបចំគម្រោងថែទាំ និងធ្វើផែនការថវិកា
- ជួយកសាងសមត្ថភាពមន្ត្រីសាលាស្រុកលើការងារជួសជុលតូចនិងធំ៖ សូមឱ្យមានដៃគូពាក់ព័ន្ធ ឬដៃគូអភិវឌ្ឍន៍បង្កើនការបណ្តុះបណ្តាលពាក់ព័ន្ធនឹងការផ្ទេរមុខងារថ្មីដើម្បីជួយកសាងសមត្ថភាពមន្ត្រីសាលាស្រុក។

យោងទៅតាមសំណើរពីរដ្ឋបាលស្រុកខាងលើយើងឃើញថា វាពិតជាតម្រូវការដ៏ចាំបាច់បំផុតសម្រាប់ដំណើរការការងារមែន។ ជាក់ស្តែងតម្រូវការទាំងនោះភាគច្រើនពាក់ព័ន្ធជាមួយការផ្ទេរមុខងារ។ ដោយសារពុំធ្លាប់បានធ្វើការជួសជុល និងមិនធ្លាប់ធ្វើការងារដែលផ្តោតសំខាន់លើការងារជួសជុលនិងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ជាហេតុធ្វើឱ្យការងារទាំងឡាយត្រូវពឹងផ្អែកលើមន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ ដែលមានគណៈកម្មាធិការទទួលបន្ទុកជួសជុលនិងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជាអ្នកជំនួយការ។ ម្យ៉ាងទៀត ដោយយល់ឃើញថាមានតែតម្រូវការខាងលើនេះទេ ដែលអាចធ្វើឱ្យក្រុមការងារនេះមានភាពជាម្ចាស់លើការងារផ្ទាល់ខ្លួនព្រមទាំងអាចបង្កើននូវប្រសិទ្ធិភាពនៃការអនុវត្តមុខងារបានទៀតផង។

### ៤.៦.៣ តម្រូវការបន្ថែមសម្រាប់ពន្លឿនដំណើរការអនុវត្តរបស់ក្រុមប្រឹក្សាឃុំ មង់រៀវ និងឃុំ ជីគរ

ចំពោះតម្រូវបន្ថែមសម្រាប់ឃុំ គឺធ្វើការស្នើសុំទៅដល់ថ្នាក់ស្រុក ឬមន្ទីរ ជួយស្វះស្វែងក្នុងការរកអ្នកវិនិយោគទុនមិនថាអង្គការ ឬវិស័យឯកជន លើប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតតាមទុយោដើម្បីធានាបាននូវការប្រើប្រាស់ទឹកប្រកបដោយសុវត្ថិភាពរបស់ប្រជាពលរដ្ឋមូលដ្ឋាន និងធ្វើការស្នើសុំដល់ថ្នាក់ស្រុក ធ្វើការជួសជុលអណ្តូងខូចដែលនៅសល់ ឱ្យបានទាន់ពេលវេលាដើម្បីសម្រួលដល់ការប្រើប្រាស់របស់ប្រជាពលរដ្ឋដែលពុំមានលទ្ធភាពប្រើប្រាស់ប្រភពទឹកផ្ទាល់ខ្លួន។

### ៤.៦.៤ តម្រូវការបន្ថែមសម្រាប់ពន្លឿនដំណើរការអនុវត្តរបស់ក្រុមអ្នកប្រើប្រាស់ទឹក

យោងតាមការសម្ភាស ប្រធានក្រុមអ្នកប្រើប្រាស់ទឹក មានប្រសាសន៍ថា តម្រូវការចំបាច់សម្រាប់ក្រុមអ្នកប្រើប្រាស់ទឹកស្អាត គឺត្រូវការនូវគ្រឿងបន្លាស់ដែលមានគុណភាពល្អដើម្បីធ្វើការជួសជុលតូចដោយខ្លួនឯងបាន។ យោងតាមបទពិសោធន៍កន្លងមករបស់លោកពូដែលជាមេក្រុមអ្នកប្រើប្រាស់ទឹកស្អាត មានប្រសាសន៍ថា ក្នុងជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ជួបប្រទះ

បញ្ហាគ្រឿងបន្លាស់ដែលមិនមានគុណភាពដែលធ្វើឱ្យការប្រើប្រាស់ពុំបានយូរ គឺធ្វើហើយបានមួយសប្តាហ៍ក៏ខូចវិញ។ គាត់ធ្លាប់ទំនាក់ទំនងទៅមន្ទីរអភិវឌ្ឍន៍ ដើម្បីសួររកគ្រឿងបន្លាស់ដែលមានគុណភាពល្អប៉ុន្តែ នៅលើទីផ្សារអ្នកផ្គត់ផ្គង់មិនមានគ្រឿងបន្លាស់ ដែលមានគុណភាពខ្ពស់ (ដាច់ស្តុក)។

ជារួមសម្រាប់តម្រូវការរបស់ក្រុមនីមួយៗ យើងឃើញថា ភាគច្រើននៃតម្រូវការទាំងនោះ គឺពាក់ព័ន្ធជាមួយធនធានមនុស្ស បច្ចេកទេស ប្រព័ន្ធទិន្នន័យ ដែលមានពីមុនការចូលរួមពីគ្រប់វិស័យ និងតម្រូវការទីពិសោធន៍របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ។ ចំពោះធនធានមនុស្ស/បុគ្គលិក ជាតម្រូវការចាំបាច់បំផុតសម្រាប់រដ្ឋបាលស្រុក ក៏ដូចជាមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ព្រោះប្រសិនបើមានធនធានមនុស្សគ្រប់គ្រាន់វាអាចធ្វើឱ្យដំណើរការនៃការអនុវត្តមុខងារ ឬការងារផ្គត់ផ្គង់ទឹកស្អាតទទួលបានភាពជោគជ័យយ៉ាងរលូន។ មួយវិញទៀតតម្រូវការបច្ចេកទេសការបណ្តុះបណ្តាលផ្សេងៗក៏មានសារៈសំខាន់ណាស់ផងដែរ ដែលវាអាចធ្វើឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងនេះ មានទស្សនៈនិងការយល់ដឹងកាន់តែច្បាស់ពីការអនុវត្តន៍លើមុខងាររបស់ខ្លួននិងអនុវត្តការងារទាំងនោះឱ្យមានប្រសិទ្ធិភាពផងដែរ។ ជាមួយគ្នានោះដែរ តម្រូវការមន្ទីរពិសោធន៍ផ្ទាល់ខ្លួនរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ ក៏ជាចំណុចសំខាន់ណាស់ដែរ ព្រោះវាអាចធ្វើឱ្យដំណើរការត្រួតពិនិត្យគុណភាពទឹក កាន់តែទទួលបានភាពសុក្រឹត្យ និងត្រឹមត្រូវតាមកម្រិតបទដ្ឋានរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ព្រមទាំងចំនេញទាំងពេលវេលា និងថវិកាថែមទៀតផង។ ក្រៅពីនោះ យើងក៏មើលឃើញនូវ តម្រូវការផ្សេងៗទៀតដែរ ដែលវាសុទ្ធតែជាតម្រូវការសំខាន់ក្នុងការអនុវត្តលើមុខងាររបស់ខ្លួន ទៅតាមកម្រិតនីមួយៗដូចគ្នា។

# ជំពូក ៥
# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សា យើងអាចសន្និដ្ឋានបានថាការផ្ទេរមុខងារជួសជុលនិងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ស្រុកត្បូងឃ្មុំពិតជាមានប្រសិទ្ធិភាពពីព្រោះវាបានជួយពន្លឿនទៅដល់ការងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ និងបានបង្កិតការសម្រេចចិត្តដល់រដ្ឋបាលក្រោមជាតិ។ ដោយការធ្វើប្រតិភូកម្មមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ របស់ក្រសួងអភិវឌ្ឍន៍ជនបទ បានកំណត់នូវមុខងាររងចំនួន៥ផ្ទេរទៅឲ្យរដ្ឋបាលស្រុក។

ចំពោះសមិទ្ធផលដែលរដ្ឋបាលស្រុក សម្រេចបានក្រោយពេលធ្វើប្រតិភូកម្មមុខងារក្នុងរយៈពេលកន្លងមក គឺមានដូចជាការជួសជុលនូវអណ្តូងស្នប់សហគមន៍ប្រភេទ អាហ្វ្រីដេវ (AFRIDEV) បានចំនួន៥អណ្តូង និងប្រភេទអណ្តូងរួមខ្មៅលេខ៦ (ក្បាលខ្មៅ) ចំនួន៤អណ្តូង។ ជាក់ស្តែង បើយោងតាមរបាយការណ៍បូកសរុបលទ្ធផលជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទរវាងឃុំទាំងពីរគឺមានភាពខុសប្លែកពីគ្នា។ ចំពោះឃុំដែលបានទទួលការអនុវត្ត (ឃុំមង់រៀវ) គឺសម្រេចបានការជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទចំនួន៥ អាចប្រើប្រាស់បានចំនួន៧៥គ្រួសារ។ ឃុំដែលមិនទាន់មានការអនុវត្ត(ឃុំជីគរ) គឺមិនទាន់បានទទួលការជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទនោះទេ។

ការគ្រប់គ្រងប្រព័ន្ធនៃដំណើរការនីមួយៗតែងតែមានភាពខ្លាំង ភាពខ្សោយ ឱកាស និងភាពប្រឈមរៀងៗខ្លួន។ ជាក់ស្តែងនៅក្នុងប្រព័ន្ធនៃការធ្វើកំណែទម្រង់ ការផ្ទេរមុខងារជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏មាននូវភាពខ្លាំង ភាពខ្សោយ ឱកាស និងភាពប្រឈមរបស់វាដែរ។ កត្តាទាំងនោះត្រូវបានគេបែងចែកជា២ធំៗ គឺឥទ្ធិពលនៃផលប៉ះពាល់ក្នុង និងឥទ្ធិពលនៃផលប៉ះពាល់ក្រៅ។ ទោះបីជាយ៉ាងនេះក្តី បើយើងពិនិត្យមើលទៅមើលស្ថានភាពជាក់ស្តែងនៃប្រព័ន្ធនេះ យើងឃើញថា ភាពខ្លាំងនៃប្រព័ន្ធគឺមានច្រើនជាងឥទ្ធិពលផ្សេងៗ។

លើសពីនេះទៅទៀតការសិក្សានេះបានវិភាគបន្ថែមនូវតម្រូវការផ្សេងៗនៃក្រុមគោលដៅទាំង៤ ដែលពាក់ព័ន្ធនឹងការអនុវត្តការជួសជុល និងថែទាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន៖

- មន្ទីរពិសោធន៍គុណភាពទឹកសម្រាប់មន្ទីរអភិវឌ្ឍន៍
- ស្នើសុំការផ្ទេរឯកសារ/ទិន្នន័យពាក់ព័ន្ធពីខេត្តមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម
- ការចូលរួមរវាងដៃគូពាក់ព័ន្ធផ្សេងៗ ដើម្បីជម្រុញការងារនិងសម្រេចបានគោលដៅដែលបានកំណត់បានឆាប់រហ័ស
- ធនធានមនុស្សបន្ថែម
- វគ្គបណ្តុះបណ្តាល លើមុខងារជួសជុលនិងថែទាំបន្ថែម

- តម្រូវការគ្រឿងបន្លាស់ដែលមានគុណភាពល្អ។

ជារួមតាមរយៈប្រសិទ្ធផលនៃករណីសិក្សានៃឃុំទាំងពីរខាងលើ គឺជាការបង្ហាញឱ្យឃើញពីល្បឿន នៃការអនុវត្តមុខងារផ្គត់ផ្គង់ទឹកស្អាតទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយជាផ្នែកមួយជួយសម្រេចនូវគោលដៅផែនការយុទ្ធសាស្ត្រជាតិផងដែរ។

## ៥.២ អនុសាសន៍

❖ ចំណុចគួរអនុវត្ត

ដើម្បីជាការជម្រុញ ឲ្យដំណើរការនៃការអនុវត្តលើការផ្ទេរមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទដល់រដ្ឋបាលថ្នាក់ក្រោមជាតិមានភាពប្រសើរឡើង ក្រុមសូមផ្តល់នូវអនុសាសន៍មួយចំនួនដូចខាងក្រោម៖

- រដ្ឋបាលថ្នាក់ជាតិ គួរតែពន្លឿននូវដំណើរការរៀបចំ និងនិតីវិធីមួយចំនួនឲ្យបានឆាប់រហ័សដើម្បីឲ្យដំណើរការនៃការអនុវត្តមុខងារប្រព្រឹត្តទៅតាមផែនការដែលកំណត់ទុក
- រដ្ឋបាលថ្នាក់ជាតិគួរតែពន្លឿននូវដំណើរការផ្ទេរធនធានមនុស្ស និងហិរញ្ញវត្ថុឲ្យបានឆាប់រហ័ស
- រដ្ឋបាលថ្នាក់ជាតិគួរតែកំណត់នូវពេលវេលានៃដំណើរការអនុវត្ត (Timeframe) ឲ្យបានច្បាស់លាស់
- បង្កើនវគ្គបណ្តុះ ស្តីពីការថែទាំនិងជួសជុលរដ្ឋបាលស្រុកនិងក្រុមអ្នកប្រើប្រាស់ទឹក
- ក្នុងដំណើរការធ្វើលទ្ធកម្មដេញថ្លៃក្នុងការជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត រដ្ឋបាលថ្នាក់ក្រោមជាតិគួរតែធ្វើការផ្សព្វផ្សាយព័ត៌មានឲ្យបានទូលំទូលាយ ដើម្បីឲ្យមានការចូលរួមរវាងអ្នកដេញថ្លៃច្រើន និងមានតម្លាភាពក្នុងការដេញថ្លៃ
- រដ្ឋបាលស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ និងមន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ គួរតែពន្លឿននូវដំណើរស្នើសុំឯកសារមួយចំនួនពីរដ្ឋបាលខេត្តកំពង់ចាម ដើម្បីកុំឲ្យមានភាពរាំងស្ទះនៃដំណើរការការងារស្រួលមួយចំនួន
- ពង្រឹងនូវកិច្ចសហប្រតិបត្តិការចូលរួមរវាងអ្នកពាក់ព័ន្ធនានា នៃវិស័យផ្គត់ផ្គង់ទឹកស្អាតជនបទ។

❖ ចំនុចគួរសិក្សាបន្ត

- ប្រៀបធៀបពីប្រសិទ្ធផលរបស់ស្រុកដែលបានអនុវត្ត និងស្រុកដែលមិនបានអនុវត្តការផ្ទេរមុខងារ
- អាចធ្វើការប្រៀបធៀបពីដំណើរការ និងប្រសិទ្ធផលនៃការអនុវត្តមុខងាររវាងខេត្តត្បូងឃ្មុំ និងខេត្តកំពត ដើម្បីស្វែងយល់ឲ្យកាន់តែស៊ីជម្រៅនូវផលប៉ះពាល់ក្នុង និងផលប៉ះពាល់ក្រៅដែលមានឥទ្ធិពលទៅដល់ដំណើរការនៃការអនុវត្តគម្រោងសាកល្បងនេះ

- គួរតែសិក្សាបន្ថែម ពីឥទ្ធិពលនៃអ្នកពាក់ព័ន្ធមួយចំនួន រួមមានៈ អង្គការសង្គមស៊ីវិល អង្គការក្រៅរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនមួយចំនួនទៀតលើដំណើរការជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ៕

# ឯកសារយោងខ្មែរ


ក្រសួងមហាផ្ទៃ. (២០០១). *ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់.*

ក្រសួងអភិវឌ្ឍន៍ជនបទ.(២០១៦ខ).*ផែនការសកម្មភាពជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យនៅជនបទឆ្នាំ ២០១៤-២០១៨*

ក្រសួងអភិវឌ្ឍន៍ជនបទ.(២០១៦ក). *របាយការណ៍បូកសរុបសកម្មភាពការងារប្រចាំឆ្នាំ ២០១៥ និងទិសដៅការងារឆ្នាំ ២០១៦ របស់ក្រសួងអភិវឌ្ឍន៍ជនបទ។*

ក្រសួងអភិវឌ្ឍន៍ជនបទ. (២០១៦គ). *វឌ្ឍនភាពការងារប្រចាំខែមេសា ឆ្នាំ២០១៦របស់ក្រសួងអភិវឌ្ឍន៍ជនបទ.*

ក្រសួងអភិវឌ្ឍន៍ជនបទ. (២០១៥ឃ). *គោលការណ៍ណែនាំក្រុមអ្នកប្រើប្រាស់ទឹកស្អាត និងអនាម័យ (WSUG).*

ក្រសួងអភិវឌ្ឍន៍ជនបទ. (២០១៥គ). *គោលការណ៍ណែនាំថ្នាក់ជាតិ ស្តីពី គុណភាពទឹកផឹកជនបទ.*

ក្រសួងអភិវឌ្ឍន៍ជនបទ. (២០១៥ក). *សេចក្តីសម្រេចរួមស្តីពីការអនុវត្តមុខងារសាកល្បងផ្ទេរជុលនិងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទរវាងក្រសួងអភិវឌ្ឍន៍ជនបទនិងរដ្ឋបាលស្រុកត្បូងឃ្មុំ.*

ក្រសួងអភិវឌ្ឍន៍ជនបទ. (២០១៥ខ). *ការផ្ទេរប្រតិភូកម្មមុខងារ និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទជូនរដ្ឋបាលស្រុកឈូក ស្រុកជុំគីរី ស្រុកបន្ទាយមាស និងស្រុកកំពង់ត្រាចនៃខេត្តកំពត និងស្រុកមេមត់ ស្រុកត្បូងឃ្មុំ និងស្រុកក្រូចឆ្មារនៃខេត្តត្បូងឃ្មុំ។*

ក្រសួងអភិវឌ្ឍន៍ជនបទ. (២០១៤ក). *ផែនការយុទ្ធសាស្ត្រជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងលើកកំពស់អនាម័យនៅជនបទ ឆ្នាំ២០១៤-២០២៥.*

ក្រសួងអភិវឌ្ឍន៍ជនបទ. (២០១៤ខ). *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ (ផយរជ) ២០១៤-២០១៨*

ក្រសួងអភិវឌ្ឍន៍ជនបទ. (២០១១). *យុទ្ធសាស្ត្រជាតិស្តីពីវិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ ២០១១-២០២៥*

ក្រសួងអភិវឌ្ឍន៍ជនបទ.*ចំណេះដឹងទូទៅនៃលក្ខណៈអណ្តូង.*

មន្ទីរខេត្តត្បូងឃ្មុំ, ម. (២០១៦). *ផែនការសកម្មភាព និងថវិកានៃការិយាល័យទឹកស្អាត ៣ឆ្នាំរំកិល (២០១៧,២០១៨,២០១៩).*

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់.(២០០៥). *អភិបាលកិច្ចល្អសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ រៀបរៀងដោយនាយដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ២០០៥។*

គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ.(២០០៨).*ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ*

គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ.(២០០៩). *សៀវភៅណែនាំស្តីពី ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់។*

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ.(២០១៦). *កិច្ចប្រជុំលើកទី១១ វឌ្ឍនភាព និងបញ្ហាប្រឈមសំខាន់ៗនៃការអនុវត្តផែនការអនុវត្ត ផែនការសេកម្មភាព និងថវិកាឆ្នាំ២០១៥។*

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ.(២០១០ក). *កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(២០១០-២០១៩)*

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ.(២០១០ខ). *ផែនការអនុវត្តបីឆ្នាំដំបូង (២០១១-២០១៣) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (ផអ៣)*

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ. (២០១៤ ក). *ផែនការអនុវត្តបីឆ្នាំដំណាក់កាលទីពីរ (២០១៥-២០១៧) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(ផអ៣ទី២).*

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ.(២០១៤ខ). *គោលនេយបាយស្តីពីប្រព័ន្ធផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ.*

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ.(២០១៥). *សៀវភៅណែនាំស្តីពី ការអនុវត្តគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។*

នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ. (២០១៤). *សៀវភៅជំនួយសាម្មរតីសហគមន៍ការប្រើប្រាស់ទឹកស្អាត និងការអនុវត្តអនាម័យល្អ.*

មន្ទីរអភិវឌ្ឍន៍ជនបទ. (២០១៥ខ). *ស្ថិតិអណ្តូងទឹក និងបណ្តាញចែកចាយទឹកស្អាតដែលសំរេចបានក្នុងខេត្តត្បូងឃ្មុំគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០១៥.*

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ. (២០១៥ក). *ទិន្នន័យអណ្តូងគ្រប់ប្រភេទ,អាងត្រងទឹកភ្លៀង, ស្ថានីយផលិតទឹកសុទ្ធ,ប្រឡាយ និងស្រះសហគមន៍ក្នុងខេត្តត្បូងឃ្មុំ ឆ្នាំ២០១៥.*

សាលាស្រុកត្បូងឃ្មុំ.(២០១៥). *សេចក្តីសម្រេចស្តីពីការរៀបចំក្រុមការងារទទួលមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទស្រុកត្បូងឃ្មុំ*

រដ្ឋសភា. (២០០១). *ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់.*

រាជរដ្ឋាភិបាលកម្ពុជា.(២០១៤). *របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ២០១៣ ស្តីពី ការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា*

រាជរដ្ឋាភិបាលកម្ពុជា.(២០០២).*អនុក្រឹត្យ ស្តីពីការធ្វើវិមជ្ឈការអំណាចតួនាទីនិងភារកិច្ចទៅឲ្យក្រុមប្រឹក្សាឃុំ សង្កាត់។*

រាជរដ្ឋាភិបាលកម្ពុជា.(២០១៣).*អនុក្រឹត្យ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និង សេចក្តីណែនាំស្តីពី បញ្ជីវិភាគមុខងារ និងការពិនិត្យមើលមុខងារឡើងវិញ*

រាជរដ្ឋាភិបាលកម្ពុជា. (២០១០). *កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩*

រាជរដ្ឋាភិបាលកម្ពុជា.(២០០៩). *អនុក្រឹត្យស្តីពីតួនាទី ភារៈកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក*

រាជរដ្ឋាភិបាលកម្ពុជា. (២០០៥). *អភិបាលកិច្ចល្អសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់.*

វណ្ណា,ផ.(២០១៤.).*សៀវភៅទិន្នន័យភូមិសង្កាត់(ឃុំមង់រៀវ)ឆ្នាំ២០១៤).*

## ឯកសារយោងអង់គ្លេស

CDBonline. (2010). *http://db.ncdd.gov.kh/cdbonline/home/index.castle*

CDB.*(2014). Profile on Economic and social in Year 2015*

DHS. (2015). *Cambodia Demographic and Health Survey 2014.*

Israel, Glen D. (2009) *Determining sample size.* Gainesville, FL: Florida State University, Cooperative Extension Service.

National Istitute of Statistics Ministry of Planning . (2015). *Cambodia Socio-Economic Survey 2014.*

SNV. (២០១៦). *វគ្គបណ្តុះបណ្តាលគន្លឹះមុនពេលចាប់ផ្តើមអនុវត្តគម្រោង.*

UNICEF, 2014. *The Rights to Safe Water And To Sanitation.* UNICEF Position Paper.

van't Land Gerhard. ( 2012). *Mid term review of the implementation plan 2011-13 (IP-3).*

WHO &UNICEF. (2016). *JMP:Joint Monitoring Programme* http://www.wssinfo.org/documents/?tx_displaycontroller%5Btype%5D=country_files

WHO &UNICEF. (2016). *JMP:Joint Monitoring Programme* http://www.wssin fo.org/documents/?tx_displaycontroller%5Btype%5D=country_files.

# ឧបសម្ព័ន្ធ ក

## បញ្ជីសំណួរសម្រាប់ការសម្ភាសន៍មន្ត្រីមន្ទីរអភិវឌ្ឍន៍ជនបទស្រុកត្បូងឃ្មុំ

១. តើរចនាសម្ព័ន្ធនៃការចាត់តាំងមន្ត្រីជំនាញ និងមន្ត្រីការិយាល័យដើម្បីគាំទ្ររដ្ឋបាលថ្នាក់ស្រុកមានលក្ខណៈដូចម្តេច?

២. តើមន្ត្រីទទួលបន្ទុកផ្នែកជួសជុល និងថែទាំប្រព័ន្ធប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតមានប៉ុន្មាននាក់? កម្រិតវប្បធម៌ដូចម្តេច?

៣. តើមន្ទីរមានការទទួលខុសត្រូវលើមុខងារអ្វីខ្លះ នៅក្នុងដំណើរការផ្គត់ផ្គង់ទឹកស្អាតជនបទ មុនពេល និង ក្រោយពេល ការធ្វើប្រតិភូកម្មមុខងារ?

៤. តើទិសដៅការងាររបស់មន្ទីរលើមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គត់ទឹកស្អាតជនបទមានអ្វីខ្លះ?

៥. តើសកម្មភាព របស់មន្ទីរ មុននិងក្រោយ ពេលធ្វើប្រតិភូកម្មមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទនៅក្នុងស្រុកត្បូងឃ្មុំមានអ្វីខ្លះ?

៦. តើដំណើរការនៃការអនុវត្តប្រតិភូកម្ម មុខងារជួសជុលនិងថែទាំប្រព័ន្ធផ្គត់ផ្គត់ទឹកស្អាតជនបទ ទទួលបានលទ្ធផលអ្វីខ្លះ?

៧. តើមន្ទីរមានផែនការថ្មីបន្ថែមសម្រាប់ការអនុវត្តការងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទឬទេ?បើមាន អ្វីខ្លះ? បើគ្មាន ហេតុអ្វី?

៨. តើការផ្ទេរមុខងារថ្មីនេះបានជួយពន្លឿនការងារជួសជុលនិងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទដែរឬទេ?

៩. តើមន្ទីរមានបានបង្កើតវគ្គបណ្តុះបណ្តាលលើផ្នែកជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទដែរឬទេ?

១០. តើការចំណាយជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទអស់ប៉ុន្មានមុន និងពេលអនុវត្តន៍ប្រតិភូកម្ម?

១១. តើមានឧបសគ្គ/បញ្ហាប្រឈមអ្វីខ្លះដែលធ្លាប់បានជួបប្រទះមុនពេល និងក្រោយពេលធ្វើប្រតិភូកម្មមុខងារ?

១២. តើកិច្ចសហប្រតិបត្តិការរវាងមន្ទីរ និងអង្គការនានាមានការប្រែប្រួលដែរឬទេ មុន និងក្រោយពេលការផ្ទេរមុខងារថ្មី?

១៣. តើលោក/លោកស្រីមានតម្រូវការអ្វីខ្លះសម្រាប់បំពេញចន្លោះខ្វះខាតនានាក្នុងដំណើរការគាំទ្រលើការអនុវត្តប្រតិភូកម្មមុខងារទាំងនេះ?

១៤. តើលោក/លោកស្រី មានមតិយោបល់អ្វីខ្លះចំពោះការផ្ទេរមុខងារខាងលើនេះ?

# ឧបសម្ព័ន្ធ ខ
## បញ្ជីសំណួរសម្រាប់ការសម្ភាសន៍មន្ត្រីរដ្ឋបាលស្រុក ឃុំ/ភូមិ

១. តើប្រភពទឹកដែលប្រជាជនប្រើប្រាស់នៅក្នុងឃុំ/ភូមិ មានអ្វីខ្លះ? (អណ្តូងឯកជន អណ្តូងសហគមន៍ អណ្តូងចម្រុះ ស្រះសហគមន៍)

២. តើនៅក្នុងភូមិ/ឃុំមានអណ្តូងសរុបចំនួនប៉ុន្មាន?អណ្តូងស្នប់ចំនួនប៉ុន្មាន? អណ្តូងលូចំនួនប៉ុន្មាន?អណ្តូងចម្រុះចំនួនប៉ុន្មាន? ស្រះសហគមន៍ចំនួនប៉ុន្មាន? បណ្តាញចែកចាយទឹករបស់សហគមន៍ចំនួនប៉ុន្មាន? ប្រភពទឹកនីមួយៗខូចចំនួនប៉ុន្មាន? និងប្រភពទឹកតាមប្រភេទនីមួយៗដែលត្រូវបានស្តារ និងជួសជុលចំនួនប៉ុន្មាន?

៣. តើអត្រាប្រើប្រាស់របស់ប្រជាជនតាមប្រភពនីមួយៗមានប៉ុន្មានភាគរយ?

៤. តើការផ្ទេរមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនេះត្រូវបានអនុវត្តន៍ចាប់ផ្តើមពី ថ្ងៃ ខែ ឆ្នាំណាមក?

៥. តើរដ្ឋបាលភូមិ/ឃុំ មានមុខងារអ្វីខ្លះក្នុងការថែទាំ និងជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត?

៦. រដ្ឋបាលភូមិ/ឃុំបានទទួលមុខងារបន្ថែមថ្មីអ្វីខ្លះ លើមុខងារដែលមានស្រាប់បន្ទាប់ពីការផ្ទេរមុខងារ?

៧. តើការអនុវត្តលើការជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកមុនពេល និងក្រោយពេលផ្ទេរមុខងារ ខុសគ្នាដូចម្តេច?

៨. តើភូមិ/ឃុំប្រើរយៈពេលប៉ុន្មានក្នុងការស្នើសុំការជួសជុល និងថែទាំអណ្តូងមុន និងក្រោយ ការផ្ទេរមុខងារ?

៩. តើសមិទ្ធផលអ្វីខ្លះដែលឃុំ/ភូមិសម្រេចបាន ក្រោយពេលទទួលបានការផ្ទេរមុខងារ?

១០. តើនៅក្នុងភូមិ/ឃុំមានក្រុមអ្នកប្រើប្រាស់ទឹកដែរឬទេ? បើមាន តើលោកពូមានបានចូលរួមគាំទ្រក្នុងដំណើរការបង្កើតក្រុមអ្នកប្រើប្រាស់ទឹកដែរឬអត់? បើមិនមាន តើលោកពូមានផែនការក្នុងការបង្កើតក្រុមអ្នកប្រើប្រាស់ទឹកដែរឬទេ? ចង់បង្កើតឆ្នាំណាដែរ និងចង់ជួយអ្វីខ្លះដល់ក្រុមអ្នកប្រើប្រាស់ទឹក?

១១. តើលោកពូមានបានទទួលការបណ្តុះបណ្តាលអំពីមុខងារ ជួសជុលនិងថែទាំអណ្តូងដែរឬទេ?

១២. តើភូមិ/ឃុំមានបានបង្កើតវគ្គបណ្តុះបណ្តាលផ្នែក ជួសជុល និងថែទាំអណ្តូងទៅដល់ក្រុមអ្នកប្រើប្រាស់ទឹកដែរឬទេ?

១៣. តើលោក/លោកស្រី មានផែនការអ្វីខ្លះក្នុងការអនុវត្តពេលបច្ចុប្បន្ន និងអនាគត?

១៤. តើការផ្ទេរមុខងារ ជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទបានជួយពន្លឿនដល់ដំណើរការអភិវឌ្ឍប្រព័ន្ធផ្គត់ផ្គត់ទឹកស្អាតជនបទដែរឬទេ?

១៥. តើអ្វីខ្លះជាផលវិបាក ក្នុងដំណើរការអនុវត្តលើមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅក្នុងមូលដ្ឋាន?

១៦. តើមានអង្គការណាខ្លះដែលមានបទពិសោធន៍លើការផ្គត់ផ្គង់ទឹកកន្លងមកនៅក្នុងភូមិ/ឃុំ?

១៧. តើមានអង្គការណាខ្លះដែលមានបទពិសោធន៍លើការជួសជុល និងថែទាំប្រព័ន្ធនៃការផ្គត់ផ្គង់ទឹកកន្លងមក?

១៨. តើលោក/លោកស្រីមានតម្រូវការអ្វីខ្លះពីថ្នាក់ជាតិ និងមន្ទីរ សម្រាប់ការបំពេញចន្លោះខ្វះខាតនានា ក្នុងដំណើរការអនុវត្តប្រតិភូកម្មមុខងារទាំងនេះ? (មិនគិតពីបញ្ហាថវិកា)

១៩. តើលោក/លោកស្រីមានជាមតិយោបល់អ្វីខ្លះចំពោះការធ្វើកំណែទម្រង់ថ្មីនេះ?

# ឧបសម្ព័ន្ធ គ
# បញ្ជីសំណួរសម្រាប់ការសម្ភាសន៍ប្រជាជនបទស្រុកត្បូងឃ្មុំ

ជម្រាបសួរខ្ញុំបាទ/នាងខ្ញុំ ជាក្រុមនិស្សិតឆ្នាំទី៤ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ធ្វើការសិក្សាស្រាវជ្រាវដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រក្រោមប្រធានបទ "**ការសិក្សាលើដំណើរការនៃអភិបាលកិច្ចថ្នាក់ក្រោមជាតិសម្រាប់ ការជួសជុលនិងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ**" ក្នុងឃុំមង់រៀវ និងឃុំជីគរស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។ យើងខ្ញុំនឹងអះអាងថា ព័ត៌មានដែលបានមកពីការឆ្លើយតបរបស់លោកអ្នកនឹងយកទៅប្រើប្រាស់ ក្នុងគោលបំណងសម្រាប់តែការសិក្សាស្រាវជ្រាវតែប៉ុណ្ណោះ។ រាល់ការឆ្លើយតបរបស់លោកអ្នកមិនមែនជាចម្លើយខុស ឬត្រូវឡើយ តែវាជាការបង្ហាញពីពត៌មាននិងការអនុវត្តផ្ទាល់កន្លងមកដែលមាន។

ថ្ងៃខែ ឆ្នាំ សម្ភាសន៍.................................................

## I. ពត៌មានទូទៅ

១. ឈ្មោះអ្នកឆ្លើយតប: ..........................................................

២. ភេទ

(ក) ស្រី (ខ) ប្រុស

៣. មុខរបរ...........................................

៤. អស័យស្ថាន..................................................................................................

## II. ពត៌មានទូទៅ

១. តើគុណភាពទឹកអណ្ដូងទទួលយកបានដែរឬទេ?

ក. បាន ខ.មិនបាន

២. តើលោកពូ/អ្នកមីងពេញចិត្តនិងដំណើការជួសជុលដែរឬទេ? ហេតុអ្វី?

.....................................................................................................................

២. តើលោកពូ/អ្នកមីង ប្រើប្រាស់ទឹកអស់ប៉ុន្មានលីត្រជាមធ្យមក្នុងមួយថ្ងៃ?

.....................................................................................................................

.....................................................................................................................

៣. តើលោកពូ/អ្នកមីងមានសំណើរឬសំណូមពរអ្វីខ្លះ ចំពោះការផ្គត់ផ្គង់ប្រព័ន្ធទឹកស្អាតជនបទ? (ការជួសជុល និងថែទាំអណ្ដូង)

.....................................................................................................................

.....................................................................................................................

# ឧបសម្ព័ន្ធ ឃ
# ទម្រង់ស្នើសុំការជួសជុលអណ្ដូងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ



ទម្រង់ WS-1

ខេត្ត៖..........

ស្រុក៖..........

**ទម្រង់ស្នើសុំការជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ**

| | |
|---|---|
| ប្រព័ន្ធផ្គត់ផ្គង់៖ ☑ អណ្ដូងស្នប់ ☐ អណ្ដូងលូ ☐ ស្រះ ☐ ផ្សេងៗ........ | |
| ប្រភេទស្នប់៖ ☑ AFRIDEV ☐ ក្បាលខ្មៅ No.6 ☐ ផ្សេង........ | |
| លេខកូដអណ្ដូង (បើមាន)៖ 091 | |
| ទីតាំងប្រព័ន្ធ៖ | ឈ្មោះម្ចាស់ផ្ទះ៖ ភូមិ ឃុំ |
| ថ្ងៃខែឆ្នាំកសាងប្រព័ន្ធ៖ | ថ្ងៃ ខែ ឆ្នាំ |
| កសាងដោយ៖ | JICA |
| តំណាង WSUG៖ | ឈ្មោះ:..........Tel:.......... |
| ចំនួនគ្រួសារប្រើប្រាស់៖ | |

ស្ថានភាពប្រព័ន្ធ៖

☐ បាក់ស្រុតកំរាលសាប ☑ ស្នប់ខូច ☐ សប់តឹង ☐ សប់អត់ចេញទឹក

☐ សប់ចេញទឹកតិច ☐ គុណភាពទឹកមិនល្អ ☐ បញ្ហាផ្សេងៗ..........

រយៈពេលខូច៖..........

បានឃើញ៖ ស្នើសុំដោយ៖

ប្រធានVDC/ប្រធានភូមិ សាន់_ចិន្ដា តំណាងសហគមន៍(ស្នាមមេដៃ)

ថ្ងៃ.13...ខែ.02..ឆ្នាំ2016 ថ្ងៃ..........ខែ..........ឆ្នាំ..........

សំគាល់៖

១. តំណាងសហគមន៍ត្រូវបំពេញទម្រង់ WS-1 គ្រប់អណ្ដូងដែលបានស្នើសុំជួសជុល

២. ប្រធាន VDC ឬប្រធានភូមិត្រូវបញ្ជាក់លើទម្រង់ WS-1 ហើយបញ្ជូនទម្រង់មករដ្ឋបាលស្រុក

# ឧបសម្ព័ន្ធ ខ

## ទម្រង់ប៉ាន់ស្មានតម្លៃសម្រាប់ជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹក



ខេត្ត៖ ស្វាយ រៀង

ស្រុក៖ ស្វាយ ជ្រំ

**ទម្រង់ប៉ាន់ស្មានតម្លៃសម្រាប់ជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ**

| | | | |
|---|---|---|---|
| ប្រព័ន្ធផ្គត់ផ្គង់៖ ☑ អណ្តូងស្នប់ ☐ អណ្តូងលូ ☐ ស្រះ ☐ ផ្សេងៗ.................... | | | |
| ប្រភេទស្នប់៖ ☑ AFRIDEV ☐ ក្បាលខ្មៅ No.6 ☐ ផ្សេង.................... | | | |
| លេខកូដអណ្តូង៖ | លេខនិយាមកា(GPS): X: 0567919 Y: 1316149 | | |
| ទីតាំងប្រព័ន្ធ៖ | ឈ្មោះម្ចាស់ផ្ទះ: [illegible] | ភូមិ [illegible] | ឃុំ |
| ថ្ងៃខែឆ្នាំកសាងប្រព័ន្ធ៖ | ថ្ងៃ | ខែ | ឆ្នាំ |
| កសាងដោយ៖ | | | |
| តំណាង WSUG៖ | ឈ្មោះ: [illegible] Tel:.................... | | |
| ចំនួនគ្រួសារប្រើប្រាស់៖ | | | |
| ពិនិត្យដល់ទីតាំងដោយ៖ | | | |

| ☐ ជួសជុលតូច | | ☐ ជួសជុលធំ |
|---|---|---|
| ☑ ខូចក្លាប៉េ | ☑ ភ្ជាក់ស្បែកស្នប់ | ☐ ប្តូរក្បាលស្នប់ ☐ បែកបំពង់ជញ្ជាំងអណ្តូង |
| ☐ សឹកបាក ឬចំាដាង | ☑ សឹកអ័ក្សស្នប់ | ☐ ផ្លុំសម្អាតអណ្តូង ☐ បែកធ្លាយបំពង់ស្នប់ |
| ☑ សឹកពីស្តុង | ☑ សឹកទ្រនាប់កៅស៊ូ | ☐ បាក់ស្រុតកំរាលសាប |
| ☑ ដាច់កងកៅស៊ូ | ☐ សឹកស្បែកស្នប់ | ☐ ជីកឲ្យជ្រៅ (អណ្តូងលូ/ស្រះ) |
| ☑ សន្ទះទប់ទឹកខូច | ☑ ដាច់កៅស៊ូទប់បណ្តូលស្នប់ | ☐ ប្តូរលូដែលបាក់ខូច (អណ្តូងលូ) |
| ☐ សឹកពិស្តុងសន្ទះទប់ទឹក | ☐ ដាច់ដែកបណ្តូលស្នប់ | ☐ ស្តារ (ស្រះ/ប្រឡាយ) |
| ☐ រម្លើងជើងស្នប់ | ☐ ផ្សេងៗ.................... | |

| **តម្លៃប៉ាន់ស្មានសម្រាប់ការជួសជុល៖** | |
|---|---|
| ថ្លៃគ្រឿងបន្លាស់ (រៀល)៖ | 275 000 |
| សេវាជាងជួសជុល (រៀល)៖ | 231 000 |
| សរុបថ្លៃជួសជុល (រៀល)៖ | 506 000 |

| បានឃើញ(មន្ត្រីទទួលបន្ទុករដ្ឋបាលស្រុក)៖ | វាយតម្លៃដោយ(មន្ត្រីបច្ចេកទេស)៖ |
|---|---|
| ឈ្មោះ:.................... | ឈ្មោះ:.................... |
| ថ្ងៃ..........ខែ..........ឆ្នាំ.......... | ថ្ងៃ..........ខែ..........ឆ្នាំ.......... |

សំគាល់៖ បន្ទាប់ពីទទួលបានការស្នើសុំការជួសជុលពីសហគមន៍ រដ្ឋបាលស្រុកត្រូវស្នើសុំមន្ត្រីបច្ចេកទេសពីការិយាល័យអភិវឌ្ឍន៍ជនបទឬមន្ទីរអភិវឌ្ឍន៍ជនបទ ដើម្បីសិក្សាពីការខូចខាត

# ឧបសម្ព័ន្ធ ច

## គំរូទម្រង់សម្រាប់កត់ត្រាលទ្ធផលនិងគុណភាពទឹករបស់SNV

<table>
<tr><td colspan="3">ទម្រង់សម្រាប់កត់ត្រាលទ្ធផលពិសោធន៍គុណភាពទឹក</td></tr>
<tr><td colspan="3">កំណត់ត្រាសារធាតុគីមី និងលក្ខណៈរូប</td></tr>
<tr><td colspan="3"></td></tr>
<tr><td>ថ្ងៃ ខែ ឆ្នាំ៖</td><td colspan="2" rowspan="3">ទីតាំងអណ្តូង៖ភូមិ ឃុំ<br>ស្រុក៖ ខេត្ត<br>កូអរដោនេ៖ X Y<br>ស្ថានភាពអាកាសធាតុ៖</td></tr>
<tr><td>ម៉ោង៖</td></tr>
<tr><td>ឈ្មោះអ្នកធ្វើពិសោធន៍៖</td></tr>
<tr><td colspan="3"></td></tr>
<tr><td>ប៉ារាម៉ែត្រដែលត្រូវធ្វើតេស្ត</td><td>លទ្ធផល</td><td>បទដ្ឋានធៀប</td></tr>
<tr><td>pH</td><td></td><td>៦-៨.៥</td></tr>
<tr><td>ដែក(Fe)</td><td></td><td>០.៣ mg/l</td></tr>
<tr><td>អាសេនិច(As)</td><td></td><td>០.០៥ mg/l</td></tr>
<tr><td>ម៉ង់កាណែស(Mn)</td><td></td><td>០.៤ mg/l</td></tr>
<tr><td>ភាពរឹងនៃទឹក(Total Hardness)</td><td></td><td>៥០០ mg/l</td></tr>
<tr><td>នីត្រាត($NO_3$)</td><td></td><td>៥០ mg/l</td></tr>
</table>

# ឧបសម្ព័ន្ធ ឆ

# គំរូសារពើភ័ណ្ឌអណ្តូងរបស់SNV

| | |
|---|---|
| ថ្ងៃ ខែ ឆ្នាំ៖ | |
| ខេត្ត៖ | ស្រុក៖ |
| ឃុំ៖ | ភូមិ៖ |

| | |
|---|---|
| ១ | ឈ្មោះម្ចាស់ដី/ទីតាំង៖ |
| ២ | ប្រភេទផ្គត់ផ្គង់ទឹក៖ □អណ្តូងស្នប់ □អណ្តូងលូ □អណ្តូងចម្រុះ □ស្រះសហគមន៍ □ប្រព័ន្ធទុយោទឹក □ផ្សេងៗ(រៀបរាប់) |
| ៣ | លេខកូដអណ្តូងស្នប់៖ |
| ៤ | ប្រភេទអណ្តូងស្នប់៖ □ស្នប់អាហ្រ្វេដេហ្វ □ស្នប់លេខ៦ □ផ្សេងៗ(រៀបរាប់) |
| ៥ | ដំណើរការ៖ □ពេញលេញ □ផ្នែកខ្លះ □ខូច □បោះបង់ចោល |
| ៦ | ផ្នែកខូចខាត៖ □បែកបំពុងអណ្តូង □រងកំណកដី □បែកបំពុងស្នប់ □បាក់ស្រុតកំរាលសាប □នីវ៉ូទឹកស្រកចុះ |
| ៧ | ថ្ងៃ ខែ ឆ្នាំកសាង៖ |
| ៨ | កូអរដោនេទីតាំង៖ X: Y: |
| ៩ | ភាពជាម្ចាស់៖ □ឯកជន □សារធារណ:/សហគមន៍ □ស្ថាប័ន |
| ១០ | ក្រុមអ្នកប្រើប្រាស់ទឹកស្អាតនិងអនាម័យ៖ □ដំណើរការ □មិនដំណើរការ |
| ១១ | ជម្រៅអណ្តូង៖ .................ម៉ែត្រ |
| ១២ | ប្រវែងបំពង់ស្នប់៖ .................ម៉ែត្រ |
| ១៣ | កម្ពស់ទឹកស្ថាតិច៖ .................ម៉ែត្រ |
| ១៤ | ទិន្នផលទឹក៖ .................ម៉ែត្រគូប/ម៉ោង |
| ១៥ | ចំនួនគ្រួសារដែលប្រើ៖ .................រដូវប្រាំង .................រដូវវស្សា |
| ១៦ | តើទឹកហ្នឹងអាចផឹកបានទេ? □បាន □មានបញ្ហាតែអាចផឹកបាន □មិនបាន |

| អ្នកស្រង់ទិន្នន័យ | អ្នកត្រួតពិនិត្យ | បញ្ជាក់ដោយ |
|---|---|---|
| ឈ្មោះ | ឈ្មោះ | ឈ្មោះ |